ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jun-2013, 14:56
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១៩៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ (Judge Silvia CARTWRIGHT)

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ (Judge Jean-Marc LAVERGNE)

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោកឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល *(Mr. Vincent de wilde d'ESTMAEL)*

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិុចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ងួ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោកស្រី ស្វ សុជាតិ (TCW-673) | ខ្មែរ |
| លោក ស៊ឹម ហោ (TCW-648) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី សូ សុជាតិ** (TCW-673)

សួរបន្តដោយលោក ឃីត វេយ៍ន័រ ផ្តើមពី..........ទំព័រ ២

សួរដោយលោក ហុង គឹមសួន ផ្តើមពី..........ទំព័រ ១៦

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី..........ទំព័រ ២៣

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ឹម ហោ** (TCW-648)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី..........ទំព័រ ៣៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្តាឯល ផ្តើមពី..........ទំព័រ ៤០

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី..........ទំព័រ ៧៥

សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី..........ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅថ្ងៃនេះ ដំណើរការសវនាការយើងនឹងបន្តស្តាប់សក្ខីកម្មសាក្សី សូ សុជាតិ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-648។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងដំណើរការសវនាការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ថាដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មថ្ងៃនេះមានពីររូប។ ព្រឹកនេះនឹងបន្តស្តាប់នូវសក្ខីកម្មរបស់សាក្សីលោកស្រី សូ សុជាតិ។ សាក្សីរូបនេះមានវត្តមានក្នុងបន្ទប់សវនាការ។

ទី២ គឺស្តាប់នូវសក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-648។ សាក្សីរូបនេះមានវត្តមានផងដែរ។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដូចបានបញ្ជាក់នៅក្នុងឯកសារ E288។ សាក្សីនេះជាសាក្សីថ្មី។ ដូច្នេះមិនមានរហស្សនាមនោះទេ។

សូមអរគុណ។

[០៩:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។ បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមជម្រាបថា អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់លោកគឺមានរយៈពេល ២៥នាទីជាអតិបរមាក្នុងការ ជា

រយៈពេលដែលសមស្របក្នុងការតាំងសំណួរចុងក្រោយចំពោះសាក្សីរូបនេះរបស់តំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ អរុណសួស្ដីភាគីទាំងអស់ មេធាវី។ ខ្ញុំសូមចាប់ផ្តើម។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ដោយយោងលើសារទូរលេខដែលមានលេខសម្គាល់ E ឯកសារ E282.1.19។ នេះគឺជាសារទូរលេខចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៧៤។ សារទូរលេខនេះចេញមកពីសហរដ្ឋអាមេរិក មានប្រភពចេញមកពីសហរដ្ឋអាមេរិក។ កថាខណ្ឌទី៧ មានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "នាយករដ្ឋមន្រ្តីស្តីទីរបស់ក្រុង និងមេបញ្ជាការកងទ័ព ខៀវ សំផន បានចេញនូវសេចក្តីអំពាវនាវមួយចំនួនទៅដល់យុវជន និស្សិត និងបញ្ញាជន និងទៅដល់កងទ័ព និងសាធារណជន ព្រះសង្ឃ និងបុគ្គលិករដ្ឋាភិបាលទាំងអស់។

[០៩:០៦:៥៣]

អំពាវនាវតាមវិទ្យុបានបង្ហាញនូវការយល់ឃើញអំពី -- បានអំពាវនាវលើកឡើងអំពីការលំបាកផ្នែកសេដ្ឋកិច្ច ហើយនិងលើកឡើងអំពីការប្តេជ្ញា បន្តវាយសម្រុកបន្តទៀត។ ហើយគាត់បានស្នើសុំឲ្យអ្នកស្តាប់ទាំងអស់ក្រោកឈរឡើង ហើយធ្វើការវាយសម្រុកៗឃ្លាំងអង្គរ ហើយយ៉ាងហោចណាស់ គឺមិនត្រូវធ្វើអ្វីទាំងអស់ផ្នែករាងកាយ និងផ្នែកសីលធម៌ដែលនាំទៅដល់ការញុះញង់ ឬជំរុញឲ្យជាផលប្រយោជន៍របស់បនក្បត់"។ បញ្ចប់ការដកស្រង់សម្តី។

លោកស្រី សូ សុជាតិ ខ្ញុំសូមសួរសំណួរឡើងវិញ។ តើលោកស្រីធ្លាប់បានស្តាប់ឮប្តីរបស់លោកស្រីចេញជាសេចក្តីអំនាវពាវធ្វើការបន្ត ធ្វើការអំនាវពាវឲ្យមន្ត្រីរដ្ឋាភិបាលនៅក្នុងសម័យនុ៎ង ចុះចូលជាមួយគាត់ដែរឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ខ្ញុំអត់ដែលឮ។

[០៩:០៨:៣៩]

**ស៖** ខ្ញុំសូមយោងលើសារទូរលេខមួយទៀត គឺចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ ឯកសារមានលេខ E282.1.22។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

[០៩:០៩:១៣]

**លោក អាកទូរ វែកតែន៖**

បាទលោកប្រធាន ខ្ញុំមិនចង់ជំទាស់ទេ ក៏ប៉ុន្តែការសួរសំណួរអម្បាញ់មិញនេះ គឺថា ដូចថាមាន យើងត្រូវតែគោរពទៅតាមវិធានរបស់អង្គជំនុំជម្រះ គឺថាត្រូវតែផ្តល់ជូនទៅដល់ភាគីជាមុននូវឯកសារ ដែលខ្លួនចង់ប្រើប្រាស់នៅក្នុងពេលសួរសំណួរសាក្សី។ ក៏ប៉ុន្តែតួលេខដំបូងដែលសហព្រះរាជអាជ្ញាបាន លើកឡើងអម្បាញ់មិញនេះ គឺមិនមាននៅក្នុងអាំងទែរហ្វាសទេ ហើយឯកសារទី២ ទូរលេខទី២អម្បាញ់ មិញនេះក៏អត់មានដែរ។

កាលពីម្សិលមិញ នៅពេលចប់សវនាការនោះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា គាត់នៅសល់ បីទំព័រទៀត។ ដូច្នេះខ្ញុំពិបាកនឹងយល់ណាស់ថា គាត់បញ្ជាក់យ៉ាងម៉េចនោះ ហើយឯកសារដែលគាត់ លើកឡើងនោះគឺថាមិនមាននៅក្នុងឯកសារ នៅក្នុងអាំងទែរហ្វាស ទេ។ ដូច្នេះ តើអង្គជំនុំជម្រះនៅតែ អនុញ្ញាតឱ្យសហព្រះរាជអាជ្ញាប្រើប្រាស់ឯកសារដែលមិនបានបញ្ជាក់ជូនភាគីជាមុនទៀត ឬក៏យ៉ាង ណា? ដូច្នេះ សូមឱ្យអង្គជំនុំជម្រះសម្រេចលើបញ្ហានេះជាមុនសិន។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ជំហររបស់យើងខ្ញុំនោះ គឺថាឯកសារមិនបានទាញយកដោយខ្លួនខ្ញុំផ្ទាល់ កាលពី យប់មិញនោះទេ។ គឺឯកសារនេះបានពិភាក្សាដោយខ្ញុំ និងអ្នកផ្សេងទៀតក្នុងការទាញយកប្រភពផ្សេង នោះ។ ហើយខ្ញុំបានទាញយកឯកសារនេះម៉ោងដប់យប់មិញ ហើយទើបដាក់ចូលម៉ោងប្រាំមួយព្រឹកតែ ប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំមិនបានដាក់បញ្ចូលឱ្យបានទាន់ពេលវេលា។

[០៩:១០:៥៩]

នេះគឺជាឯកសារមួយដែលសំខាន់។ សារទូលេខនេះគឺមានសារៈសំខាន់ណាស់ គឺវាបង្ហាញអំពី អង្គហេតុដែលក្រុមមេធាវីការពារក្តីបានដាក់ពាក្យញត្តិជូនអង្គជំនុំជម្រះលើកឡើងថា សារទូលេខនេះក៏ មានការពាក់ព័ន្ធដែរ តាមការយល់ឃើញរបស់មេធាវីការពារក្តី។ ហេតុដូច្នេះ ខ្ញុំស្នើសុំអនុញ្ញាតឱ្យខ្ញុំបន្ត

ទៅមុខទៀត។ សូមអធ្យាស្រ័យពីខាងមេធាវីការពាក្តី ដែលខ្ញុំកាលពីយប់មិញមិនបានដាក់ចូលក្នុងប្រព័ន្ធអ៊ីនធីហ្វេស។

[០៩:១១:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន។ ខ្ញុំគិតថាទូលេខទាំងអស់នេះ គឺជាទូលេខដែលយកចេញមកពីវេបសាយ *វីគីលីត* ហើយឯកសារហ្នឹងគឺថាប្រហែលជានឹងមានការប្រកាសបដិសេធដោយអង្គជំនុំជម្រះនាពេលខាងមុខនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៣:០១]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំសូមអនុញ្ញាតលើកឡើងបន្តិចលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៤:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

ជម្រាបលោកថា លោកមានពេលវេលាតិចណាស់ ហើយមិនគប្បីបង្កើតនូវបញ្ហាដែលជួបប្រទះធ្វើឱ្យតុលាការបាត់បង់ពេលវេលាច្រើននៅក្នុងការពិភាក្សា ចំពោះឯកសារដែលលោកមានបំណងដេញដោលនោះទេ។ លោកគប្បីប្រើប្រាស់ឯកសារណាដែលសមស្រប ដែលមានលទ្ធភាពដែលអង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យដាក់ពិភាក្សាដេញដោល។

សូមបញ្ជាក់នូវបញ្ហាដែលកំពុងប្រឈមនេះ តើមានប្រភពមកពីណា ហើយតើដូចការជំទាស់របស់មេធាវីការពារក្តីដែរឬទេ?

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានជាទីគោរព។ ខ្ញុំសូមពន្យល់ ឯកសារនេះគឺឯកសារចំណាត់ថ្នាក់ D ដែលយើងហៅថាជាឯកសារមកពីប្រភព *វីគីលីក*។ វាជាឯកសារធ្វើចំណាត់ថ្នាក់ E ហើយមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ហើយថាឯកសារនេះគឺគាត់លើកឡើងថាឯកសារនេះមិនមានតម្លៃជាភស្តុតាង ក៏ប៉ុន្តែវាមានលក្ខណៈសំខាន់។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានបន្តទៅមុខទៀត។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៦:១៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តទៅមុខទៀត បើលោកមិនពាក់ព័ន្ធទៅនឹងឯកសារដែលមានការជំទាស់នេះទេ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សួ សុជាតិ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ក្រោយពីការកាន់កាប់ទីក្រុងភ្នំពេញ លោកស្រីនៅវិហារព្រះកែវមរកតនោះប៉ុន្មានខែដែរ? ហើយប្រហែលជាដល់រហូតពាក់កណ្តាលឆ្នាំ ១៩៧៥ ទើបលោកស្រីធ្វើដំណើរទៅមន្ទីរ ក-៣។ តើអ៊ីចឹងដែរឬទេ?

**លោកស្រី សួ សុជាតិ៖**

**ឆ៖** ចាស គឺវិហារព្រះកែវ គឺទៅ ក-១ អត់ទៅ ក-៣ មុនទេ។ ហើយខ្ញុំមិនចាំថាប៉ុន្មានខែៗទេ ប៉ុន្តែទៅ ក-១ មុន។

[០៩:១៧:៤០]

**ស៖** នៅក្នុងភស្តុតាងដែលលោកស្រីបានឆ្លើយនៅថ្ងៃទី១០ ខែមិថុនា ត្រង់ប្រតិចារឹកម៉ោង ១៤:៣៧:៤៦ លោកស្រីបាននិយាយឆ្លើយដូច្នេះដូចតទៅ។ “ខ្ញុំនៅព្រះវិហារកែវមរកតប៉ុន្មានខែដែរគឺប្រហែលដល់ចុងឬពាក់កណ្តាលឆ្នាំ១៩៧៥ ទើបខ្ញុំបានទៅមន្ទីរ ក-១”។ តើចម្លើយដែលលោកស្រី ឆ្លើយនេះត្រឹមត្រូវដែរឬទេ? ជាការពិតដែរឬទេ?

**ឆ៖** ជាការពិត។

**ស៖** នៅក្នុងការផ្តល់សក្ខីកម្មថ្ងៃដដែលគឺម៉ោង ១៤:៤០:២១៧ លោកស្រីបានឆ្លើយថា “ក-១ គឺជាកន្លែងធ្វើការរបស់មេដឹកនាំ។ មេដឹកនាំដូចជា ប៉ុល ពត, នួន ជា ពួកគាត់រស់នៅមន្ទីរ ក-១ នោះ។ ហើយមានអ្នកខ្លះទៀតក៏រស់នៅក្នុងមន្ទីរ ក-១ នោះផងដែរ”។ លោក ខៀវ សំផន ស្នាក់នៅទីនោះជាមួយ នឹង ប៉ុល ពត និង នួន ជា។ តើមែនដែរឬទេ?

**ឆ៖** ចាស មែន។

**ស៖** នៅពេលដែលលោកស្រីនិយាយថាអ្នកផ្សេងក៏នៅទីនោះផងដែរជាមួយនឹង ប៉ុល ពត និង នួន ជា។ តើអ្នកណាគេទៅដែលលោកស្រីសំដៅអ្នកខ្លះទៀតនោះក៏នៅទីនោះដែរ? តើជាអ្នកណាគេដែរ?

[០៩:១៩:៣៨]

**ឆ៖** ពេលនោះ យើងខ្ញុំមិនស្គាល់ទាំងអស់ទេ ច្បាស់ជាងគេគឺ ប៉ុល ពត, នួន ជា, ខៀវ សំផន, តា អៀង សារី។ ឯអ្នកផ្សេងទៀតមួយចំនួន យើងខ្ញុំមិនស្គាល់ច្បាស់ទេ។ គ្រាន់ថាដឹងជា តាមរយៈធ្វើបាយ ហើយគឺមានគ្នាច្រើន។

**ស៖** នៅក្នុងម៉ោងឆ្លើយម៉ោង ១៤:៤៣:៣៦ លោកស្រីបានឆ្លើយនៅក្នុងពេលនោះថា “អ្នកមកទីក្រុងភ្នំពេញនេះគឺមកពីមូលដ្ឋាន បាននន័យថាអ្នកពីមូលដ្ឋានបានទៅ ក-១”។ តើជាញឹកញាប់ប៉ុនណាដែរ ដែលអ្នកមូលដ្ឋាននោះធ្វើដំណើរមកមន្ទីរក-១ នៅពេលដែលប្តីរបស់លោកស្រីហ្នឹងស្នាក់នៅទីនោះជាមួយនឹងមេដឹកនាំផ្សេងទៀត? តើពួកគេមកញឹកញាប់ប៉ុនណាដែរ?

**ឆ៖** យើងខ្ញុំមិនចាំច្បាស់ថាញឹកញាប់មិនញឹកញាប់ទេ ព្រោះអីតាមរយៈដែលធ្វើបាយ គឺពេលខ្លះគ្នាច្រើន ពេលខ្លះគ្នាតិច ហើយពេលខ្លះក៏តែ -- មានតែពួកគាត់ប៉ុន្មាននាក់។

**ស៖** តើលោកស្រីជាប្រធានផ្នែកដាំស្លនៅមន្ទីរក-១ ដែរឬទេ?

**ឆ៖** អត់ទេ។

[០៩:២១:៤៧]

**ស៖** តើនរណាគេជាប្រធាន?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក អាកទ្វូរ វែកគែន៖**

បាទ អម្បាញ់មិញនេះគឺថា ខ្ញុំអត់បានស្តាប់ឮសំណួររបស់សហព្រះរាជអាជ្ញាជាភាសាបារាំងទេ ស្តាប់តែឮចម្លើយរបស់លោកស្រីសាក្សី។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំសួរសំណួរអម្បាញ់មិញនោះ គឺថាតើគាត់គឺជាប្រធានដាំស្លនៅ ក-១ ដែរឬទេ? លោកស្រីបានឆ្លើយថា អត់ទេ គាត់មិនមែនជាប្រធាននោះទេ។ ដូច្នេះខ្ញុំសួរសំណួរបន្តទៀត ប្រសិនបើលោកស្រីមិនមែនជាប្រធានដាំស្លនៅមន្ទីរក-១ នោះទេ តើនរណាគេដែរជាប្រធាន?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ពេលនោះ គេអត់មានប្រាប់ថាអ្នកណាជាប្រធានទេ។

[០៩:២២:៥៣]

**ស៖** តើនរណាគេទទួលបន្ទុកផ្នែកដាំស្លនៅពេលដែលមេដឹកនាំមកពីមូលដ្ឋាន មកមន្ទីរក-១ នោះ?

**ឆ៖** គឺមានប្រពន្ធតា នួន ជា នៅកន្លែងនោះ។

**ស៖** តើលោកស្រីជាប្រធានផ្នែកដាំស្លនៅមន្ទីរក-៣ ដែរឬទេ?

**ឆ៖** ក៏អត់ដែរ។

**ស៖** នៅក្នុងឯកសារ E3/16 ត្រង់ជំពូកទី៥ នៃសៀវភៅដែលប្តីរបស់លោកស្រីជាអ្នកសរសេរនោះ ERN ជាភាសាអង់គ្លេសគឺ 00498280, បារាំងមានលេខ 00643886, ខ្មែរមានលេខ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក អាកទ្វូរ វែកគែន!

**លោក អាកទ្វូរ វែកគែន៖**

បាទ សូមអភ័យទោសលោកប្រធាន ដែលខ្ញុំកាត់អម្បាញ់មិញនេះ ប៉ុន្តែឯកសារដែលគាត់ប្រើអម្បាញ់មិញនេះគឺថាអត់ទាន់មានដាក់ជូនដល់ភាគីទៀតហើយ។

[០៩:២៤:៣៤]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោកតំណាងសហព្រះរាជអាជ្ញា អំពីការប្រើប្រាស់ឯកសារដេញដោលនៅក្នុង

ដំណើរការសវនាការនេះ? យើងបានជម្រាបជូនលោកហើយអំមិញ លោកទាមទារស្នើសុំពេលវេលាម្តងហើយម្តងទៀត ប៉ុន្តែសូមលោកកំណត់ឯកសារដែលត្រូវប្រើប្រាស់ឲ្យត្រឹមត្រូវតាមការណែនាំនីតិវិធីពិភាក្សាដេញដោលឯកសារនៅចំពោះមុខអង្គជំនុំជម្រះដែលយើងបានអនុវត្តជាង១ឆ្នាំកន្លងមកហើយ។

**លោក ឃីត វេយ៍ន័រ៖**

ឯកសារនេះនៅក្នុងបញ្ជី តាមវិធាន១៨រួចមកហើយ វិធាន៨០ ហើយឯកសារនេះគឺត្រូវបានដាក់រួចមកហើយ។ ហើយខ្ញុំប្រហែលជាមានសិទ្ធិក្នុងការសួរសំណួរដោយយោងនៅក្នុងសៀវភៅនេះ។ ខ្ញុំយោងតែមួយចំណុចតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

អង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើប្រាស់ឯកសារដូច្នេះ។ ព្រោះឯកសារនេះធ្លាប់ប្រើប្រាស់ក្នុងកិច្ចពិភាក្សាដេញដោលនៅក្នុងអំឡុងពេលពិភាក្សាដេញដោលសាក្សីដទៃទៀតកន្លងមកហើយ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ហើយខ្ញុំអម្បាញ់មិញនេះចាប់ផ្តើមបញ្ជាក់លេខខ្មែរ ERN ហើយគឺ 00380459/60 នេះគឺជាសៀវភៅដែលនិពន្ធដោយប្តីរបស់លោកស្រី លោកស្រី សូ សុជាតិ។ គាត់ជាអ្នកនិពន្ធសៀវភៅនេះ ខ្ញុំសូមដកស្រង់សម្តី "ប្រពន្ធរបស់ខ្ញុំទទួលបន្ទុកផ្នែកដាំស្ល"។ តើគាត់និយាយនេះពិតដែរឬទេ?

[០៩:២៦:៣១]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស ពិតមែន។

**ស៖** តើលោកស្រីអាចបញ្ជាក់ថា ពេលលោកស្រីឆ្លើយខាងដើមអម្បាញ់មិញនោះជាការយល់ច្រឡំដែរឬទេ ដែលលោកស្រីឆ្លើយថាលោកស្រីមិនមែនជាប្រធានខាងផ្នែកដាំស្លនោះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរដែលតាំងឡើងដោយតំណាងសហ

ព្រះរាជអាជ្ញាចំពោះសាក្សីពេលនេះ។ កាលពិតតំណាងសហព្រះរាជអាជ្ញាទេ ដែលជាអ្នកយល់ច្រឡំចំពោះចម្លើយរបស់សាក្សី។ សាក្សីគាត់បានបញ្ជាក់ស្របទៅតាមចម្លើយដែលមានសរសេរដែលតាមការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាថា លោកស្រីជាអ្នកទទួលបន្ទុកដាំស្ល។ ទទួលបន្ទុកដាំស្លវាខុសគ្នាពីប្រធានក្រុមដាំស្ល។ អ៊ីចឹងខ្ញុំមិនដឹងថា តើតំណាងសហព្រះរាជអាជ្ញាធ្វើការប្រើធៀបដូចម្ដេចចំពោះបញ្ហានេះ។ បាទ សូមអរគុណ។

[០៩:២៧:៥១]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន សំណួរដែលខ្ញុំសួរដំបូងនោះគឺថាតើលោកស្រីគាត់ជាប្រធានខាងផ្នែកដាំស្ល ឬចង្ក្រានបាយ ឬក៏យ៉ាងណា? គាត់ថាអត់ទេ គាត់មិនមែនជាប្រធាននោះឡើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៨:២៤]

**ប្រធានអង្គជំនុំ៖**

បាទសេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីលោក ខៀវ សំផន មិនត្រឹមត្រូវទេ។ គាត់ក្ដាប់បញ្ហាមិនបានទេ។ ដូច្នេះសេចក្ដីជំទាស់នេះគ្មានប្រសិទ្ធភាព។

សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំអម្បាញ់មិញនោះ គឺខ្ញុំសួរដូច្នេះថា តើលោកស្រីទទួលស្គាល់ថាលោកស្រីបានឆ្លើយមិនត្រឹមត្រូវដែរឬទេ នៅពេលដែលលោកស្រីថា លោកស្រីមិនមែនជាប្រធានខាងផ្នែកផ្ទះបាយនោះ?

**ឆ៖** គឺខ្ញុំមិនមែនជាប្រធាន។ ដូច្នេះមិនត្រឹមត្រូវ។

[០៩:២៩:៣០]

**ស៖** លោកស្រីបានឆ្លើយនៅក្នុងម៉ោង ១៤:៤៦:០៣ កាលពីថ្ងៃ១០ ខែមិថុនា ពេលដែលលោកស្រីផ្លាស់ប្ដូររស់នៅពីមន្ទីរក-១ ទៅមន្ទីរក-៣។ មេដឹកនាំភាគច្រើនទៅមន្ទីរ ក-៣ ដូចលោក ខៀវ សំផន ដែរក៏គាត់ទៅមន្ទីរ ក-៣ ផងដែរ។ គាត់បានចាកចេញពីមន្ទីរ ក-៣ នេះមុនខ្ញុំ គឺនៅចុងឆ្នាំ១៩៧៥

ឬក៏ដើមឆ្នាំ១៩៧៦។ ហេតុដូច្នេះចម្លើយដែលលោកស្រីឆ្លើយកាលពីថ្ងៃ១០ ខែមិថុនា ម៉ោង ១៤:៤៦:០៣ នេះតើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមទោសលោកប្រធាន ព្រះរាជអាជ្ញា -- ខ្ញុំអត់យល់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរម្តងទៀត។ យើងបានរំឭករួចហើយពីម្សិលមិញ សូមលោករៀបចំនូវសំណួរឲ្យបានងាយយល់ ដើម្បីឲ្យគោលដៅដែលត្រូវទទួលការឆ្លើយហ្នឹង គាត់យល់អំពីសំណួររបស់លោក ហើយនិងអាចឆ្លើយតបបាន។ បាទ ជៀសវាងរៀបចំនូវសំណួរដែលលំបាកធ្វើឲ្យគោលដៅនៃការដែលត្រូវឆ្លើយតបហ្នឹង គឺក្តាប់នូវសំណួរមិនបាន មិនអាចឆ្លើយតបទៅតាមបំណងនៃគោលបំណងនៃសំណួរដែលលោកសួរបានទេ។

[០៩:៣១:០១]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ តើប្តីរបស់លោកស្រីចេញពី ក-១ ទៅ ក-៣ នៅក្នុងចុងឆ្នាំ១៩៧៥ ឬក៏ដើមឆ្នាំ១៩៧៦ ដែរឬទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** តើលោកស្រីបានទៅតាមគាត់ក្រោយពី២ ឬ៣ខែ បន្ទាប់គាត់បានចាកចេញទៅដែរឬទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** តើត្រឹមត្រូវដែរឬទេ ថាលោកស្រី និងប្តីរបស់លោកស្រីបានស្នាក់នៅអស់រយៈពេល៤ ឬក៏៥ខែ នៅក-៣ មុនពេលដែលការរត់គេចខ្លួននៅពេលដែលមេដឹកនាំចាកចេញពីទីនោះទៅនោះ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ដូច្នេះហើយនៅឆ្នាំ១៩៧៦ នៅពេលដែលលោកស្រីនិយាយថា មេដឹកនាំបានចាកចេញពីកន្លែងនោះ?

**ប្រធានអង្គជំនុំ៖**

សូមសួរម្តងទៀត! បាទ សូមដាក់ ក-១ ឬក៏ ក-៣ ឲ្យច្បាស់ទៅ ហើយលោកប្រើពាក្យ "នោះ" ដូច្នេះ ទំនងជាសាក្សីស្តាប់មិនយល់។ អ៊ីចឹងមិនអាចឆ្លើយបានទេ។ អ៊ីចឹងហើយបានជាគាត់ឆ្ងល់ ហើយគាត់មិនឆ្លើយតបជាមួយនឹងលោកទេ។ ពាក្យ "នោះ" ព្រោះឥឡូវ ក-១, ក-៣១ ហ្នឹង មិនដឹងជាកន្លែង

ណាមួយដែលច្បាស់លាស់។

[០៩:៣៣:២១]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ តើមេដឹកនាំជាន់ខ្ពស់បានចាកចេញពី ក-៣ នៅឆ្នាំ១៩៧៦ ដែលទុកឲ្យលោកស្រី ហើយនិងប្ដីរបស់លោកស្រីនៅ ក-៣ ហ្នឹងក្រោយគេ អ៊ីចឹងមែនឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** មែន។

**ស៖** បន្ទាប់ពីមេដឹកនាំទាំងនោះចាកចេញ តើប្ដីរបស់លោកស្រីធ្លាប់ជជែកជាមួយលោកស្រីដែរឬទេ ថាមេដឹកនាំផ្សេងទៀតបានប្រជុំគ្នាលាក់កំបាំងពីគាត់ ក្រោយខ្នងគាត់? តើគាត់ធ្លាប់រអ៊ូរទាំប្រាប់លោកស្រីពីរឿងហ្នឹងទេ?

**ឆ៖** អត់មានទេ។

**ស៖** ខ្ញុំចង់ចូលទៅដល់ប្រធានបទថ្មី គឺជាប្រធានបទចុងក្រោយ ដោយសារតុលាការ ដោយសារខ្ញុំមានពេលខ្លីចុងក្រោយ។ លោកស្រី តើលោកនៅចាំឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន ដែរឬទេ?

**ឆ៖** ខ្ញុំចាំតែឈ្មោះ ឌឿន។ សឿ វ៉ាស៊ី អត់ស្គាល់។

**ស៖** តើលោកស្រីធ្លាប់បានទុកម្ហូបអាហារជូនគាត់ ឬក៏ឲ្យគាត់ទេ នៅក្នុងកាលនោះ ក្នុងឋានៈជាចុងភៅនោះ លោកស្រីចុងភៅនោះ?

[០៩:៣៥:១២]

**ឆ៖** ធ្លាប់ទុកជូនគាត់។

**ស៖** តើនៅមន្ទីរមួយណាដែលលោកស្រីបានរៀបចំម្ហូបអាហារលើតុទុកឲ្យ ឌឿន នោះ?

**ឆ៖** នៅ ក-៣។

**ស៖** តើលោកស្រីស្គាល់ឈ្មោះប្រពន្ធរបស់ ឌឿន ដែរឬទេ?

**ឆ៖** អត់ស្គាល់ទេ។

**ស៖** តើនៅឆ្នាំណាដែលលោកស្រីបានជួប ឌឿន ជាលើកដំបូងនោះ?

**ឆ៖** នៅ ក-៣, ៧៦ ប្រហែល -- ប៉ុន្តែខែឆ្នាំ ខែមិនដឹងទេ ថ្ងៃមិនដឹងទេ។

**ស៖** តើលោកស្រីធ្លាប់បានជួប ឌឿន ទេក្នុងឆ្នាំ ១៩៧៧?

**ឆ៖** យើងខ្ញុំមិនបានចំណាំចាំទេ។

**ស៖** តើលោកស្រីធ្លាប់ពិភាក្សាពីរឿង ឌឿន ជាមួយប្តីរបស់លោកស្រីទេ កាលណោះ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកស្រីបានទុកម្ហូបអាហារលើតុរបស់ ឌឿន ហ្នឹងប៉ុន្មានដងដែរ តាមលោកស្រីចាំ?

**ឆ៖** ច្រើនដងដែរ តែមិនដឹងថាប៉ុន្មានៗទេ ប៉ុន្តែច្រើនដង។

**ស៖** តើនៅពេលបាយលោកស្រីបានជួបប្តីរបស់លោកស្រី បានអង្គុយនៅតុពិសាបាយ ហើយបានជជែកគ្នាអ្វីជាមួយ ឌឿន ដែរឬទេ?

[០៩:៣៧:៥២]

**ឆ៖** មិនដែលឃើញជជែកអីនោះទេ គ្រាន់តែឃើញសើចលេង។

**ស៖** តើ ឌឿន ហើយនិងប្តីរបស់លោកស្រីក្នុងឋានៈជជែកជាមិត្តភក្តិហ្នឹងគ្នាធម្មតាដែរឬទេ?

**ឆ៖** ជជែកតែធម្មតា។

**ស៖** តើមានពេលណាមួយដែលលោកស្រីបានជជែកជាមួយប្តីលោកស្រីថា ឌឿន គឺមិនមកហូបបាយហ្នឹងទៀតទេ គឺលែងមកកន្លែងហ្នឹងទៀតហើយ។ តើធ្លាប់បានជជែកគ្នាពីរឿងហ្នឹងទេ?

**ឆ៖** ចាសអត់មានអ្នកណាប្រាប់ទេ។

**ស៖** នៅក្នុងឯកសារ D3/16 លោកស្រី ខ្ញុំបានផ្តល់ ERN រួចហើយ។ ប្តីរបស់លោកស្រីបានសរសេរនៅក្នុងសៀវភៅដូចខាងក្រោមនេះ។ ហើយខ្ញុំសូមដកស្រង់ពាក្យរបស់គាត់ "ប្រពន្ធរបស់ខ្ញុំកាន់ចង្ក្រានបាយ ហើយទុកម្ហូបនៅលើតុបាយជូនគាត់។ ជាញឹកញយណាស់មិនឃើញគាត់មិនឃើញគាត់មកហូបទៀតទេ។ យូរៗទៅយើងហាក់ដូចជាស៊ាំនឹងសភាពការណ៍នេះ"។ សូមចង់សេចក្តីដកស្រង់។ សំណួរ តើប្តីរបស់លោកស្រីនិយាយត្រូវដែរឬទេ ដែលថាលោកស្រីហើយនិងគាត់ ហើយស៊ាំទៅនឹងសភាពការណ៍នេះ ដែលថា ឌឿន មិនបានមកហូបបាយនៅមន្ទីរ"ក" នោះទៀតទេនោះ ក-៣ នោះទៀតទេនោះ?

[០៩:៤០:១៥]

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** អ៊ីចឹងលោកស្រីបានពិភាក្សាពីរឿង ឌឿន ជាមួយប្ដីរបស់លោកស្រីទេ? ហើយលោកស្រីបានពិភាក្សាថា ឌឿន នោះលែងនៅ ក-៣ ទៀតហើយ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រង់នេះខ្ញុំមិនច្បាស់--

**លោក គង់ សំអុន៖**

លោកប្រធានសុំ!

**ប្រធានអង្គជំនុំ៖**

បាទ កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវី!

[០៩:៤០:៥៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ ម៉្យាងយើងមើលច្បាស់ថាជាសំណួរនាំមុខ ហើយប្រធានបទនេះមិនបានពិភាក្សាដែលអ្នកស្រីមិនដែលបានឆ្លើយអំពីការពិភាក្សារវាងប្ដីអ្នកស្រី លោក ខៀវ សំផន អំពីការបាត់ខ្លួនរបស់ ឌឿន នោះទេ។ ដូច្នេះសូមលោកប្រធានជំទាស់ចំពោះសំណួរនេះ។ បាទ សូមអរគុណ។

**លោក ឃីត វេយ៉ន័រ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនមានចេតនានឹងរំខានទេ។ ហើយចំណុចទី៣ ដែលថាលើកបី មេធាវីការពារក្ដីជាតិរបស់លោក ខៀវ សំផន គាត់ឆ្លើយបំភ្លៃចម្លើយរបស់សាក្សី។ ហើយខ្ញុំនឹងមានសំណើទៅតុលាការនៅពេលចុងបញ្ចប់នេះ។ សំណួរចុងក្រោយដែលខ្ញុំសួរហ្នឹង គឺដូចខាងក្រោមនេះ។ តើមានពេលណាមួយដែលលោកស្រីមានការពិភាក្សាជាមួយ ខៀវ សំផន ដែលថា ឌឿន មិនមកហូបបាយទៀតទេ ហើយមិនមកទេ? ហើយគាត់ឆ្លើយថា “ទេ”។ បាទ អ៊ីចឹងគឺថាសាក្សីនិយាយបែបនេះ។ ដូច្នេះយើងមិនអាចទទួលយកបានទេ ដែលមេធាវីការពារក្ដីឆ្លើយបំភ្លៃពាក្យចម្លើយរបស់សាក្សីបែបនេះនោះ។

[០៩:៤២:៤២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីជាតិការពារជាតិការពារក្ដី

លោក ខៀវ សំផន មិនសមស្របទេ ហើយក៏មិនគប្បីធ្វើបែបនេះម្តងហើយម្តងទៀតដែរ។ ហើយសាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហមេធាវី -- ដោយតំណាងសហព្រះរាជអាជ្ញានៅសំណួរចុងក្រោយអម្បាញ់មិញនេះ។ សូមអញ្ជើញ!

**លោកស្រី សូ សុជាតិ៖**

**ឆ៖** សូមមេត្តាសួរម្តងទៀត។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ដូច្នេះលោកស្រីបាន ពិតជាបានពិភាក្សារឿង ឌឿន ជាមួយលោក ខៀវ សំផន ហើយលោកស្រីបានពិភាក្សាថា ឌឿន នោះមិននៅក-៣ ទៀតទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** តាមខ្ញុំដឹងគឺខ្ញុំមិនថាគាត់អត់នៅទេ ប៉ុន្តែខ្ញុំគ្រាន់តែថា "គាត់អត់មកហូបបាយទេអី?" អ៊ីចឹងមាន។ ហើយប្តីខ្ញុំថាចេះតែទុកទៅ។ ខ្ញុំក៏អត់ដឹងដែរ គេទៅធ្វើការ។ អ៊ីចឹងមាន១និយាយគ្នា។

[០៩:៤៤:១៨]

**ស៖** ដូច្នេះបន្ទាប់ពីប្តីរបស់លោកស្រីប្រាប់ថា ឲ្យទុកម្ហូបអាហារនៅទីនោះ តើលោកស្រីនៅតែបន្តទុកម្ហូបអាហារលើតុសម្រាប់ឲ្យ ឌឿន នោះតទៅទៀតទេ?

**ឆ៖** ទុកបន្ត។

**ស៖** ហេតុអ្វី?

**ឆ៖** ពេលខ្លះ គាត់អញ្ជើញមកអត់ យើងអត់ដឹង។ ដល់អ៊ីចឹងគឺត្រូវតែទុក ខ្លាចមកធ្វើមិនទាន់។

**ស៖** តើលោកស្រីបន្តរៀបចំម្ហូបអាហារឲ្យគាត់តទៅទៀតទេ បន្ទាប់ពីឆ្នាំ១៩៧៧ មកនោះ?

**ឆ៖** ក្រោយមកយូរពេកក៏ឈប់ ហើយក៏អត់មានអ្នកណាប្រាប់ថាយ៉ាងម៉េចទេ តែយូរពេកទៅក៏ឈប់។

**ស៖** តើលោកស្រីធ្លាប់ដឹងថា ឌឿន ហ្នឹងមានបញ្ហាអ្វីដែលឬទេ?

**ឆ៖** ចាស អត់ដឹងទេ។

[០៩:៤៦:០០]

**ស៖** បញ្ជីអ្នកទោសនៅ ស-២១ គឺ E3/347 សូមកែគឺ 343 -- 42 គឺ ឌឿន នោះត្រូវបានចាប់ខ្លួននៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ តើលោកស្រីធ្លាប់ដឹងដែរឬទេថា គេចាប់ខ្លួន ឌឿន នៅក្នុងពេលណាមួយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧នោះ?

**ឆ៖** ចាស នាងខ្ញុំអត់ដឹងទេ។

**ស៖** បើនិយាយពីក្នុងករណីលោក ប៉ុល ពត, នួន ជា និង អៀង សារី តើប្រពន្ធរបស់ពួកគាត់ប្រពន្ធអ្នកម្នាក់ដែលលោកស្រីជិតស្និទ្ធជាងគេ?

**ឆ៖** ប្រពន្ធតា នួន ជា នៅផ្ទះបាយជាមួយគ្នា។

**ស៖** បន្ទាប់ពីមេដឹកនាំចេញពីកន្លែង ក-៣ នៅក្នុងឆ្នាំ១៩៧៦នេះ តើលោកស្រីបានជួបប្រពន្ធលោក នួន ជា នេះញឹកញាប់ ឬក៏ច្រើនដងទៀតទេ?

**ឆ៖** ជួបម្តងៗ។

[០៩:៤៧:៤៧]

**ស៖** តើលោកស្រីបានជួបគាត់នៅកន្លែងណា?

**ឆ៖** នៅ ក-១ ម្តងៗ ហើយគាត់មក ក-៣ ម្តងៗ។

**ស៖** ក្រោយពីមេដឹកនាំជាន់ខ្ពស់បានចាកចេញពីទីនោះ តើអ្នកណាជាអ្នកចំណាយពេលជាមួយកូនរបស់លោកស្រី ក្រៅពីប្តីរបស់លោកស្រី និងលោកស្រី។ បានន័យថា អ្នកណាជាអ្នកមើលកូនរបស់លោកស្រីនោះ?

**ឆ៖** ចាស អត់មានទេ។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំពិនិត្យមើលពេលវេលា ខ្ញុំបានប្រើពេលដែលបានចែកជូន។ សូមជម្រាបជូនលោកប្រធានថា សំណើដែលខ្ញុំធ្វើ សំណើម្សិលមិញមិនទាន់មានការសម្រេចនោះទេ។ ឥឡូវនេះ តើខ្ញុំត្រូវស្នើបន្តទៅទៀត ឬក៏ទៅតាមគ្រោងដែលអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យមេធាវីនាំមុខរដ្ឋប្បវេណីបន្ត។ បាទ ហើយផ្អែកទៅលើសេចក្តីស្នើសុំទាក់ទងទៅនឹងវិធានការណ៍ចំពោះមេធាវីការពារក្តីជាតិរបស់លោក ខៀវ សំផន ផងដែរបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណចំពោះការលើកឡើងនេះ ហើយសំណើនេះចាំដោះស្រាយនៅបន្ទាប់ពីការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដោយភាគីដែលនៅសេសសល់ដទៃទៀត។

សូមអញ្ជើញលោក! អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ មេធាវីទទួលសិទ្ធិគឺលោកមេធាវី ហុង គឹមសួន ហើយលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងអាចបន្តសំណួរតទៅទៀត។

សូមអរគុណលោកប្រធាន។ សូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ហុង គឹមសួន៖**

បាទជាដំបូង ខ្ញុំសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រម ជាទីគោរព! សូមថ្វាយបង្គំព្រះសង្ឃជាទីគោរពសក្ការៈ និងអង្គសវនាការជាទីគោរព។ ខ្ញុំបាទឈ្មោះ ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:៥០:៤៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរអ្នកស្រី សូ សុជាតិ។ ខ្ញុំមានសំណួរខ្លះៗ ដើម្បីឲ្យអ្នកស្រីបំភ្លឺតទៅនេះ។ អស់រយៈពេល២ថ្ងៃមកហើយ ដែលអ្នកស្រីបានជម្រាបជូនអង្គសវនាការអំពីប្រវត្តិរឿងរ៉ាវរបស់អ្នកស្រីជាមួយនឹងស្វាមីរបស់អ្នកស្រី គឺលោក ខៀវ សំផន។ សំណួររបស់ខ្ញុំ (សូមទោស) ជាដំបូងខ្ញុំសូមរំឭកបន្តិចឡើងវិញថា ក្រោយពេលមានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ អ្នកស្រីរស់នៅក្នុងខេត្តព្រះវិហារ។ អ៊ីចឹងមែនទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស ពិតមែន។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីថាអ្នកស្រីបានចូលធ្វើជាពេទ្យភូមិ ហើយក្រោយមកបានចូលធ្វើបដិវត្តន៍ដោយមាន អ៊ំយឹម នាំចូល។ តើអ្នកស្រីអាចបញ្ជាក់បានទេថា ការចូលរួមតស៊ូក្នុងបដិវត្តន៍

ពេលនោះ មានន័យយ៉ាងម៉េច ឬគេអប់រំយ៉ាងម៉េចខ្លះដែរបាទ?

**ឆ៖** សូមអនុញ្ញាតលោកប្រធាន ខ្ញុំសូមជម្រាបដូចតទៅ។ គឺក្នុងរដ្ឋប្រហារហើយ ក្នុងរយៈឆ្នាំ ៧០ ប្រហែលជាពាក់កណ្ដាលឆ្នាំ៧០ ពេលនោះខ្ញុំនៅភូមិនៅឡើយទេ ដល់ពាក់កណ្ដាលឆ្នាំ៧០ គឺមានអ៊ំម្នាក់គឺឈ្មោះ យឹម គាត់ចំណាស់បន្តិចហើយ ខ្ញុំហៅតែអ៊ំៗ។ ហ្នឹងគាត់ក៏បានមកតាមភូមិ--

[០៩:៥២:៥៥]

**ស៖** បាទ សូមកាត់ប្រសាសន៍អ្នកស្រីបន្តិច។ រឿងទាំងអស់ហ្នឹងយើងដឹងហើយ គ្រាន់តែខ្ញុំចង់សួរអ្នកស្រីថា តើគេអប់រំឱ្យចូលបដិវត្តន៍ហ្នឹង អប់រំយ៉ាងម៉េចតែប៉ុណ្ណឹងទេ? ព្រោះដឹងថា អ៊ំយឹម ហ្នឹង គឺនាំអ្នកស្រីចូលក្នុងតំបន់រំដោះហ្នឹង បាទ។

**ឆ៖** គឺការអប់រំរៀនសូត្រពេលនោះ គឺមាននារីជាច្រើនមកចូលរួម ហើយគេអប់រំថា មានរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ។ ហើយក្នុងនោះ មានចក្រពត្តិចូលឈ្លានពាន រួមជាមួយ លន់ នល់ ហើយបន្ទាប់មកក៏គេអប់រំថា ដើម្បីដណ្ដើមឯករាជ្យមកវិញ លុះត្រាតែយើងទាំងអស់គ្នាចូលរួមធ្វើបដិវត្តន៍។ ហើយធ្វើបដិវត្តន៍ យើងខ្ញុំក៏មិនយល់ថាម៉េចដែរ ប៉ុន្តែគាត់ក៏បានពន្យល់ គឺថាធ្វើបដិវត្តន៍ លុះត្រាតែយើងលះបង់ដើម្បីមកចូលរួមតស៊ូ។ ដូច្នេះ អ្នកទាំងអស់គ្នាត្រូវគិតពីខ្លួនឯង ហើយតើយើងទាំងអស់គ្នាចូលរួមក្នុងការតស៊ូបានទេ។

[០៩:៥៤:៤៩]

**ស៖** បាទ សូមអរគុណអ្នកស្រី។ ខ្ញុំសូមកាត់ប្រសាសន៍បន្តិច ព្រោះការរៀបរាប់ហ្នឹងមានវែងឆ្ងាយ។ អ៊ីចឹងខ្ញុំមានពេលវេលាតិចណាស់។ ខ្ញុំសូមសួរបន្តទាក់ទងជាមួយនឹងពេលដែលអ្នកស្រីចូលធ្វើបដិវត្តន៍ហ្នឹង តើអ្នកស្រីបានតួនាទីជាអ្វីដែរ? ជាប្រធានកង ឬក៏ជាកូនក្រុម មេក្រុមអីជាដើម?

**ឆ៖** ចាសពេលនោះ ខ្ញុំអត់មានអ្នកណាចាត់តាំងអីទៀតទេ គ្រាន់តែចាត់តាំងជាពេទ្យភូមិ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមសួរសំណួរលោតទៅដល់នៅពេលដែលអ្នកស្រីបានចូលបដិវត្តន៍ហើយបានមកនៅស្ទឹងជីនិត អ្នកស្រីថា បានមកនៅដាំបាយជិតកន្លែងថ្នាក់ដឹកនាំ។ អ៊ីចឹងពេលហ្នឹងអ្នកស្រីនៅធ្វើជាពេទ្យដែរទេ?

**ឆ៖** ពេលនោះនៅធ្វើជាពេទ្យ ជួយដាំបាយផងធ្វើជាពេទ្យផង។

**ស៖** អ្នកស្រីអាចបញ្ជាក់បានទេ ធ្វើពេទ្យពេលហ្នឹងព្យាបាលឱ្យថ្នាក់ដឹកនាំ ឬក៏ឱ្យខាងសមាជិកសាមញ្ញបាទ?

**ឆ៖** ឲ្យសមាជិកសាមញ្ញនៅក្នុងកន្លែង។

**ស៖** ចុះការដាំបាយនៅពេលហ្នឹងដែលថានៅជិតថ្នាក់ដឹកនាំ តើអ្នកស្រីដាំបាយឲ្យពួកថ្នាក់ដឹកនាំដែរទេ?

[០៩:៥៦:៤០]

**ឆ៖** បានជួយដាំ ព្រោះមានអ្នកដាំនៅហ្នឹងស្រាប់ យើងខ្ញុំជួយដាំ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងតំបន់ដែលអ្នកស្រីរស់នៅ នៅជិតស្ទឹងជីនិតហ្នឹង តើពេលនោះគេដាក់ឈ្មោះលេខសម្ងាត់តំបន់ហ្នឹងជាឈ្មោះអីដែរបាទ?

**ឆ៖** ពេលនោះគេដាក់ជាមន្ទីរស្ទឹងជីនិត ខ្ញុំមិនដឹងថាលេខគេយ៉ាងម៉េចទេ ខ្ញុំដូចជាមិនបាន ចាប់អារម្មណ៍។

**ស៖** អ្នកស្រីអាចចាំបានទេ ថ្នាក់ដឹកនាំពេលនោះអ្នកស្រីនៅស្គាល់ថាមានអ្នកណាខ្លះ?

**ឆ៖** ពេលនោះមាន តាប៉ុល ពត, តានួន ជា, តាខៀវ សំផន បានក្រោយមកមានឃើញ តាសុន សេន និងប្រពន្ធ។

**ស៖** សូមអរគុណ។ អ្នកស្រីដែលបានរៀបការជាមួយស្វាមីអ្នកស្រីគឺលោក ខៀវ សំផន ពេលនោះអ្នកស្រីស្គាល់ឈ្មោះគាត់ថា ខៀវ សំផន អ៊ីចឹងហើយឬនៅ?

[០៩:៥៨:១៣]

**លោក គង់ សំអុន៖**

លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប។

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

ខ្ញុំសូមជំទាស់សំណួរនេះ ពីព្រោះវាជាសំណួរដដែលៗ អ្នកស្រីបានឆ្លើយបញ្ជាក់រួចហើយថា អ្នកស្រីអត់បានស្គាល់ថាលោក ខៀវ សំផន ហ្នឹងជាអ្នកណាទេ គាត់ស្គាល់ឈ្មោះ ហែម ដែលជាបុគ្គលដែលគាត់រៀបការជាមួយនោះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ សេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីលោក ខៀវ សំផន គឺសមស្រប។ ពីព្រោះសំណួរនេះពិតជាសំណួរច្រំដែល ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្តាប់មិនបានទេ ទើបតាំងសំណួរច្រំដែលរបៀបនេះនាំឱ្យខាតពេល។

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរច្រំដែលបែបនេះទេ។

[០៩:៥៩:០២]

**លោក ហុង គីមសួន៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំ សូមដូរសំណួរទៅសំណួរផ្សេងទៀត។ មុនពេលរំដោះទីក្រុងភ្នំពេញថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អ្នកស្រីបានជម្រាបអង្គសវនាការថា មកតាមស្វាមីនៅស្តុកតោល តើរយៈពេលប្រហែលជាប៉ុន្មានថ្ងៃ ទើបអ្នកស្រីបានចូលទីក្រុងភ្នំពេញ?

**ឆ៖** ចាស មិនមែនខ្ញុំមកតាមស្វាមីនៅស្តុកតោលទេ ខ្ញុំមកភ្នំពេញក្រោយរំដោះ១អាទិត្យ ខ្ញុំមកភ្នំពេញ មកជួបគាត់នៅស្តុកតោល១យប់។

**ស៖** សូមអរគុណ។ អ្នកស្រីចូលមកភ្នំពេញតាមផ្លូវណាដែរ?

**ឆ៖** យើងខ្ញុំអត់ស្គាល់ផ្លូវទេ ពេលនោះ។

**ស៖** សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេ ការធ្វើដំណើរពីស្តុកតោលចូលមកភ្នំពេញតាមមធ្យោបាយអ្វី? ហើយចូលមកដល់ទីក្រុងភ្នំពេញតាមរយៈនរណានាំមក?

**ឆ៖** គាត់ឈ្មោះ សែម ហើយជិះម៉ូតូតាមផ្លូវលំ រួចទៅតាមណា ខ្ញុំមិនសូវចាំទេ ប៉ុន្តែមានឈ្មោះ សែម ជាអ្នកនាំ ជិះម៉ូតូ។

**ស៖** សូមបន្តសំណួរទៅទៀត មកតាមផ្លូវអ្នកស្រីមានឃើញប្រជាពលរដ្ឋដែលជម្លៀសចេញពីទីក្រុងភ្នំពេញដើរ ឬក៏ជាហ្វូងមនុស្សតាមផ្លូវដែរទេ?

[១០:០១:០៦]

**ឆ៖** ចាស អត់មានឃើញទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបន្តសំណួរតទៅទៀត ដោយសារព័ត៌មានដែលអ្នកស្រីបានជម្រាបជូនអង្គសវនាការច្រើនហើយ ហើយបើសំណួរនោះវាសួរទៅវាអាចមានទាក់ទងនឹងសំណួរមុនចម្លើយមុនខ្លះ ខ្ញុំសួរទាក់ទងពី នៅពេលដែលអ្នកស្រីរស់នៅក្នុងទីក្រុងភ្នំពេញ មានន័យថាក្រោយពេលរំដោះថ្ងៃ

១៧ មេសា ១៩៧៥ ហើយ រហូតមកដល់អ្នកស្រីរស់នៅជាមួយនឹងស្វាមីអ្នកស្រីនៅមន្ទីរ ក-១ ឬ ក-៣ ជាដើម។ តើអ្នកស្រីអាចបញ្ជាក់បានទេថា បងប្អូនរបស់អ្នកស្រីដែលត្រូវបានជាប់ឃុំនៅខេត្តសៀមរាប ឈ្មោះ យៀត មែនទេ?

**ផ៖** ចាស បងជីដូនខ្ញុំឈ្មោះ យៀត។

**ស៖** បាទ សូមអរគុណ។ ពីម្សិលមិញគឺជាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ នេះអ្នកស្រីបានជម្រាបជូនអង្គសវនាការ ប៉ុន្តែខ្ញុំសូមឲ្យអ្នកបញ្ជាក់ឡើងវិញបន្តិចថា នៅពេលដែលឪពុក ឬក៏ម្ដាយអ្នកស្រីត្រូវបានបញ្ជូនមកតាខ្មៅ បើខ្ញុំមិនច្រឡំទេគឺថាអ្នកស្រីថា គាត់ជាប់ឃុំនៅតាខ្មៅ អ៊ីចឹងមែនទេ?

**ផ៖** ចាស មិនមែនទេ លោកច្រឡំហើយ គឺគេយកទៅសៀមរាប។ ឯតាខ្មៅគេលែងមក គេលែងអ្នកដែលគេចាប់ហ្នឹងមកតាខ្មៅ ដូចជា បងយៀត បងខ្ញុំ។

[១០:០៣:០២]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីបានជម្រាបជូនអង្គសវនាការថានៅពេលដែលទៅជួបបងស្រីនៅតាខ្មៅហ្នឹង គឺលួចទៅៗជិះឡានជាមួយអ្នកដឹកអីវ៉ាន់អីជាដើម។ អ៊ីចឹងពេលហ្នឹងអ្នកស្រីដែលលួចទៅហ្នឹងមិនមានកន្លែងកុងត្រូលដែលគេយាមតាមផ្លូវសួរសាកសួរដែរឬទេ?

**ផ៖** ចាស អត់មានផង។

**ស៖** អ្នកស្រីអាចបញ្ជាក់បានទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យការដើរហើរនៅទីក្រុងភ្នំពេញហ្នឹងមានចេញជាលិខិត ឬក៏គេហៅថាសំបុត្រអនុញ្ញាតធ្វើដំណើរដែរទេ?

**ផ៖** ចាស អត់ដឹងមានសំបុត្រ ឬអត់ ខ្ញុំអត់ដឹងដែរ។

**ស៖** អ្នកស្រីដែលធ្លាប់ឮសួរគេនិយាយអំពីស្វាមីអ្នកស្រីឈ្មោះ ខាង ដែរទេ?

**ផ៖** ចាស អត់ដែលឮផង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលទៅសំណួរទាក់ទងជាមួយនឹងការទទួលខុសត្រូវ ឬការដាំស្លនៅផ្ទះបាយអ្នកស្រីតែងតែជម្រាប។ អ្នកស្រីបានជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះស្ដីអំពីការដាំស្លឲ្យស្វាមីអ្នកស្រី តើពេលហ្នឹងការដាំស្លហ្នឹងសុទ្ធតែប្រពន្ធថ្នាក់ដឹកនាំដូចជាប្រពន្ធ នួន ជា, ប្រពន្ធ សុន សេន ជាដើម។ល។ ដាំស្លជាមួយអ្នកស្រីអ៊ីចឹងទេ?

**ផ៖** ចាស អត់មែនទេ។ ព្រោះតែប្រពន្ធ នួន ជា, តានួន ជា ហើយនិងមានក្មួយគាត់ ហើយនិងមានអ្នកពីរនាក់បីនាក់នៅជាមួយ។

[១០:០៥:២២]

**ស៖** បាទសូមអរគុណ។ ក្រៅពីការដាំស្លរ អ្នកស្រីមានដឹងថាការងារស្វាមីអ្នកស្រីហ្នឹងធ្វើអ្វីដែលជាកម្រិតក្នុងថ្នាក់ដឹកនាំដែរទេ?

**ឆ៖** ចាស អត់ដឹង។

**ស៖** ពេលស្វាមីអ្នកស្រីចេញទៅជួបប្រជុំជាមួយនឹងថ្នាក់ដឹកនាំ គាត់ដែលជម្រាបឲ្យអ្នកស្រីដឹងខ្លះដែរទេ?

**ឆ៖** គាត់គ្រាន់ប្រាប់។ ឧទាហរណ៍គាត់ទៅ ក-១ គាត់ប្រាប់ថាគាត់ទៅ ក-១ ទៅប្រជុំ ឬក៏ស្អីខ្ញុំអត់ៗមានប្រាប់។

**ស៖** តើអ្នកស្រីដែលឮស្វាមីអ្នកស្រីត្អូញត្អែរអំពីការបាត់ខ្លួនមនុស្ស ឬក៏ចាប់មនុស្សចេញពីអង្គភាពហ្នឹងដែរទេ?

**ឆ៖** អត់ដែលឮផង។

[១០:០៦:៤១]

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅក្នុង (សូមទោស) នៅក្នុងមន្ទីរដែលអ្នកស្រីរស់នៅមន្ទីរ ក-១ ឬមន្ទីរ ក-៣ ជាដើម។ ស្តីអំពីការលាក់ការណ៍ការសម្ងាត់។ តើមានន័យថាអ្នកណាធ្វើអ្វីជារឿងរបស់គេ គេមិនប្រាប់យើង យើងធ្វើអ្វីជារឿងរបស់យើង យើងមិនប្រាប់គេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** តើខ្ញុំនិយាយត្រូវទេថា ការងាររបស់ស្វាមីអ្នកស្រីជារឿងសម្ងាត់របស់គាត់ រឿង ប៉ុល ពត ជារឿងការងារសម្ងាត់របស់គេ គេមិនប្រាប់គ្នាទៅវិញទៅមកអ៊ីចឹងដែរទេ?

**ឆ៖** អាហ្នឹងខ្ញុំគ្រាន់តែដឹងគោលការណ៍ ឯខាងនេះយ៉ាងម៉េច ខ្ញុំអត់នេះទេ គ្រាន់តែដឹងជាគោលការណ៍អ៊ីចឹង។

[១០:០៧:៥៨]

**ស៖** បាទសូមអរគុណ។ សំណួរចុងក្រោយ ខ្ញុំសូមសួរអ្នកស្រីថា តើក្រោយការពេលរបបខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យដួលរលំក្រោយថ្ងៃ០៧ មករា ១៩៧៩ ទៅហ្នឹង។ តើអ្នកស្រីដែលធ្លាប់បានឮ ឬក៏បានដឹងអំពីវិនាសកម្មនៅក្នុងសម័យខ្មែរក្រហមកាន់កាប់ប្រទេស ដូចជាការស្លាប់ប្រជា

ពលរដ្ឋរាប់លាននាក់ដែរទេ?

**ឆ៖** កាលពីមុនរស់នៅក្នុងក-៣ ខ្ញុំមិនដែលឮមានអ្នកណានិយាយពីរឿងស្លាប់។ តែក្រោយមកទើបដឹង។

**ស៖** ការដឹងរបស់អ្នកស្រីនេះ អ្នកស្រីជឿថាមានវិនាសកម្មនៅក្នុងសម័យខ្មែរក្រហមស្លាប់មនុស្សអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំជឿ។

[១០:០៩:១៦]

**ស៖** តើអ្នកស្រីជឿថាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ថ្នាក់ដឹកនាំប្រទេសរបបកម្ពុជាប្រជាធិបតេយ្យដឹងថាមានវិនាសកម្ម។ អ្នកស្រីជឿអ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ពីព្រោះវាជាប្រភេទសំណួរដែលផ្តល់ឲ្យសាក្សីធ្វើការសន្និដ្ឋានថាជឿ ឬក៏មិនជឿពីអង្គហេតុណាមួយ។ វាមិនមែនជាសមត្ថភាពរបស់សាក្សីត្រូវមកបង្ហាញទេ។ ហើយជាក់ស្តែងសាក្សីនេះគាត់ជាអ្នកដាំបាយ អ៊ីចឹងទាល់បង្ហាញពីបញ្ហាអ្វីដែលផ្តល់សក្ខីទៅលើការសន្និដ្ឋានផ្សេងៗ វាអត់មានជាសមត្ថភាពរបស់គាត់ដែលអាចធ្វើបាទ។ សូមជំទាស់ សូមអរគុណ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទអស់សំណួរហើយ សូមឲ្យសហមេធាវីសមាជិករបស់ខ្ញុំបន្តទៀត។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១០:១០:៣៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ជាទីគោរព! ភាគីទាំងអស់ជាទីគោរព។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោកស្រី។ ខ្ញុំសូមចោទសំណួរមួយចំនួនតែប៉ុណ្ណោះ។ ខ្ញុំមានពេលវេលាខ្លី។ អ៊ីចឹងខ្ញុំសូមឱ្យលោកស្រីឆ្លើយឱ្យបានច្បាស់តាមដែលអាចធ្វើទៅបាន ហើយនិងឱ្យខ្លីតាមដែលអាចធ្វើទៅបាន។ ហើយខ្ញុំសួរសំណួរទៅលោកស្រី ក្នុងឋានៈលោកស្រីជាភរិយារបស់លោក ខៀវ សំផន ជាងក្នុងឋានៈលោកស្រីជាចុងចោទ។ លោកស្រីនៅថ្ងៃទី១០ មិថុនា លោកស្រីបាននិយាយថា "លោកស្រីបានរៀនដល់ថ្នាក់ទី៥" ប្រហែលជាម៉ោង ១១:៤០:២៥ តើយើងអាចសន្និដ្ឋានថាជាកម្រិតវប្បធម៌គួរសមដែរនៅសម័យនោះ ជាពិសេសនៅតាមជនបទនោះ។ យើងអាចសន្និដ្ឋាន សន្មតអ៊ីចឹងបានទេលោកស្រី?

[១០:១១:៤៥]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស។

**ស៖** ខ្ញុំសូមអរគុណ។ នៅថ្ងៃទី១ ថ្ងៃទី២ ហើយអម្បាញ់មិញនេះ លោកស្រីបាននិយាយទៅខាងសហភាតារបស់ខ្ញុំថា លោកស្រីបានចូលរួមនៅក្នុងការតស៊ូបដិវត្តន៍ ហើយលោកស្រីក៏បានផ្តល់ពីមូលហេតុផងដែរ ថាត្រូវតែតស៊ូប្រឆាំងនឹងពួកចក្រពត្តិ។ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ក្នុងការចូលធ្វើបដិវត្តន៍នេះ លោកស្រីចាប់អារម្មណ៍ហ្នឹងនយោបាយរបស់ប្រទេសរបស់លោកស្រី ហើយលោកស្រីចាប់អារម្មណ៍ខ្លាំងទៅខាងនយោបាយនេះ នៅសម័យបដិវត្តន៍នោះ?

**ឆ៖** សូមទោស គាត់ចង់សួរយ៉ាងម៉េចទេនេះ ស្តាប់មិនទាន់។ សូមទោសលោកប្រធាន។

[១០:១២:៥៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីតាំងសំណួរចុងក្រោយរបស់លោកស្រីចំពោះសាក្សីនេះ សាជាថ្មីម្តងទៀត។ ព្រោះសាក្សីស្តាប់សំណួររបស់លោកស្រីមិនបានទេ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំសូមសួរម្តងទៀត លោកស្រីបាននិយាយជាច្រើនដងនៅក្នុងសាលសវនាការអស់រយៈពេល២ថ្ងៃមកហើយ គឺថាលោកស្រីបានចូលរួមប្រឡូកក្នុងការតស៊ូបដិវត្តន៍ប្រឆាំងនឹងចក្រពត្តិ។ សំណួរខ្ញុំដូចតទៅនេះ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ស្ថានភាពរបស់ប្រទេសរបស់លោកស្រីធ្វើឱ្យលោកស្រីព្រួយបារម្ភ ហើយអាស្រ័យហេតុដូច្នេះហើយ បានជាអ្នកស្រីចូលប្រឡូកក្នុងការតស៊ូ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស មែន។

[១០:១៥:១០]

**ស៖** សូមអរគុណ។ នៅថ្ងៃទី១០ មិថុនា ម៉ោង ១៥:២០:២៣ លោកបាន លោកស្រីបានពន្យល់អំពីលក្ខខណ្ឌស្នាក់នៅស្វាមីរបស់លោកស្រីនៅមន្ទីរ ក-៣ ហើយលោកស្រីបានយំបន្តិចបន្តួចផងដែរ។ លោកស្រីបាននិយាយថា "លក្ខខណ្ឌនោះ គឺថាផ្ទះទ្រុឌទ្រោម ហើយមនុស្សនៅកន្លែងនោះ មិនសមគួរទេ"។ តើនៅសម័យនោះ លោកស្រីធ្លាប់បានឮអំពីលក្ខខណ្ឌជីវភាពលំនៅដ្ឋាន ចំណីអាហារ ឬក៏របស់អ្នកដែលគេជម្លៀសចេញពីទីក្រុងភ្នំពេញទៅតាមជនបទដែរឬទេ?

**ឆ៖** ចាស ពេលនោះខ្ញុំអត់ដឹង។

**ស៖** លោកស្រី តើលោកស្រីធ្លាប់បានស្ដាប់ ឬក៏អានអ្វីដែលគេលើកឡើងនៅថ្ងៃទី២៧ ឧសភា គឺថាដើមបណ្ដឹងរដ្ឋប្បវេណីបានមកនិយាយនៅថ្ងៃនោះ អំពីជីវភាពរបស់គាត់នៅក្នុងសហករណ៍។ លោកស្រីបានស្ដាប់ ឬក៏អានទេ?

**ឆ៖** យើងខ្ញុំអត់បានមកតាមដាននូវសវនាការនោះទេ។

**ស៖** តើលោកស្រីចាប់អារម្មណ៍ទេ ចង់ឲ្យគេនិយាយប្រាប់លោកស្រីអំពីអ្វីដែលកើតឡើងនៅសម័យខ្មែរក្រហមដែរឬទេ?

**ឆ៖** ក្រោយមកយើងខ្ញុំដឹងហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ ដោយសារសាក្សីឆ្លើយរួចហើយ យើងខ្ញុំអត់ -- សូមលះបង់ការតវ៉ានេះវិញ។ សូមអរគុណ។

[១០:១៦:៥៦]

**ប្រធានអង្គជំនុំ៖**

បន្តទៅទៀត!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំអំបាញ់មិញនោះ ដូចថាជាមិនទាន់បានឆ្លើយទេ ប៉ុន្តែមិនសំខាន់អ្វីទេ។ ឥឡូវទាក់ទងនឹងសុន្ទរកថារបស់ស្វាមីរបស់លោកស្រីហ្នឹង លោកស្រីថាលោកស្រីមិនបានស្តាប់សុន្ទរកថាគាត់កាលពីខែមេសា ទេ តើលោកស្រី បើអ៊ីចឹងសួរថាតើលោកស្រីធ្លាប់បានស្តាប់សុន្ទរកថាផ្សេងទៀតទេ ឧទាហរណ៍ដូចជាសុន្ទរកថានៅប្រារព្ធបុណ្យខួបពេលរំដោះបានទីក្រុងភ្នំពេញនោះ ឬក៏សុន្ទរកថាដែលគាត់អាននៅពេលក្នុងឱកាសផ្សេងទៀត?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** នាងខ្ញុំមិនដែលបានស្តាប់នូវសុន្ទរកថាទេ ពីព្រោះរវល់។

**ស៖** លោកស្រីកាលសម័យខ្មែរក្រហមនោះ តើលោកស្រីធ្លាប់ស្តាប់វ៉ាដ្យូទេ?

**ឆ៖** នៅកន្លែងខ្ញុំអត់មានវ៉ាដ្យូផង។

[១០:១៨:៥២]

**ស៖** តើដែលមានកិច្ចប្រជុំណាដែលនៅក្នុងកិច្ចប្រជុំហ្នឹងលោកស្រីត្រូវស្តាប់សុន្ទរកថាមួយចំនួន ឬក៏មានមីក្រូដែលគេផ្សព្វផ្សាយព័ត៌មានទៅឲ្យមនុស្សគ្រប់ៗគ្នា ព័ត៌មានដូចគ្នាសម្រាប់មនុស្សគ្រប់ៗគ្នាដែរឬទេ?

**ឆ៖** កន្លែងខ្ញុំអត់មានមីក្រូទេ។

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់ថាអ្នកស្រីមិនធ្លាប់បានទៅចូលរួមប្រជុំ ដែលគេផ្សព្វផ្សាយដែលគេចាក់សុន្ទរកថាឲ្យស្តាប់ទេ ខ្ញុំត្រូវយល់អ៊ីចឹងឬក៏យ៉ាងម៉េចលោកស្រី?

**ឆ៖** សូមទោស យល់យ៉ាងម៉េច ខ្ញុំស្តាប់អត់បានកន្លែងហ្នឹង។

**ស៖** ខ្ញុំសួរថាតើលោកស្រីចន្លោះឆ្នាំ៧៥ និង៧៩នេះ យើងធ្លាប់បានស្តាប់មនុស្សច្រើនហើយនៅក្នុងសាលសវនាការនេះ គេទៅចូលប្រជុំ ហើយនៅក្នុងកិច្ចប្រជុំនោះមានគេចាក់សុន្ទរកថារបស់ថ្នាក់អ្នកដឹកនាំជាន់ខ្ពស់ ដូចជាស្វាមីរបស់លោកស្រី ឬក៏អ្នកដឹកនាំផ្សេងទៀត។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថាលោកស្រីធ្លាប់ចូលរួមកិច្ចប្រជុំបែបនេះទេ?

**ឆ៖** ចាស អត់ដែលចូល។

**ស៖** សូមអរគុណ។ មុនពេលដែលលោកស្រីមកផ្តល់សក្ខីកម្មហ្នឹង មានសាក្សីផ្សេងទៀតកាលហ្នឹងមានថាមានមនុស្សពីរនាក់ដែលរស់នៅមន្ទីរ ក-៣ នេះ តើលោកស្រីធ្លាប់សង្កេតឃើញថាមាន

ក្រុមកុមារមួយក្រុមមាន១២ ទៅ១៣នាក់។ ហើយលោកស្រីនៅទីនោះធ្វើម្ហូបអាហារហ្នឹងឲ្យកុមារទាំងអស់ហ្នឹង?

[១០:២១:៣៩]

**ផ៖** ចាស អត់មានផង។

**ស៖** អ្នកស្រី ម្សិលមិញគេបានបង្ហាញរូបថតទៅអ្នកស្រី តើជាលើកទីមួយហើយដែលលោកស្រីឃើញរូបថតស្វាមីរបស់លោកស្រីហ្នឹងក្នុងឱកាសកម្មវិធីជប់លាង តើហ្នឹងជាលើកទី១ ឬក៏យ៉ាងម៉េច?

**ផ៖** ចាស ខ្ញុំឃើញជាលើកទី១។

**ស៖** អ៊ីចឹងតើលោកស្រីធ្លាប់ឃើញរូបថតផ្សេងទៀតរបស់ស្វាមីរបស់លោកស្រីទេ កាលពីសម័យខ្មែរក្រហមហ្នឹង?

**ផ៖** ចាស អត់មានទេ។

**ស៖** លោកស្រី កាលពីម្សិលមិញលោកស្រីបាននិយាយទៅកាន់ចៅក្រម ឡាវែន៍ ដែលចោទសំណួរទៅកាន់លោកស្រី សំណួរមួយនៅម៉ោង០៩:៤៦:៥៦ ជាភាសាបារាំង លោកស្រីបានឆ្លើយយ៉ាងដូច្នេះ "នៅសម័យនោះមុខងាររបស់គាត់មិនសំខាន់ទេ គាត់មិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ទេបាទ"។ ខ្ញុំសូមបញ្ជាក់ថា សំណួរនោះទាក់ទងទៅនឹងរយៈកាលមុនឆ្នាំ៧៥។ សំណួរខ្ញុំឥឡូវនេះ ដូចតទៅនេះ បើមុនឆ្នាំ៧៥ ប្ដីរបស់លោកស្រីមិនមែនជាមេដឹកនាំជាន់ខ្ពស់ តើអ៊ីចឹងតើក្រោយឆ្នាំ៧៥ហ្នឹង គាត់ជាមេដឹកនាំជាន់ខ្ពស់ដែរឬទេ?

**ផ៖** កាន់តែមិនមែន។

[១០:២៤:០០]

**ស៖** អ៊ីចឹងក្រោយឆ្នាំ៧៥ហ្នឹង គាត់ធ្វើអីដែរ?

**ផ៖** ខ្ញុំមិនដឹងច្បាស់គាត់ធ្វើអីទេ ប៉ុន្តែឃើញគាត់នៅនឹងកន្លែង ហើយម្ដងម្កាលទៅ ក-១ ហើយម្ដងម្កាលទៅជួបសម្ដេច។ ហ្នឹងដែលខ្ញុំឃើញជាក់ស្ដែង។

**ស៖** ខ្ញុំសូមអរគុណ។ ខ្ញុំសួរជិតចប់ហើយ។ លោកស្រី តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា២ថ្ងៃមកហើយ ថាលោកស្រីបាននិយាយថា ចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ លោកស្រីមិនបានដឹងអ្វីទាំងអស់អំពីរបបខ្មែរក្រហម ហើយលោកស្រីកាលសម័យនោះ គ្រាន់តែជាចុងភៅតែប៉ុណ្ណោះ?

**ឆ៖** ចាស ពិតមែន។

**ស៖** តើខ្ញុំយល់ត្រូវដែរឬទេ គឺថា២ថ្ងៃកន្លងមកហើយ អ្នកស្រីបាននិយាយថា ទាំងនៅក្រោយរបបខ្មែរក្រហមក៏ដោយ ហើយក្រោយឆ្នាំ៧៩ មកដល់ឥឡូវនេះ ៣០ឆ្នាំផ្លាយហើយក៏ដោយ គឺថាក្នុងពេលឥឡូវនេះក៏ដោយ គឺថាពេលដែលប្ដីរបស់លោកស្រីនៅក្នុងសាលសវនាការនេះ។ លោកស្រីនៅតែមិនដឹងថាប្ដីរបស់លោកស្រីហ្នឹង មានមុខងារអ្វីដែរ តើខ្ញុំត្រូវយល់អ៊ីចឹង ឬក៏យ៉ាងម៉េច?

[១០:២៦:១៣]

**ឆ៖** អាហ្នឹងលោកស្រីយល់យ៉ាងម៉េច អាហ្នឹងរឿងរបស់លោកស្រី។ ព្រោះខ្ញុំមកនេះ មិនមែនជាការដឹងថា អ្នកណាយល់យ៉ាងម៉េចៗទេ លោកស្រីជាអ្នកតាមដាន ជាអ្នក -- លោកស្រីយល់យ៉ាងម៉េច អាហ្នឹងគឺជារបស់លោកស្រី។

**ស៖** ខ្ញុំមិនសួរអ្នកស្រីថា ចង់ដឹងថាអ្នកស្រីដឹងរបៀបណា ឬក៏យ៉ាងណាៗនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើពិតត្រឹមត្រូវដែរឬទេ ដែលថាលោកស្រីតាំងពីសម័យខ្មែរក្រហមរហូតមកដល់ពេលនេះ លោកស្រីនៅតែមិនដឹងថាប្ដីរបស់លោកហ្នឹងកាន់កាប់មុខងារអ្វី? ខ្ញុំសួរតែប៉ុណ្ណឹងទេ លោកស្រី។

**ឆ៖** ខ្ញុំមិនយល់ ពីព្រោះជាហូរហែមក ខ្ញុំមិនស្មានប្ដីខ្ញុំជាអ្នកធំ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំបានដឹងថាលោកស្រីបានយល់សំណួរខ្ញុំច្បាស់ហើយអម្បាញ់មិញនេះ ហើយអ៊ីចឹងខ្ញុំគាំទ្រសហព្រះរាជអាជ្ញាដូចម្សិលមិញអ៊ីចឹង។ អ៊ីចឹងគឺថាខ្ញុំ ដោយគួរសមហ្នឹង គឺថាខ្ញុំចង់និយាយថា លោកស្រីមិននិយាយការពិតជូនតុលាការទេ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរខ្ញុំត្រឹមហ្នឹង។

[១០:២៨:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកស្រី សូ សុជាតិ។ ការស្ដាប់សក្ខីកម្មរបស់លោកស្រីរហូតមកដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកស្រីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លែងមានភាពចាំបាច់ទៀតហើយ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រីដែលបានលះបង់ពេលវេលាដែលមានតម្លៃ មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេលជាង១ថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។

សក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្ដីនេះ។ ហើយសូមជូនពរលោកស្រី សូ សុជាតិ ឲ្យមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន ហើយវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

**លោកស្រី សូ សុជាតិ៖**

--

[១០:២៩:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់លើកឡើងថាមិនជាការសមរម្យទេ គឺថាកាលពីម្សិលមិញគាត់ប្រើច្បាប់ខំមិនឡ ហើយកាលនោះសាក្សីគាត់បានឆ្លើយដោយហួសពេលទៅហើយ។ ហើយឥឡូវនេះសួរសំណួរចប់ហើយ មេធាវីគាត់ឆ្លៀតឱកាសធ្វើការអត្ថាធិប្បាយលើសាក្សី ហើយខ្លួនឯងនេះនិយាយថា សាក្សីនេះគឺជាសាក្សីដែលសំខាន់ណាស់ក្នុងចំណោមសាក្សីទាំង៥នាក់នោះ។ អ៊ីចឹងការធ្វើអត្ថាធិប្បាយនេះវាមិនត្រឹមត្រូវទាល់តែសោះ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ក្រោកឈរឡើងនោះដើម្បីចង់និយាយថាមិនសមគួរទេ ក្នុងការធ្វើការអត្ថាធិប្បាយបែបនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវីដែលបានធ្វើការកត់សម្គាល់នេះ។ ហើយជាការកត់សម្គាល់ដ៏សមស្របមួយដែលអង្គជំនុំជម្រះបានព្រមាន និងបានជម្រាបជូនភាគីពាក់ព័ន្ធនៃរឿងក្ដីរួចមកហើយ។ ប៉ុន្តែដោយសារសវនាការនេះជាង១ឆ្នាំ ដូច្នេះបញ្ហានេះគឺហាក់ដូចជានៅតែមានដដែល ពិសេសមេធាវីអន្តរ-ជាតិ ការពារក្ដីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែម្ដង ចេះតែលើកឡើងនូវបញ្ហាចុងក្រោយដែលបង្កើតឲ្យមានកំហុសដូច្នេះ។ យើងសង្ឃឹមថាគាត់ជាមេធាវីអន្តរជាតិមិនគប្បីមានបញ្ហាដូច្នេះទេ។

លោកស្រី សូ សុជាតិ ចង់មានបញ្ហាអីទៅ សូមអញ្ជើញ!

[១០:៣១:៤០]

**លោកស្រី សូ សុជាតិ៖**

ជាចុងក្រោយនេះ ខ្ញុំសូមគោរពលោកប្រធាន។ ខ្ញុំចង់ជម្រាបអស់លោកចៅក្រម ព្រះរាជអាជ្ញា

ដែលលោកទាំងអស់បានសួរខ្ញុំ ហើយខ្ញុំក៏សូមអរគុណ។ តែថ្ងៃនេះមុននឹងបញ្ចប់ ខ្ញុំសូមរំឭកថាទោះបីជាចៅក្រម លោកចៅក្រម លោកព្រះរាជអាជ្ញា លោកតុលាការមានការចោទមកលើប្ដីខ្ញុំត្រូវចាប់ ត្រូវកាត់ទោសយ៉ាងណាក៏ដោយ តែខ្ញុំជាប្រពន្ធគឺនៅតែជឿទុកចិត្តលើប្ដីខ្ញុំជាមនុស្សល្អត្រឹមត្រូវ ពីព្រោះរស់នៅក្នុងរយៈជាង៣០ឆ្នាំមកនេះ ខ្ញុំស្គាល់ប្ដីខ្ញុំ ស្គាល់អត្តចរិត ស្គាល់ឫកពា គឺមិនមែនជាមនុស្សស្វែងរកលាភសក្ការៈ ស្វែងរកមុខមាត់បុណ្យស័ក្តិ ស្វែងរកអំណាចអាជ្ញានោះទេ។ ក៏មិនមែនជាមនុស្សកាចសាហាវឃោរឃៅដើរចាប់ចងកាប់សម្លាប់នោះដែរ។ ដូច្នេះទោះបីមានការចោទប្រកាន់យ៉ាងណាក៏នៅតែជឿទុកចិត្ត--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:៣៣:៤១]

**លោក ឃីត វេយ៍ន័រ៖**

សូមអភ័យទោសលោកប្រធាន នេះជាភស្តុតាងនិយាយអំពីអត្តចរិត ហើយខ្ញុំមិនអាចនឹងសួរដេញដោលគាត់ទេ។ ដូច្នេះខ្ញុំជម្រាបថា សេចក្ដីថ្លែងការណ៍របស់លោកស្រីនោះមិនសមស្របទេ។ តុលាការមិនគប្បីអនុញ្ញាត ហើយលោកស្រីមិនអាចធ្វើដូចដើមបណ្ដឹងរដ្ឋប្បវេណីទេ។ ដូច្នេះគឺថា តុលាការមិនគប្បីអនុញ្ញាតទេ ហើយវិធានផ្ទៃក្នុងក៏មិនអនុញ្ញាតដែរ។ ដូច្នេះសូមតុលាការពិចារណាសម្រេច។

**ប្រធានអង្គជំនុំ៖**

អរគុណអញ្ជើញ តំណាងសហព្រះរាជអាជ្ញាជាតិ!

**កញ្ញា សុង ឆវ័ន្ត៖**

អរគុណលោកប្រធាន ខ្ញុំឡើងមកគាំទ្រសហព្រះរាជអាជ្ញាអន្តរជាតិ ហើយសូមបញ្ជាក់ថា សាក្សីនេះជាសាក្សីអត្តចរិត គាត់ត្រូវបានសួរចប់ហើយ។ អ៊ីចឹងអ្វីដែលគាត់ថ្លែងនៅចុងក្រោយនេះ គាត់មិនមានសិទ្ធិទេ ហើយប្រសិនបើអ្វីដែលគាត់បានថ្លែងប្រសិនបើមានការអនុញ្ញាត យើងខ្ញុំស្នើសុំឲ្យមានការសួរដេញដោលម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីប្រឹក្សាសាក្សីមានបញ្ហាអីទៅ?

[១០:៣៤:៥០]

**លោក ម៉ម រិទ្ធា៖**

បាទ ជាបឋមខ្ញុំមេធាវី ម៉ម រិទ្ធា សូមគោរពលោកប្រធាន ហើយសូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ អម្បាញ់មិញសាក្សីគាត់ចង់ជម្រាបនូវអ្វីដែលគាត់បានមកបំភ្លឺនៅតុលាការ។ ប៉ុន្តែគាត់ហាក់ដូចជាមានការមិនសប្បាយចិត្តនៅពេលដែលភាគីគាត់បានលើកជាសំណួរ ហើយចោទប្រកាន់គាត់ថា គាត់មកឆ្លើយនេះនិយាយកុហកតុលាការ ដោយពាក្យមិនពិត។ ទាំងអស់នេះគាត់ចង់ថ្លែងបញ្ជាក់ ប៉ុន្តែអម្បាញ់មិញគាត់បានលើករឿងវែងឆ្ងាយបន្តិច ដើម្បីមុននឹងចូលទៅប្រធានបទដែលគាត់ចង់លើកឡើង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសូមជម្រាបជូនលោកមេធាវីប្រឹក្សាសាក្សីថា លោកមេធាវីមានសិទ្ធិត្រឹមតែប្រឹក្សាជាមួយនឹងសាក្សីអំពីសំណួរទាំងឡាយដែលទំនងជាដាក់ពិរុទ្ធភាពទៅលើ -- ឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងប៉ុណ្ណឹង និងការងារបន្ទាប់បន្សំផ្សេងទៀត។ អង្គជំនុំជម្រះផ្តល់ភារៈជូនឲ្យដើម្បីសម្រួលដល់ការប្រព្រឹត្តិទៅបានសមរម្យប៉ុណ្ណោះ មិនមានអាច មិនមែនលោកមេធាវីការពារ -- មេធាវីការពារសាក្សីទេ មេធាវីប្រឹក្សាសាក្សី សូមយល់អំពីតួនាទីនេះឲ្យបានច្បាស់លាស់។ យើងឃើញថាលោកចូលរួមនៅក្នុងកិច្ចដំណើរការនេះច្រើនលើកច្រើនសាហើយ ប្រហែលជាទំនងលោកមិនយល់អំពីភារកិច្ចរបស់លោកក្នុងនាមជាមេធាវីប្រឹក្សាសាក្សី។

យើងតែងតែបញ្ជាក់អំពីថាការប្រឹក្សានេះ គឺពេលណាដែលជួបប្រទះនឹងសំណួរដែលទំនងជានឹងមានភាពដាក់ចម្លើយ ឬការផ្តល់នូវអត្ថាធិប្បាយដែលអាចដាក់ពិរុទ្ធភាពលើខ្លួនឯង សូមពិភាក្សា ហើយនិងអាចប្រើសិទ្ធិថាឆ្លើយតប ឬមិនឆ្លើយតប។

[១០:៣៦:៤២]

បាទ អរគុណណាស់ ដោយសារមានបញ្ហាជម្រោងចម្រាសដូច្នេះ ហើយយើងសម្រេចថាមិនអនុញ្ញាតឲ្យលោកស្រីធ្វើអត្ថាធិប្បាយបន្តទៀតទេ ហើយទោះបីយ៉ាងណាក៏ដោយលោកស្រី សូ សុជាតិ អង្គជំនុំជម្រះអរគុណលោកស្រី ហើយនិងការផ្តល់សក្ខីកម្មរបស់លោកស្រីដ៏មានតម្លៃ ហើយបញ្ហានៃការវាយតម្លៃទៅលើភស្តុតាង ទម្ងន់ និងតម្លៃនៃភស្តុតាងជាភារកិច្ចរបស់ចៅក្រមនៃអង្គជំនុំជម្រះ ដែលជាចៅក្រមមានវិជ្ជាជីវៈខាងអាជីពជាចៅក្រមនឹងយកពាក្យពេចន៍ទាំងឡាយ សក្ខីកម្មរបស់លោកស្រី

ទៅពិនិត្យពិចារណាទៅតាមស្ថានភាពជាក់ស្តែងនៃមតិយោបល់របស់ចៅក្រម។ ហើយទោះបីយ៉ាងណាក៏ដោយគឺអង្គជំនុំជម្រះអរគុណដល់លោកស្រីចំពោះសក្ខីកម្មដែលលោកស្រីខិតខំប្រឹងប្រែងផ្តល់ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មនៅទីនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការបញ្ជូនលោកស្រី សូ សុជាតិ ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។ ហើយលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សីអាចសម្រាកបានហើយនាពេលនេះ។ ហើយអាចអាចចេញបានហើយ ចេញពីបន្ទប់សវនាការនេះបានហើយ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

**លោក ម៉ម រិទ្ធា៖**

សាក្សីក្រោយ ខ្ញុំបាទជាមេធាវីប្រឹក្សាដែរ។ អ៊ីចឹងខ្ញុំគួរចេញទៅ ឬក៏--

**ប្រធានអង្គជំនុំ៖**

ខ្ញុំជម្រាបលោកអំមិញឲ្យសម្រាកៗសិន ពីព្រោះអង្គជំនុំជម្រះបន្តិចទៀតត្រូវសម្រាក ប៉ុន្តែឥឡូវនេះអង្គជំនុំជម្រះត្រូវពិភាក្សាលើបញ្ហាសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះណា។

សម្រាកសិនចុះ!

[១០:៣៨:២៩]

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីលើកឡើងអំពីបង្ហាញអំពីសំណើសុំរបស់លោកឲ្យបានច្បាស់លាស់លើចំពោះអាកប្បកិរិយា ឬក៏វិធីសាស្ត្រក្នុងការការពារក្តីរបស់មេធាវីជាតិការពារក្តីលោក ខៀវ សំផន នៅក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី សូ សុជាតិ កន្លងមកនេះ។ តើមានបញ្ហាយ៉ាងម៉េចខ្លះ? ហើយមានមូលហេតុអី សូមបញ្ជាក់ឲ្យបានច្បាស់លាស់? ហើយមេធាវីជាតិការពារក្តីលោក ខៀវ សំផន សូមត្រៀមខ្លួនស្តាប់ ហើយមានឱកាសក្នុងការឆ្លើយតបទៅនឹងការទាមទាររបស់តំណាងសហព្រះរាជអាជ្ញា។

**លោក ឃីត សេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ សំណើជាក់លាក់របស់ខ្ញុំគឺដូចខាងក្រោមនេះ។ ខ្ញុំសូមដាក់សំណើថាតុលាការគប្បីដាក់វិន័យមេធាវីការពារក្តីជាតិរបស់លោក ខៀវ សំផន ចំពោះការប្រព្រឹត្តរបស់គាត់នៅក្នុងការធ្វើសក្ខីកម្មរបស់លោកស្រី សូ សុជាតិ។ សំណួររបស់ -- សំណើរបស់ខ្ញុំធ្វើឡើងតាមវិធាន

៣៥នៃវិធានផ្ទៃក្នុង។

សូមស្នើតុលាការថា សូមឱ្យបញ្ជាក់ថា គាត់បានធ្វើដោយចេតនា ដោយដឹងខ្លួនក្នុងការរំខានការប្រព្រឹត្តទៅនៃរដ្ឋបាលតុលាការ។ ហើយគាត់បានមានប៉ុនប៉ងក្នុងការរំខានក្នុងការបង្ហាញភស្តុតាងរបស់លោកស្រី សូ សុជាតិ។

[១០:៤០:១៤]

ខ្ញុំសូមស្នើដល់តុលាការថា ទី១) គប្បីតុលាការបដិសេធចំពោះការជំទាស់រំខានរបស់គាត់ ឬក៏ដាក់ទណ្ឌកម្មទៅលើគាត់ ហើយនិងកត់ត្រានៅក្នុងកំណត់ត្រារបស់តុលាការពីអាកប្បកិរិយានេះ។

សំណើទី២ គឺកាយវិការរបស់គាត់គប្បីបញ្ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដោយអង្គជំនុំជម្រះនេះ។ សំណើរទី៣ របស់ខ្ញុំសុំតុលាការផ្តល់ការព្រមានជាផ្លូវការដោយតុលាការនេះ នៅក្នុងពាក្យសាមញ្ញរបស់តុលាការ អំពីបញ្ជាក់ថាការបញ្ជាក់រំខានដដែលៗ និងត្រូវដកគាត់ចេញពីដំណើរការនីតិវិធីនេះ។

ហើយខ្ញុំសូមគោរពថា តុលាការត្រូវតែបញ្ជូនសារថា កាយវិការបែបនេះមិនគប្បីអនុញ្ញាតដែលជាវិធានរបស់តុលាការអន្តរជាតិ ហើយវិធាន២២ នៃវិធានផ្ទៃក្នុងដែលនិយាយថា កថាខណ្ឌទី៤ ការអនុវត្តភារកិច្ចរបស់ខ្លួន មេធាវីក៏ត្រូវគោរពទៅតាមច្បាប់កម្ពុជា ហើយនិងលក្ខន្តិកៈគណមេធាវី ហើយនិងគោលការណ៍ និងក្រមសីលធម៌ដែលទទួលស្គាល់។ គេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីដោយប្រសិទ្ធភាព ហើយនិងទាក់ទងទៅនឹងភស្តុតាងអំពីថ្ងៃទី១១ ខែមិថុនា។

[១០:៤១:៥៩]

ខ្ញុំយោងទៅប្រតិចារឹកព្រាង។ ខ្ញុំយោងទៅភស្តុតាងរបស់ សូ សុជាតិ ហើយខ្ញុំយោងទៅពេលគឺម៉ោង ១៥:០៩:០២វិនាទី។ នៅពេលដែលមេធាវីការពារក្តីលោក ខៀវ សំផន មេធាវីជាតិនិយាយថា សូមដកស្រង់សម្តីគាត់ "ខ្ញុំសូមជំទាស់ គាត់និយាយថាគឺការប្រើប្រាស់ពាក្យខុស សម្តីរបស់សាក្សី ហើយគាត់និយាយថាសាក្សីនេះបានធ្វើសក្ខីកម្មថានេះជាពេលវេលាដែលកូនរបស់គាត់មានអាយុ១ខែ មិនមែនពេលដែលលោកខៀវ សំផន ទៅនៅជាមួយគ្រួសាររបស់គាត់ទេ"។

លោកប្រធានចាំហើយ លោក លោកស្រីចាំហើយថា សហព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត បានអានពីប្រតិចារឹកខ្មែរ ហើយគាត់បានអានឃ្លានេះ "ក្រោយមកគាត់ត្រឡប់មកពីប្រទេសចិន គាត់បានរស់នៅទីនោះជួយកូនរបស់ខ្ញុំប្រហែលជា១ខែ"។ ម្តងទៀត សុង ឆវ័ន្ត នោះក៏បានបញ្ជាក់ថា ប្រតិចារឹក

ខ្មែរគឺទាក់ទងទៅនឹងរយៈពេលវេលាដែល ខៀវ សំផន បាននៅជាមួយគាត់។ គឺមិនមានអ្វីដែលទាក់ទងទៅនឹងអាយុកុមារដូចមេធាវីការពារក្ដីលើកទេ។

ហើយនិងបន្តដាក់សំណើរ ហើយខ្ញុំសូមជម្រាបតុលាការថា នេះគឺជាការបំពានធ្ងន់ធ្ងរទៅលើក្រមសីលធម៌ដើម្បីឲ្យមេធាវីទៅនិយាយអំពីសក្ខីកម្មរបស់សាក្សី ហើយនិងបកស្រាយអត្ថន័យរបស់នៅក្នុងសក្ខីកម្មរបស់សាក្សី។ នេះជាមុខងាររបស់សាក្សីក្នុងការផ្ដល់សាក្សី មិនមែនមុខងាររបស់មេធាវីដើម្បីពន្យល់ថាសាក្សីនិយាយដូចម្ដេចនៅក្នុងចម្លើយរបស់ខ្លួននោះទេ។ ខ្ញុំសូមដកស្រង់ចេញពីប្រតិចារឹកនៅម៉ោង ១៥:១៤:៣៨វិនាទី។ មេធាវីការពារក្ដីរបស់លោក ខៀវ សំផន បាននិយាយថា សូមដកស្រង់ “ដូច្នេះ ខ្ញុំគិតថាគឺជាការអានមិនត្រឹមត្រូវនូវភាសានោះ។ នៅពេលដែលលោក ខៀវ សំផន មកជួយគាត់នោះ គាត់មានន័យថា នៅពេលដែលកូនរបស់គាត់មានអាយុស្ទើរតែ១ខែ ជិត១ខែ”។

[១០:៤៤:៤១]

ចំណុចសំខាន់នៅទីនេះ សូមជម្រាបលោកប្រធានថា តាមពាក្យនេះលោកមេធាវីចង់បញ្ជូនសញ្ញាទៅឲ្យសាក្សីថាឲ្យផ្ដល់ គឺគាត់ផ្ដល់ព័ត៌មានទៅឲ្យសាក្សី គឺប្រាប់ទស្សនៈរបស់គាត់ថា សាក្សីគប្បីតែនិយាយបែបនេះវិញ។ នេះហើយគឺជាចេតនារបស់មេធាវីការពារជាតិ ហើយភស្តុតាងបញ្ជាក់ពីយល់នេះ អំពីការឆ្លើយតបរបស់លោកស្រី សូ សុជាតិ នោះ គឺនៅម៉ោង ១៥:១៨:១៣វិនាទី នៅពេលដែលគាត់និយាយថា “ប្ដីរបស់ខ្ញុំមកពីប្រទេសចិន ហើយនៅពេលដែលគាត់មក កូនរបស់ខ្ញុំគឺមានអាយុជិត១ខែ”។ ហើយម្យ៉ាងទៀត មេធាវីនោះក៏បានលើកឡើងថា “គឺនៅគាត់នៅតែទទួលស្គាល់ថា រយៈពេលនោះគឺជាអាយុកូន មិនពេលរបស់លោក ខៀវ សំផន ទេ”។

ដូច្នេះ សូមតុលាការ លោកប្រធាន ខ្ញុំសូមបំភ្លឺបន្ថែម ហើយនិងចៅក្រមផ្សេងទៀតថា សំណើរបស់ខ្ញុំនេះគឺច្បាស់សម្រាប់តុលាការហើយ គឺថាមិនមានអ្វីច្បាស់ជាងហ្នឹងទៀតទេ ប្រសិនជាតុលាការត្រូវការបំភ្លឺ ខ្ញុំនឹងជម្រាបបំភ្លឺបន្ថែម។ សូមអរគុណ។

[១០:៤៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក អាក់ទួរ វែកគែន!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយខ្លីទេ។ បាទ ជាបឋមគឺថាសូមផ្ដោលទោស

ការប៉ុនប៉ងគំរាមកំហែង។ បើតាមខ្ញុំយល់នេះ គួរឲ្យអស់សំណើចណាស់ ពីសំណាក់ខាងសហព្រះរាជអាជ្ញា។ យើងមានអារម្មណ៍ថា យើងមិននៅចំពោះមុខតុលាការអាជីពទេ ក៏ប៉ុន្តែនៅចំពោះមុខ ថាអ្នកដែលគ្រាន់តែចេះច្បាប់បន្តិចបន្តួចនោះ ដោយគ្រាន់តែមកនិយាយលើកដៃ លើកជើង។ នេះជាការកត់សម្គាល់ទី១ របស់ខ្ញុំ។ ខ្ញុំគិតថា បើនៅក្នុងសាលសវនាការនេះ អស់រយៈពេល១ឆ្នាំកន្លះជាងហើយ យើងបានសុំការដាក់ឲ្យមានពិន័យនៅពេលដែលមានការជំទាស់អីនោះ ភាគីទាំងអស់និយាយសុំដាក់ឲ្យជំទាស់រាល់ដង ឲ្យមានការពិន័យនេះ តុលាការនេះរលាយបាត់ទៅហើយ ព្រោះថារាល់ដងត្រូវតែចេញសេចក្តីសម្រេច។

អ៊ីចឹង ខ្ញុំគិតថានេះគួរឲ្យ ថាគួរឲ្យអស់សំណើចណាស់ដែលមានការប៉ុនប៉ងសុំបំភិតបំភ័យនេះ។ ក៏ប៉ុន្តែផ្ទុយទៅវិញ សហភាតារបស់ខ្ញុំ សហភាតាជាតិរបស់ខ្ញុំនេះបានធ្វើការងារមួយ គឺថាគាត់គ្រាន់តែចង់ ពេលដែលគាត់ជំទាស់នោះ គ្រាន់តែចង់បង្ហាញថាជាការលំបាកក្នុងការបកស្រាយ ការបកប្រែព្រោះនៅក្នុងតុលាការយើងនេះ។ ព្រោះថាយើងឃើញស្រាប់ហើយមាន មិនមែនជាកំហុសអ្នកណាទេ ជាការលំបាកក្នុងការបកប្រែដោយផ្ទាល់ នៃពាក្យពេចន៍ដែលយើងបាននិយាយ ភាគីបាននិយាយ។

[១០:៤៨:០១]

យើងមានខ្សែអាត់ យើងមានប្រតិចារឹត។ ខ្ញុំគិតថា អង្គជំនុំជម្រះមានការងារផ្សេងទៀតត្រូវធ្វើ។ អ៊ីចឹងដូចមិនចាំបាច់ឆ្លើយ បើសិនជាអង្គជំនុំជម្រះចង់ឆ្លើយតបទៅនឹងសំណើសហព្រះរាជអាជ្ញានោះ អ៊ីចឹងសូមឲ្យគាត់ឆ្លើយលាយលក្ខណ៍ជា -- ធ្វើសំណើជាលាយលក្ខណ៍អក្សរទៅ ហើយយើងមានខ្សែអាត់ យើងមានប្រតិចារឹក។ អ៊ីចឹងយើងនឹងឃើញហើយថា ការជំទាស់របស់សហភាតារបស់ខ្ញុំនោះគ្រាន់តែចង់បង្ហាញថា មានការបញ្ហាក្នុងការបកស្រាយបកប្រែទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់លើកឡើងប៉ុណ្ណឹងទេ មានខ្សែអាត់ មានប្រតិចារឹកអីអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំសូមអរគុណតំណាងសហព្រះរាជអាជ្ញាដែលបង្ហាញពីជំហរមួយ ដែលលោកគិតថាដើម្បីយុត្តិធម៌នៃតុលាការនេះជារួម។ ហើយទាក់ទងនឹងរឿងដែលលោកបានលើកឡើងជាក់លាក់ចំពោះ

ករណីដែលខ្ញុំធ្វើការជំទាស់ក្នុងពេលកន្លងមកនេះ។

ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា បញ្ហានេះគឺជាការងារក្នុងនាមខ្ញុំជាមេធាវីម្នាក់ដែលចូលរួមក្នុងនីតិវិធីនេះ ដើម្បីពិនិត្យទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីនេះផងដែរ ថាតើមានអ្វីដែលជាចំណោទទាំងអង្គហេតុ ទាំងអង្គច្បាប់ ដែលយើងបានពិភាក្សាដេញដោលនេះ។ ជាក់ស្តែងទាក់ទងនឹងសក្ខីកម្មរបស់អ្នកស្រី សូ សុជាតិ។

[១០:៤៩:៤៥]

នៅពេលដែលមានបញ្ហាពីការអានមិនត្រឹមត្រូវនៅក្នុងអត្ថបទដែលជាកំណត់ហេតុសវនាការនោះ ខ្ញុំស្នើសុំលោកប្រធានដើម្បីធ្វើការជំទាស់ និងបញ្ចេញយោបល់របស់ខ្លួនក្នុងឋានៈមេធាវីរបស់លោក ខៀវ សំផន។ ក្នុងអត្ថបទដែលយើងអាននេះ វាជាភាសាខ្មែរដែលជាភាសាដើម។ អ៊ីចឹងយើងអាចមើលឃើញយ៉ាងច្បាស់ថាអ្នកដែលមិនប្រើប្រាស់ភាសាខ្មែរតាមដាននៅក្នុងសវនាការនេះ គឺឃ្លាតឆ្ងាយពីការយល់ដឹងពិតប្រាកដណាស់ គឺគាត់មិនអាចយល់ច្បាស់ទេទោះបីប្រើភាសាអង់គ្លេស ឬភាសាបារាំងក៏ដោយ។ អ៊ីចឹងអ្នកដែលចេះភាសាខ្មែរ គឺអាចពិនិត្យទៅលើសាច់រឿងនេះបានយ៉ាងច្បាស់ល្អជាងអ្នកដែលប្រើភាសាបរទេស។

ហើយជាក់ស្តែងអង្គហេតុដែលអ្នកស្រី សូ សុជាតិ បានលើកហើយដែលខ្ញុំបានធ្វើការកែតម្រូវចំពោះការអានអត្ថបទនេះ មិនមែនជាអង្គហេតុថ្មីទេ គឺអ្នកស្រី សូ សុជាតិ បានឆ្លើយបញ្ជាក់ចំពោះមេធាវីលោក អាកទូរ វែកគែន ដែលបានសួររួចទៅហើយ។ ហើយចំណុចនេះវាអត់មានអីជាចំណុចថ្មីដែលធ្វើឲ្យខ្ញុំនាំសាក្សីទៅនិយាយអ្វីដែលជាចំណុចខុសទេ គឺចំណុចដែលខ្ញុំកែប្រែៗការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាមិនត្រឹមត្រូវ គឺគាត់លើកនូវអង្គហេតុមួយខុសដើម្បីធ្វើឲ្យសាក្សីយល់ច្រឡំ។ ចំណុចនេះហើយ ដែលធ្វើឲ្យខ្ញុំត្រូវតវ៉ា។

[១០:៥១:១៥]

ហើយទាក់ទងទៅនឹងការស្នើសុំដាក់វិន័យចំពោះការដែលថាខ្ញុំខុសវិជ្ជាជីវៈ សូមឲ្យលោករៀបចំជាលាយលក្ខណ៍អក្សរទៅ ហើយយើងនឹងធ្វើការ ហើយជាក់ស្តែងតុលាការនេះក៏អាចមានសិទ្ធិក្នុងការបញ្ជូនពាក្យបណ្តឹងទៅគណៈមេធាវី ពីព្រោះខ្ញុំជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អ៊ីចឹងលោកអាចបញ្ជូនសំណុំរឿងនេះទៅដើម្បីឲ្យគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវីជាអ្នកវិនិច្ឆ័យចំពោះការប្រព្រឹត្តរបស់ខ្ញុំ។ ហើយខ្ញុំក៏នឹងមានសិទ្ធិវាយបកសម្រាប់លោកវិញដែរ ចំពោះការរំខាននានា

ក្នុងការអនុវត្តសិទ្ធិរបស់ខ្ញុំជាមេធាវីការពារនៅទីនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ មានអីទៀតទេ?

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១០:៥២:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ ទោះជាយ៉ាងណាក្ដី យើងមិនមែន ហាក់ដូចជាមិនភាគីផ្ទាល់ទាក់ទងទៅនឹងការខ្វែងគំនិតគ្នារវាងមេធាវីលោក ខៀវ សំផន និង សហព្រះរាជអាជ្ញា។ ប៉ុន្តែខ្ញុំយល់ថាសារៈសំខាន់ណាស់ក្នុងកំណត់ត្រាតុលាការ សំឡេងរបស់យើងខ្ញុំក្នុងការគាំទ្រទាំងស្រុងអំពីសំណើរបស់មេធាវីការពារក្ដីរបស់លោក ខៀវ សំផន។

យើងខ្ញុំស្ងាត់ណាស់ថ្ងៃនេះនិងម្សិលមិញ។ ប៉ុន្តែយើងបានសង្កេតឃើញថា នៅក្នុងទស្សនៈរបស់យើងគឺថាហាក់ដូចជាមានលក្ខណៈបំភិតបំភ័យក្នុងការរំខានដល់សាក្សីនេះពីភាគីម្ខាងនោះពីសហព្រះរាជអាជ្ញានោះដែរ។ ដូច្នេះហើយការសួរសំណួរសាក្សីនេះបានបញ្ចប់ ហើយពេលនោះគឺសហព្រះរាជអាជ្ញាបានលើកឡើងពីបញ្ហារបស់មេធាវីជាតិរបស់លោក ខៀវ សំផន ហើយឃើញថាមិនមានប្រភព និងមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីឱ្យភាគីម្ខាងនោះចោទប្រកាន់ទៅលើមេធាវីការពារក្ដីលោក ខៀវ សំផនទេ។ ដូច្នេះយើងគាំទ្រ ខាងមេធាវីលោក ខៀវ សំផន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០ នាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ ដែលអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការសម្រាប់សាក្សីសក្ខីកម្មថ្មីមួយរូបទៀតគឺសាក្សីដែលមានរហស្សនាម TCW-648។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៥៤នាទី ដល់ម៉ោង១១:២១នាទី)*

[១១:២១:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម TCW-648 ព្រមទាំងមេធាវី ប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទាប់សវនាការ)*

[១១:២៣:៤៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ស៊ឹម ហោ៖**

**ឆ៖** ខ្ញុំបាទ សូមគោរពលោកប្រធាន អង្គចៅក្រម ខ្ញុំបាទឈ្មោះ ស៊ឹម ហោ រស់នៅក្នុងឃុំត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំបាទ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ ហើយប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំអាយុ៦២ បាទ។ មុខរបរធ្វើជាមេភូមិបច្ចុប្បន្ន។

**ស៖** តើឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ស៊ឹម ម្តាយខ្ញុំឈ្មោះ ប្រាក់។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

[១១:២៥:០៤]

**ឆ៖** ប្រពន្ធឈ្មោះ យ៉ត។ កូនប្រាំមួយនាក់។

**ស៖** អរគុណលោក ស៊ឹម ហោ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីម្សិលមិញ ថាតាមសមត្ថភាពតាមលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ ហើយក៏មិនជាប់ញាតិ ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបនាក់ -- ទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ

សំផន។ ហើយថាលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយកាលពីម្សិលមិញ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតហើយ ខ្ញុំពុំមានជាប់ជាសាច់ញាតិអ្វីជាមួយនឹងលោក នួន ជា និងលោក ខៀវ សំផន ទេ។

**ស៖** បាទ អរគុណ។ ហើយលោក ស៊ឹម ហោ ក្នុងនាមលោកជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ លោកអាចបដិសេធក្នុងឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើបទអត្ថាធិប្បាយណាមួយឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ដោយសារបញ្ហានេះដែលអាចកើតមាន គឺអង្គជំនុំជម្រះបានសហការជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ បានផ្តល់ជូននូវមេធាវីប្រឹក្សាសាក្សីមួយរូប គឺលោកមេធាវី ម៉ម រិទ្ធា ដែលអង្គុយក្បែរលោកនេះ ដើម្បីលោកអាចប្រឹក្សាពិភាក្សាយោបល់ជាមួយគាត់ចំពោះសំណួរណាដែលទំនងជាអាចផ្តល់ចម្លើយ ឬក៏សេចក្តីអះអាងរបស់លោកមានលទ្ធភាពអាចការដាក់បន្ទុកលើខ្លួនឯង គឺប្រឆាំងនឹងរូបលោក។

[១១:២៧:០១]

ហើយទន្ទឹមនឹងនេះ គឺលោកក្នុងនាមជាសាក្សីក៏មានករណីកិច្ចត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ដោយឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក ហើយលោកត្រូវតែផ្តល់សក្ខីកម្មនូវអ្វីដែលលោកបានដឹង បានឮ បានឃើញ បានធ្វើការសង្កេត ឬក៏ធ្លាប់បានបទពិសោធជួបប្រទះដោយផ្ទាល់នូវព្រឹត្តិហេតុ និងហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលគាត់ ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះដែរឬទេ?

[១១:២៧:៤៧]

**ឆ៖** បាទ សូមជម្រាបទៅលោកចៅក្រម រឿងអង្គជំនុំជម្រះ ដែលបានកោះអញ្ជើញខ្ញុំបានធ្វើជាសាក្សីក្នុងករណីកន្លងទៅអាចបានដឹង និងបានឃើញពិត សូមឆ្លើយទៅតាមការងារស្មោះត្រង់របស់យើងខ្ញុំបាទ។

**ស៖** អរគុណ។ ហើយលោក ស៊ឹម ហោ តើលោកមានធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នក

ស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបសង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញាក្នុងតុលាការកម្ពុជានេះ ដែរឬទេ ប៉ុន្មានឆ្នាំកន្លងមកនេះ?

**ឆ៖** កន្លងទៅក្រុមស៊ើបអង្កេតបានទៅជួបសម្ភាសយើងខ្ញុំបានម្តងពីរដងដែរលោក។

**ស៖** លោកចាំទេ កាលគេធ្វើនៅទីកន្លែងណា ហើយនៅពេលណា? នៅក្នុងឆ្នាំណាលោកចាំទេ?

**ឆ៖** ខ្ញុំមិនបានចាំទេថ្ងៃខែ តែគ្រាន់តែដឹងថាធ្វើនៅនឹងលើផ្ទះរបស់យើងខ្ញុំតែម្តង ក្នុងឆ្នាំ -- អត់បានចាំឆ្នាំផងបាទ ភ្លេចដែរ។

**ស៖** ប៉ុន្មានឆ្នាំហើយលោក ហោ? ពីរបីឆ្នាំកន្លងមកហើយមែនទេ?

**ឆ៖** អត់ចាំដែរបងឆ្នាំ។

[១១:២៩:៣៧]

**ស៖** អរគុណ។ ហើយមុននឹងចូលមក -- កំណត់ហេតុដែលបានផ្តល់--

**លោក គង់ សំអុន៖**

លោកប្រធាន អត់បើកក្បាលមីក្រូ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មុននឹងចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ តើលោកបានពិនិត្យ និងបានអាននូវកិច្ចសម្ភាសន៍ដែលលោកបានផ្តល់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលោកថាមិនចាំថ្ងៃ ហើយបានធ្វើនៅផ្ទះរបស់លោកម្តង ឬក៏ពីរដង។ តើលោកបានអាន បានពិនិត្យ និងបានអានហើយឬនៅ? ហើយខ្លឹមសារនៃកិច្ចសម្ភាសន៍ហ្នឹង វាស្របជាមួយនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មដែរឬទេ?

**ឆ៖** បាទ ត្រង់បញ្ហាបទសម្ភាសន៍នោះ ខ្ញុំគ្រាន់តែមើលបានត្រួសៗទេ មិនបានចាំឲ្យបានពិតប្រាកដទេ។ សូមជម្រាបលោកចៅក្រម។

**ស៖** បើលោកពិនិត្យទៅ លោកអាចពិនិត្យមើល ហើយចងចាំបានទេ ហើយខ្លឹមសារដែលលោកបានពិនិត្យចុងក្រោយមុនពេលមកចូលមកបន្ទប់សវនាការនេះ ធៀបជាមួយនឹងអ្វីដែលជាលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតហ្នឹង។ តើវាស៊ីសង្វាក់គ្នា វាស្របដែលឬទេ ឬក៏វាមានចំណុចណាដែលផ្ទុយគ្នា?

[១១:៣១:១៣]

**ឆ៖** អានេះអាស្រ័យនៅលើអង្គចៅក្រមជាអ្នកសួរនាំ យើងខ្ញុំឆ្លើយទៅតាមការឃើញការដឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហក្រុមមេធាវីការពារក្តីលោក ខៀវ សំផន រួមនិងមេធាវីការពារក្តីលោក នួន ជា ក្នុងការសួរសាក្សីនេះ គឺមានរយៈពេលកន្លះថ្ងៃ។

*(សម្រាករយៈពេលខ្លី)*

[១១:៣២:១៨]

បាទសូមកែសម្រួលឡើងវិញ បាទមានការភ័ន្តច្រឡំ មិនមែនស្នើឡើងដោយមេធាវីការពារក្តី លោក ខៀវ សំផន ទេ គឺស្នើសុំឡើងដោយតំណាងសហព្រះរាជអាជ្ញាទេ។ ដូច្នេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវសួរមុនភាគីដទៃទៀតនៃរឿងក្តី។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោក ស៊ឹម ហោ។ ខ្ញុំឈ្មោះ វាំសង់ វ៉ាយដ៍ ខ្ញុំតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំនឹងសួរសំណួរទៅកាន់លោកព្រឹកនេះ និងនៅរសៀលនេះ។ ជាដំបូងខ្ញុំចង់បានការបំភ្លឺអំពីលោក។ លោកបានឆ្លើយថា លោកបានផ្តល់សម្ភាសជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ តើលោកធ្លាប់ត្រូវបានសម្ភាសកាលពីដើមឆ្នាំ២០០០នោះ ដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

[១១:៣៣:៣៨]

**លោក ស៊ឹម ហោ៖**

**ឆ៖** បានសម្ភាសម្តងដែរលោក។

**ស៖** បាទសូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះខ្ញុំត្រឡប់មកនិយាយអំពីខ្សែជីវិត

របស់លោកនៅមុន និងក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ដូច្នេះខ្ញុំយោងទៅលើឯកសារមួយ គឺឯកសារ IS19.177។ ឯកសារនេះជាប្រវត្តិរូបបដិវត្តន៍របស់ឈ្មោះ ស៊ឹម ហោ ហៅ ថាត កើតនៅភូមិទួលត្រាត ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ជូននូវប្រវត្តិរូបបដិវត្តន៍ជូនសាក្សី ហើយនិងសុំការអនុញ្ញាតដើម្បីបញ្ចាំងនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំយល់ព្រម និងអនុញ្ញាត។

សូមមន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១១:៣៥:១៨]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីសូមលោកបើកទៅទំព័រទី៣ ដែលមាននិយាយអំពីព័ត៌មានផ្ទាល់ខ្លួន ក្នុងនោះមានឈ្មោះ បាទទំព័រហ្នឹងហើយ ត្រូវហើយ ទំព័រទី៣។ ទំព័រនេះមានព័ត៌មានផ្ទាល់ខ្លួន មានឈ្មោះ មានថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើតរបស់អ្នកដែលសរសេរប្រវត្តិរូបនេះ។ លោកសាក្សីតើលោកអាចប្រាប់បានទេ ថានេះគឺជាប្រវត្តិរូបដែលលោកសរសេរដោយផ្ទាល់ដៃនៅក្នុងរបបខ្មែរក្រហម មែនទេ?

**លោក ស៊ឹម ហោ៖**

**ឆ៖** បាទ។ បានបញ្ជាក់ឃើញថា សរសេរផ្ទាល់មែនបាទ។

**ស៖** តើលោកចាំទេ ថាអ្នកណាជាអ្នកសុំឱ្យលោកសរសេរប្រវត្តិរូបនេះ?

**ឆ៖** អត់ទោស ខ្ញុំមិនបានចាំបាទ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ សូមឱ្យលោកបើកមកទំព័រខាងមុខវិញ គឺទំព័រទី២ គឺយើងឃើញមានតារាងមួយ ហើយមានថ្ងៃខែឆ្នាំច្រើនណាស់ក្នុងនេះ។ ក្នុងនោះដាក់ថាទីកន្លែងធ្វើការ។ យើងឃើញមានកាលបរិច្ឆេទមួយចំនួនសម្រាប់ជាប្រតិចារឹកនោះ។ ឯកសារនោះត្រូវបានបកជាភាសាបារាំង។ ក៏ប៉ុន្តែមានកំហុសបកប្រែមួយចំនួនដែរ។ ដូច្នេះ ខ្ញុំនឹងកែតម្រូវការបកប្រែនោះ ជាបន្តបន្ទាប់។ លោកសាក្សី សូមឱ្យលោកពិនិត្យថ្ងៃខែឆ្នាំនៅទំព័រទី២។ យើងមើលថ្ងៃខែឆ្នាំ មុនឆ្នាំ៧៥ ថ្ងៃខែឆ្នាំទី១នោះ

គឺដាក់ថា ក្នុងឯកសារហ្នឹង គឺ១៥-៦-៧២ ហើយនៅផ្នែកនោះ ដាក់ថា យោធា អង្គភាព គឺវរសេនាតូច ៣០៦។ តើលោកអាចបញ្ជាក់បានទេ ថាលោកពិតជាចូលកងវរសេនាតូច៣០៦ហ្នឹង នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧២?

[១១:៣៨:២៧]

**ឆ៖** បាទ ខ្ញុំបាទសូមឆ្លើយជូន គឺថាក្នុងថ្ងៃខែហ្នឹងមិនបានចាំ ប៉ុន្តែក្នុងការចូលជាកងទ័ពវរសេនា តូច៣០៦ហ្នឹង បានធ្វើពិតមែនបាទ។

**ស៖** លោកសាក្សី នេះគឺជាប្រវត្តិរូបដែលលោកសរសេរនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ តើនៅក្នុងរបបនោះ ថ្ងៃខែឆ្នាំដែលលោកសរសេរហ្នឹងគឺថាជាពិតហើយ តើអ៊ីចឹងមែនទេ ជាថ្ងៃខែឆ្នាំត្រឹមត្រូវ?

**ឆ៖** បាទៗ ខ្ញុំថាពិតហើយលោក សូមជម្រាបជូនដោយខ្លីៗប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ តើលោកអាចប្រាប់បានទេ ហេតុអ្វីបានជាលោកចូលបក្សបដិវត្តន៍ ហើយជាពិសេសហ្នឹងចូលវរសេនាតូច៣០៦ហ្នឹង នៅឆ្នាំ១៩៧២?

**ឆ៖** កាលក្នុងសម័យនោះ ខ្ញុំសូមជម្រាបជូនអង្គចៅក្រមថា បញ្ហាដែលចូលទ័ពមិនចំពោះតែយើងខ្ញុំទេ អានេះវាជាទូទៅហើយនៅក្នុងសម័យសង្គម ហៅថារបបខ្មែរក្រហមជំនាន់នោះបានកៀងគរកម្លាំងទៅឲ្យចូលទ័ពអ៊ីចឹងតែម្តងដើម្បីប្រនាំងជាមួយនឹង និយាយថាប្រឆាំងជាមួយនឹងយួនអ៊ីចេះតែម្តងបាទ។

**ស៖** សូមអរគុណ។ ថ្ងៃខែឆ្នាំបន្ទាប់មកទៀតនៅក្នុងប្រវត្តិរូបរបស់លោកនោះ គឺថ្ងៃទី៣ ខែ២ ឆ្នាំ១៩៧៤ ហើយក្នុងនោះដាក់ថាវរសេនាតូច៧០៩។ តើលោកចាំទេ តើលោកបានចូលធ្វើការនៅក្នុងវរសេនាតូច៧០៩ ហ្នឹងមែន?

**ឆ៖** បាទ បន្តបន្ទាប់ទៅ គឺចូលក្នុងវរសេនាតូច៧០៩អ៊ីចឹងមែន នៅខាងសៀមរាបនៅធ្វើការ។

**ស៖** ថ្ងៃខែឆ្នាំបន្ទាប់មកទៀតនោះ គឺថាមើលទៅថ្ងៃយើងមើលអត់ឃើញទេ ឃើញតែខែ៣ ឆ្នាំ ១៩៧៥ ហើយនោះដាក់ថាវរសេនាតូច៧៧៤។ តើលោកចាំទេ ថាលោកបានចូលនៅក្នុងវរសេនាតូចហ្នឹង? វរសេនាតូច៧៧៤ ហ្នឹង? ហើយតើលោកមានមុខងារអ្វីដែរ ក្នុងវរសេនាតូច៧៧៤នោះ?

[១១:៤១:៤៥]

**ឆ៖** ត្រង់វរសេនាតូច៧៧៤ គឺមិនបានចាំ។

**ស៖** មុនខែមេសា ឆ្នាំ១៩៧៥ នោះ តើគេមានការតម្លើងឋានន្តរសក្តិរបស់លោកនៅក្នុងជួរកងទ័ពជាពិសេសនៅក្នុងវរសេនាតូចទាំងប៉ុន្មានដែលលោកបានធ្វើការនោះ តើមានទេមានការដំឡើងឋានន្តរសក្តិទេ?

**ឆ៖** នៅពេលនោះដែលចូលជាកងទ័ពនោះ មិនមានឋានន្តរសក្តិជាអ្វីទេ នៅជាដូចថាសាច់ទ័ពតែម្តង ជាយុទ្ធជនតែម្តង អ្នកធ្វើទ័ព។

**ស៖** ដើម្បីបំភ្លឺបញ្ហាទាំងអស់នេះ ខ្ញុំសូមបញ្ជាក់អំពីអ្វីដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងកំណត់ហេតស្តាប់ចម្លើយរបស់លោក គឺលេខ E3/363 គឺថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០០៨។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ដូច្នេះសូមការអនុញ្ញាតលោកប្រធាន ដើម្បីផ្តល់ជូនកំណត់ហេតុស្តាប់ចម្លើយជាភាសាខ្មែរជាក្រដាសជូនសាក្សីដើម្បីឲ្យគាត់អាន លោកប្រធាន។

[១១:៤៣:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីសូមលោកមើលទំព័រជាភាសាខ្មែរនោះ គឺសូមឲ្យលោកមេធាវីជួយផង គឺ 00236031 សូមម្តងទៀត គឺ 00236031, ជាភាសាបារាំងទំព័រទី២, ជាភាសាអង់គ្លេសក៏ទំព័រទី២ដែរ។ ខ្ញុំសូមដកស្រង់ "នៅខែមេសា ឆ្នាំ១៩៧៥ គេតម្លើងតំណែងខ្ញុំជាអនុប្រធានក្រុម"។ សូមបញ្ចប់ការដកស្រង់។ តើលោកចាំទេថាគេ តម្លើងតំណែងលោកជាអនុប្រធានក្រុមនៅខែមេសា -- ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ គឺថា២ខែមុនពេលវាយចូលភ្នំពេញ។ បាទ គឺថា១ក្នុងឯកសារហ្នឹង គឺនៅសំណួរដំបូងតែម្តង។

ខ្ញុំសូមដកស្រង់ម្តងទៀត "នៅខែមេសា ឆ្នាំ-- ខែកុម្ភៈ(សូមទោស) ឆ្នាំ១៩៧៥ ខ្ញុំបានឡើងជាអនុប្រធានក្រុម"។ តើត្រឹមត្រូវដែរឬទេ លោកសាក្សីគឺថានៅខែកុម្ភៈ ឆ្នាំ១៩៧៥ លោកជាអនុប្រធានក្រុម?

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអរគុណ។ ការផ្តល់ចម្លើយនេះ គឺខ្ញុំបានឡើងជាអនុប្រធានក្រុមពិតមែនក្នុងអំឡុងឆ្នាំនុ៎ង។

**ស៖** តើលោកអាចជម្រាបតុលាការអំពីរយៈពេលមុនខែមេសា ឆ្នាំ៧៥ គឺមុនដែលលោកចូលវរសេនាតូច៣០៦ ហើយនិងវរសេនាតូច៧០៩។ តើលោកនៅក្នុងកងទ័ពមួយណាមុនពេលនោះ? គឺនៅក្នុងកងទ័ពរបស់ភូមិភាគឬមិនមែនទេ? បើសិនជាកងទ័ពភូមិភាគ តើកងទ័ពភូមិភាគណា?

**ឆ៖** បាទ នៅពេលនោះ គឺថាយើងខ្ញុំនៅក្នុងទ័ព -- ក្នុងកងទ័ពភូមិភាគដែរបាទ តែគេបានចេញពីខេត្តកំពង់ធំមកចូលទៅក្រុងភ្នំពេញហ្នឹង នៅចុងឆ្នាំ៧៥ ហើយបាទ ប៉ុន្តែនៅក្នុងនោះ យើងខ្ញុំបានរបួសអត់មានធ្វើការអីកើតទេបាទ។ នៅសម្រាកតែក្នុងកន្លែងមន្ទីរពេទ្យ។

[១១:៤៧:០០]

**ស៖** សូមអរគុណ។ លោកនិយាយអំពីភូមិភាគណា? លោកស្គាល់លេខកងពលដែលលោកស្ថិតនៅក្នុងហ្នឹងទេ ហើយអ្នកណាជាមេកងពលនោះ?

**ឆ៖** ក្នុងនោះគឺភូមិភាគឧត្តរ ប្រធានកងពល គឺគេហៅថា តាពក១ អ៊ីចឹង ព្រោះអត់ដែលបានស្គាល់ផ្ទាល់ទេ គ្រាន់តែឮឈ្មោះ។

**ស៖** ចុះអ្នកណាជាប្រធានកងវរសេនាតូច គឺថាក្នុងមុនពេលខែមេសា ឆ្នាំ១៩៧៥ហ្នឹង? អ្នកណាជាប្រធានកងវរសេនាតូចរបស់លោកនោះ?

**ឆ៖** ប្រធានកងវរសេនាតូចរបស់យើងខ្ញុំគឺមានឈ្មោះលោក តាបេង ៧០៩។

**ស៖** សូមអរគុណ។ សូមលោកប្រាប់ឈ្មោះផងដែរនៅប្រធានភូមិភាគឧត្តរ ហើយនិងអនុប្រធានភូមិភាគឧត្តរ?

**ឆ៖** ប្រធានភូមិភាគឧត្តរ ក៏មិនដែលបានឃើញរូបគាត់ផ្ទាល់ទេ តែគ្រាន់តែឈ្មោះគាត់គឺហៅថា ឈ្មោះ ធុច។ អនុគឺ តាពក ជាប្រធានកងពលហ្នឹងហើយ។

[១១:៤៩:១១]

**ស៖** តើលោកអាចនិយាយអំពីវិន័យនៅក្នុងកងពលបានទេ? ឧទាហរណ៍ថា តើលោកមានសិទ្ធិជំទាស់ទៅនឹងការបញ្ជារបស់ថ្នាក់លើ របស់មេរបស់លោក ឬក៏មានសិទ្ធិជំទាស់ទៅនឹងគោលនយោបាយដែលដាក់ចេញដោយបក្សដែរឬទេ?

**ឆ៖** នៅក្នុងសម័យនោះ គឺខ្ញុំសូមជម្រាបដោយស្មោះថា មិនមានសិទ្ធិអ្វីដែលអាចជំទាស់ហ្នឹងប្រធានកងវរៈនោះទោះបានទេបាទ។

**ប្រធានអង្គជំនុំ៖**

លោក ហោ លោកទុកឯកសារនុំងសិនទៅ ចាំពេលណាដែលគេសួរដល់ការពិនិត្យឯកសារសូមលោកមើលឯកសារ។ ឥឡូវនេះលោកស្ដាប់សំណួរ ហើយនិងឆ្លើយតាមការចងចាំរបស់លោក។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកអាចផ្ដល់ឧទាហរណ៍អំពីអ្វីដែលបានកើតឡើងចំពោះយោធា ឬក៏ទាហានដែលមិនបានគោរពវិន័យរបស់កងពល និងវិន័យរបស់បក្សនោះ។ ឧទាហរណ៍ថាបើសិនជាមានទាហានណាមួយមិនគោរពវិន័យហ្នឹង តើគេធ្វើយ៉ាងម៉េចចំពោះពួកគាត់?

**លោក ស៊ឹម ហោ៖**

**ឆ៖** ក្នុងសម័យនោះ ខ្ញុំពិនិត្យទៅ តែមេបញ្ជាការផ្ទាល់ហ្នឹងគឺប្រធានវរៈនោះ ខ្ញុំថាបើមិនគោរពវិន័យហ្នឹង មិនដែល -- អ្នកណាហ៊ានតែម្ដង ព្រោះនិយាយទៅនៅក្នុងកងវរៈនុំង គាត់ហ្នឹងគឺកាចយកតែម្ដង ខ្លាចធ្វើអីមិនចេញ។ គ្រាន់តែមើលមុខមិនចង់ហ៊ានមើលផង។ តែបញ្ជាឲ្យទៅគឺទៅ។

[១១:៥១:៣៧]

**ស៖** ក្នុងឋានៈលោកជាសមាជិកវរសេនាតូចនៃភូមិភាគឧត្ដរ តើលោកធ្លាប់បានប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ព លន់ នល់។ ឧទាហរណ៍ដូចជានៅកំពង់ធំ ឬនៅសៀមរាបដែរឬទេ?

**ឆ៖** វ៉ៃនៅម្ដុំសៀមរាបដែរ ហើយត្រឡប់មកក្រោយមកមុននឹងរំដោះ ហៅថា១៧មេសា ហ្នឹងគេមកនៅវ៉ៃនៅខេត្តកំពង់ធំ យើងខ្ញុំបានរបួសនៅម្ដុំកន្លែងគេហៅខាងណោះកំពង់ធំនេះ អត់ចាំ កន្លែងខ្ញុំភ្លេចទាំងភូមិទៀត។ តាំងពីនុំងមក ខ្ញុំឈប់ធ្វើការកើត។ ដល់មកភ្នំពេញនេះ គេបញ្ជូនមក គឺមកទាំងពិការទេ មកនៅកន្លែងពិការហ្នឹង។ គេអត់មានវ៉ៃ អត់មានទោសអីនឹងគេទេ។ ដឹងតែប៉ុណ្ណឹង។

[១១:៥២:៤៤]

**ស៖** សូមអរគុណដែលលោកបានឆ្លើយបំភ្លឺ។ តើលោករបួសមុនពេលវ៉ៃចូលភ្នំពេញ ឬក៏ក្រោយពេលវ៉ៃចូលភ្នំពេញ?

**ឆ៖** របួសមុនពេលចូលទីក្រុងភ្នំពេញ នៅខេត្តកំពង់ធំ នៅម្ដុំស៊ីយ៉ូវ ក្នុងខែ២ ឆ្នាំ៧៥ បាទរបួស។

**ស៖** សូមអរគុណ។ នៅក្នុងវរសេនាតូចរបស់លោក និងនៅក្នុងកងពលនៅភូមិឧត្តរនោះ តើលោកធ្លាប់ទទួលបានជ័យជម្នះដែរឬទេ គឺថានៅចន្លោះឆ្នាំ៧៣ និង៧៤នោះ? លោកអាចវ៉ៃរំដោះយកបានភូមិភាគ -- តំបន់ ឬក៏ភូមិ ឬក៏ឃុំអីមួយចំនួនទេ ពីចន្លោះឆ្នាំ៧៣ ដល់ឆ្នាំ៧៤?

**ឆ៖** កន្លែងចន្លោះពីឆ្នាំ៧៣-៧៤ មកទល់នឹង៧៥ហ្នឹង ក្នុងវរសេនាតូចហ្នឹងគឺអាចមានសកម្មភាពផ្លាស់ប្ដូរទៅវិញទៅមកនៅតំបន់សៀមរាបអង្គរនេះឯង ប៉ុន្តែប្ដូរចុះប្ដូរឡើង បាទដូចខ្ញុំថាខាងទាហាន លន់ នល់ ឡើងទៅវ៉ៃគ្នានៅម្ដុំខាងសៀមរាប ខាងណេះសៀមរាបហ្នឹង គឺក្នុងខ្ញុំភ្លេចចាំហើយភូមិនោះ គឺងាប់ច្រើនណាស់ គរជើងលើគ្នាមិនធម្មតាទេ។ គឺការកងពលស្ពឺ៨០ គេឡើងទៅជើងខ្លាំងហ្នឹងក៏បានវ៉ៃគ្នានៅវាលនោះឯង ស្មៅស្មោង។ ស្លាប់អស់ច្រើន។

[១១:៥៤:៥៣]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរខ្ញុំនោះ ខ្ញុំចង់ដឹងថានៅពេលដែលវ៉ៃចូលកន្លែងណាមួយនោះ តើលោកអាចមានរំដោះបានភូមិ ឬក៏ស្រុក ឬក៏ឃុំអីណាមួយទេ?

**ឆ៖** ក្នុងសម័យនោះគ្រាន់តែការវ៉ៃទប់នោះឯង មានការហ៊ុមព័ទ្ធ ឡោមព័ទ្ធជុំវិញនៅខេត្តសៀមរាបតែម្ដង។ មិនមែនថាទាហានកាន់កាប់ឲ្យយើងទៅរំដោះបានហ្នឹង គឺអត់ទេ។ វាមានការតគ្នាទៅវិញទៅមកនោះឯង។ នៅតែការពារជុំវិញបរិវេណហ្នឹងតែម្ដង ខេត្តសៀមរាប។ ងាប់ទ័ពមិនតិចទេ ច្រើនកងវរៈដែរ មួយជុំវិញខេត្តហ្នឹង។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបបានទេថានៅពេលណាដែលលោកដឹងអំពីផែនការវ៉ៃចូលទីក្រុងភ្នំពេញ គឺថាវ៉ៃដើម្បីរំដោះយកទីក្រុងភ្នំពេញនោះ?

**ឆ៖** ក្នុងផែនការរំដោះទីក្រុងភ្នំពេញ ព្រោះយើងខ្ញុំរបួសហើយ មិនបានមក ហើយថាតទល់អីទេ តែគ្រាន់តែដឹងផែនការទេកំណត់ថាឲ្យរំដោះបានក្នុងឆ្នាំ៧៥តែប៉ុណ្ណោះ តែខែអត់ដឹងតែម្ដង អត់ចាំទេ ខ្ញុំនៅតែក្រោយ គឺចាប់ពីរបួសមក។

[១១:៥៦:៥០]

**ស៖** សូមអរគុណ។ មុននិយាយអំពីរយៈពេលក្រោយខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងប្រវត្តិរូបរបស់លោក ដែលលោកមាននៅមុខនឹងហើយ គឺលេខ IS19.177។ ខ្ញុំសូមអានឃ្លាមួយចំនួន ហើយសូមចោទសួរលោក។ ឃ្លាដំបូងដែលខ្ញុំចង់សួរលោកនោះ គឺថានៅលេខ 00053659, ជាភាសាបារាំង គឺនៅទំព័រ៤ គឺសំណួរទី១៣ ដែលនៅក្រោមចំណងជើង “ព័ត៌មានផ្ទាល់

ខ្លួន”។ ខ្ញុំសូមអាន “ធ្លាប់រួមជីវភាព និងធ្វើការងារបដិវត្តន៍ក្នុងមជ្ឈដ្ឋានសង្គមណាខ្លះ? ក្នុងកម្មករ កសិករបញ្ញាជន នាយទុន នារី ព្រះសង្ឃ? យល់មជ្ឈដ្ឋាននេះយ៉ាងណា? លោកបានឆ្លើយថា ធ្លាប់រួមជីវភាពធ្វើការងារជាមួយយោធារហូតមកដល់សព្វថ្ងៃបានរួមរស់ធ្វើការងារជាមួយកម្មករពាណិជ្ជកម្មរបស់បក្ស ពីព្រោះមជ្ឈដ្ឋានទាំងពីរនេះជាបង្អែករបស់បក្ស”។ លោកបាននិយាយអំពីយោធា ហើយនិងកម្មករក្នុងចម្លើយរបស់លោកនេះ។ ចុះចំពោះកសិករវិញនេះ តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងកសិករមានឋានៈយ៉ាងម៉េចដែរ?

[១១:៥៨:៥០]

**ឆ៖** ក្នុងរបបហ្នឹងគឺថា ដូចយើងខ្ញុំបានសរសេរចារទុកអ៊ីចេះឯង គឺថាជាមួយនឹងយោធារហូតមកទាល់ពេលក្រោយនេះឯង។ តមកទៀត គេថាធ្វើតែជាមួយនឹងកម្មករ។ ចំពោះកសិករបានន័យថានៅខាងក្រោយគឺមិនដែលបានចូលរួមទេ ព្រោះនៅតែធ្វើជាកម្មករលីសែងហ្នឹងបាទ។

ទី១ ទៅនៅ-- មុនដំបូងគេបញ្ជូនក្រោយរំដោះទៅ ទៅនៅកំពង់សោម បានរយៈពេល១ឆ្នាំ បានទើបត្រឡប់មកនៅទីក្រុងភ្នំពេញវិញ នៅខាងច្រាំងចំរេះអ៊ីចឹង។ បានត្រឡប់ពីច្រាំងចំរេះអ៊ីចឹងមក គេឱ្យមកនៅខាងក្រសួងពាណិជ្ជកម្មដែរ លីសែងនេះ នៅនឹងវត្តទួលទំពូងនេះតែម្តង។ ធ្វើជាកម្មករដែលថានិយាយចំពោះរូបខ្ញុំផ្ទាល់នេះ វានៅតែរ៉ៃសំឡីគនៅកណ្តាលវត្តនេះតែម្តង។

**ស៖** សូមអរគុណ។ យើងនឹងត្រឡប់មកនិយាយអំពីបញ្ហានេះ ក្រោយពេលសម្រាកថ្ងៃត្រង់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានសំណួរចុងក្រោយមុនពេលឈប់សម្រាក។ ពាក់ព័ន្ធនឹងសំណួរ១៣នេះដដែលក្នុងនោះ យើងនិយាយអំពីបញ្ញាជន នាយទុន អនុធន ព្រះសង្ឃ។ តើលោកអាចពន្យល់បានទេ ថាមេដឹកនាំវរសេនាតូចរបស់លោក ឬក៏មេដឹកនាំបក្ស គិតបែបណាចំពោះបញ្ញាជន នាយទុន អនុធន ហើយនិងចំពោះព្រះសង្ឃទាំងអស់នេះ? ខ្ញុំចង់ដឹងពីជំហររបស់ពួកគាត់ទៅលើអ្នកទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញមេធាវីជាតិការពារក្តីលោក ខៀវ សំផន។

[១២:០១:០៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ ដោយខ្ញុំគិតថា សាក្សីមិនអាចដឹង ថាតើមេវរសេនារបស់គាត់ក្នុងសម័យនោះ គិតពីអ្វីចំពោះអ្នកមួយនោះបានទេ។ ពីព្រោះលោកសាក្សីនេះមិនមែនជាវរសេនា ជាមេរបស់គាត់នោះទេ។ បាទ អ៊ីចឹងការឲ្យសាក្សីបញ្ជាក់ទៅលើគំនិតរបស់អ្នកដទៃ មិនគួរអាចធ្វើបានទេ ព្រោះវានាំឲ្យមានការសន្និដ្ឋាន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ ការជំទាស់នោះ មិនមានមូលដ្ឋានទេ ខ្ញុំនឹងរៀបចំសំណួរឡើងវិញ។

[១២:០១:៥៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** សំណួរខ្ញុំៗចង់ដឹងថាតើថ្នាក់លើផ្ទាល់របស់លោកមានបានប្រាប់លោកអំពីជំហរបដិវត្តន៍ ឬក៏ជំហររបស់បក្សបដិវត្តន៍ពាក់ព័ន្ធនឹងបញ្ញាជន អនុធន ពួកនាយទុន ហើយនិងព្រះសង្ឃ។ ព្រោះលោកបានឆ្លើយថា យោធា ហើយនិងកម្មករពិណជ្ជកម្មគឺជាមូលដ្ឋានបង្អែករបស់បក្ស។ ដូច្នេះ បើតាមមេដឹកនាំ មេរបស់លោកផ្ទាល់នោះ គឺថាបញ្ញាជន អ្នកនាយទុន អនុធន និងព្រះសង្ឃនោះ ក៏មានតួនាទីក្នុងសង្គមខ្មែរក្រហមដែរ ឬក៏យ៉ាងណា?

**លោក ស៊ឹម ហោះ**

**ឆ៖** ខ្ញុំសូមឆ្លើយទៅតាមការជាក់ស្តែង គឺក្នុងសម័យនោះ ចំពោះរបបនាយទុន អនុធន។ អនុធន បានន័យថា ចាប់ពីគ្រូបង្រៀនដែលជាអ្នកចេះដឹងជ្រៅជ្រះ ព្រមទាំងព្រះសង្ឃ គឺមិនអាចមានគ្រាន់តែដូច្នេះខ្ញុំនិយាយនេះគឺក្នុងន័យជាក់ស្តែងដែលនៅជាមួយយើងខ្ញុំមានគ្រូបង្រៀនមួយជាប្រធានកងតូចដែរ នៅក្នុងរបបដែលត្រូវបានឆ្នាំ៧៦ លីសែងនោះ។ ដល់ពេលអ៊ីចឹងទៅគេថាហៅទៅរៀន ដល់ទៅទៅបាត់ឈឹង អត់ឃើញត្រឡប់មកវិញ ខ្ញុំចេះតែឆ្ងល់។ បាទ អ៊ីចេះបានន័យថា ហើយសួរថា ហ៊ានទេ? អត់ហ៊ាននិយាយទេ គឺគោរពទៅតាមអង្គការវិន័យរបស់បក្សគេនោះ។ បាទ ខ្ញុំសូមជម្រាបដោយត្រង់ៗទៅបាទ។

[១២:០៤:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណលោក ស៊ឹម ហោ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយលោក ស៊ឹម ហោ ដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ លោកនៅបន្តធ្វើផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅរសៀលនេះទៀត។

បាទ ហើយឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬទីកន្លែងណាមួយសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅម៉ោងមួយសាមសិបនាទី ហើយអញ្ជើញមេធាវីប្រឹក្សាសាក្សីដូចគ្នាជាមួយនឹងសាក្សីដែរ។

ហើយបង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

អរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន បាទ ខ្ញុំនឹងសួរទៅដល់ពេលសម្រាករសៀលនេះ។ ហើយខ្ញុំនឹងមើលថា តើពេលហ្នឹងខ្ញុំអាចសួរចប់ ឬក៏សុំ១០នាទីបន្ថែម ហើយដឹងថាខាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពី៣០ ទៅ៤០នាទី។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសូមចោទសំណួរពីរបីសំណួរទាក់ទងនឹងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងអ្វីដែលកើតឡើងនៅថ្ងៃនុំង។ លោកបាននិយាយទៅចៅក្រមស៊ើបអង្កេតថា លោកបានចូលមកភ្នំពេញប្រហែលជា៣ថ្ងៃក្រោយពេលដែលរំបែកភ្នំពេញហើយ។ តើត្រឹមត្រូវដែរឬទេ?

[១៣:៣៤:០៨]

**លោក ស៊ឹម ហោះ៖**

**ឆ៖** បាទ សូមអរគុណ។ សូមជម្រាបប្រសាសន៍ថា រយៈពេល៣ថ្ងៃក្រោយរំដោះទីក្រុងភ្នំពេញមក ពិតជាត្រឹមត្រូវមែនអ៊ីចឹងឯង ចូលមកបាទ។

**ស៖** ហើយនៅពេលនុំង តើលោកបានទៅចូលកងវរសេនាតូចរបស់លោកនៅភ្នំពេញដែរឬទេ?

**ឆ៖** ពេលនោះ គឺថាក្រោយមកគឺគេបានប្រមូលគ្នាមកជួបជុំនៅម្តុំគីឡូលេខ៦បាទ ច្រាំងចំរេះ ជួបជុំ ធ្វើមីទ្ទីងអបអរសាទរ ថាជ័យជម្នះអីហ្នឹងបាទ។

**ស៖** បាទ អរគុណ។ តើនៅពេលនោះលោកនៅជាមួយ សួនរី ដែរឬទេ? សួនរី គឺជា អ្នកដែលលោកស្គាល់។ តើលោកនៅជាមួយ ជួនរី ទេនៅពេលហ្នឹង?

**ឆ៖** សូមអភ័យទោស ស្តាប់អត់បានមិនសូវច្បាស់។ សូមលើកសាថ្មីទៀតខ្ញុំស្តាប់មិនបាន។

**ស៖** តើនៅពេលដែលគេប្រារព្ធជ័យជម្នះនៅគីឡូលេខ៦នោះ តើអនុវរសេនាតូចរបស់លោកនោះលោកនៅជាមួយ សួនរី ទេ?

**ឆ៖** សួន រ៉ី ឬ សួន រី ខ្ញុំដូចអត់ច្បាស់ត្រង់នេះ?

[១៣:៣៦:៤១]

**ស៖** ខ្ញុំមិនប្រាកដថាខ្ញុំអានឈ្មោះនេះច្បាស់ទេ ក៏ប៉ុន្តែខ្ញុំគិតថាប្រហែលជា សួន រ៉ី ទេ ព្រោះ សួន រ៉ី ទេ ហើយឈ្មោះហៅក្រៅហ្នឹង ខាន់។

**ឆ៖** បាទ បញ្ជាក់ច្បាស់បាទ អរគុណ។ ត្រូវ នៅជាមួយគ្នាបាទ។

**សៈ** អ៊ីចឹងនៅគីឡូម៉ែត្រ៦ហ្នឹង តើលោកមានបានឃើញប្រជាជនដែលចាកចេញពីទីក្រុងភ្នំពេញ ដែលឆ្លងកាត់តាមកន្លែងដែលលោកនៅគីឡូម៉ែត្រលេខ៦ ហ្នឹងដែរឬទេ?

**ឆៈ** បាទ ក្នុងនោះចាប់ពីក្រោយរំដោះឆ្នាំ៧៥ ៧មករា គេមកគឺប្រជាជនដែលនៅក្នុងទីក្រុងភ្នំពេញគឺបានជម្លៀសចេញតាមផ្លូវជាតិលេខ៦, លេខ៥ ជាបន្តបន្ទាប់ដែរ ឃើញ។

**សៈ** តើលោកឃើញអ្នកដែលគេជម្លៀសហ្នឹងដើរនៅតាមផ្លូវដែលលោកនៅហ្នឹងនៅគីឡូម៉ែត្រលេខ៦ហ្នឹង លោកមានបានឃើញប្រជាជនជម្លៀសចេញទេ?

[១៣:៣៨:២០]

**ឆៈ** បាទ ខ្ញុំឃើញគេជម្លៀសចេញ ប្រជាជនបានដើរជាបន្តបន្ទាប់ចេញទៅ។

**សៈ** តើសមាជិកវរសេនាតូចលោកហ្នឹង ត្រូវទទួលបន្ទុកសួរចម្លើយអ្នកដែលគេជម្លៀសចេញ ដើម្បីនេះសម្រាំងយកអ្នកដែលជាអតីតទាហាន លន់ នល់ ឬក៏អតីតអ្នករដ្ឋការជាដើមនោះ?

**ឆៈ** អត់បានដឹងផងត្រង់នោះបាទ ឃើញតែចេញបន្តបន្ទាប់ តែត្រង់គេធ្វើសកម្មភាពទៅលើពលរដ្ឋនោះគឺខ្ញុំមិនបានដឹង ឃើញតែចេញ។

**សៈ** បាទ ខ្ញុំសូមប៉ុនប៉ងសួរសំណួរនេះម្តងទៀត។ ខ្ញុំសូមអានផ្នែកមួយនៃចម្លើយរបស់ សួន រ៉ុ ដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលចុះថ្ងៃទី០២ កុម្ភៈ ឆ្នាំ២០០៣ ដែលមានលេខឯកសារហ្នឹងគឺ ES19.192 ហើយសម្រង់ដែលខ្ញុំចង់អាននេះមានលេខ ERN ជាភាសាខ្មែរគឺថាទំព័រ 0055290 រហូតដល់ 293, ជាភាសាអង់គ្លេសគឺទំព័រ១៨ និង១៩, ជាភាសាបារាំង គឺទី១៤ ដល់១៥ នៅក្នុងឯកសារហ្នឹង។

បាទ ខ្ញុំមិនសូមបញ្ចាំងឯកសារទៅអេក្រង់ទេ ព្រោះគាត់មិនបានអានឯកសារនេះទេ។ ហើយខ្ញុំគ្រាន់តែសុំឲ្យគាត់ធ្វើការកត់សម្គាល់នៃ -- ទៅលើខ្លឹមសារដែល សួន រ៉ុ បាននិយាយនេះ។

“សំណួរ៖ តើទាហានលន់ នល់ នុំងត្រូវបានលាក់បាំងខ្លួនដែរឬទេ? ចម្លើយ៖ បាទនុំងហើយ គឺដោយសារតែគេមិនបានស្លៀកឯកសណ្ឋានគេទេ គេស្លៀកពាក់ជាស៊ីវិល។ អ៊ីចឹងគេចូលឡូកឡំទៅអស់ទៅក្នុងហ្វូងមនុស្ស។ សំណួរ៖ តើគេអាចស្គាល់ពួកហ្នឹងបានទេ? ចម្លើយ៖ បាទ មិនអាចស្គាល់ទេ ក៏ប៉ុន្តែនៅក្នុងនោះគេសួរខ្លះមានចំទាហាន គេសង្ស័យ។ ធម្មតា អ្នកធ្លាប់ធ្វើទាហាន និងប្រជាជន។ កាលណាគេសង្ស័យគេសួរ ឧទាហរណ៍គេសួរពួកកុម្មង់ដូជាដើម។ សំណួរ៖ នៅពេលខ្មែរក្រហមជួបពួកទាំងអស់ហ្នឹង ដូចពួកកុម្មង់ដូ ហើយពួកអតីតទាហាន លន់ នល់ អីហ្នឹង ខ្មែរក្រហមហ្នឹងគេធ្វើយ៉ាង

ម៉ែច? ចម្លើយ (របស់ សួន រ៉ី)៖ កាលណោះគេចាប់ចេញ នៅពេលដែលជាទាហាន លន់ នល់ នោះគេដកចេញដាច់ខាតតែម្តង ហើយគេមិនឱ្យចូលឡូកឡំជាមួយប្រជាជនទេ។ ហើយបន្ទាប់ទៀត គេប្រមូលពួកហ្នឹងនៅម្តុំ ហើយចាំសិន ហើយខ្ញុំឃើញព្រឹត្តិការណ៍ទាំងអស់នេះនឹងភ្នែកខ្ញុំ"។ ខ្ញុំបញ្ចប់ការដកស្រង់។ នេះគឺជាផ្នែកមួយនៃកិច្ចសម្ភាសន៍របស់លោក សួន រ៉ី។

[១៣:៤២:១២]

បាទ លោកសាក្សី លោកបានទៅកងវរសេនាតូចរបស់លោកក្រោយគេ។ តើលោកបញ្ជាក់ថា លោកមិនបានឃើញគេការ -- ដកទាហាន លន់ នល់ ចេញពីប្រជាជនដែរឬទេ? ហើយការដកទាហាន លន់ នល់ ចេញនេះមិនត្រូវបានធ្វើដោយសមាជិកនៃអង្គភាពលោកដែរឬក៏អត់ទេ? លោកនៅតែរក្សាចម្លើយថាលោកអត់បានដឹង ឬអត់បានឃើញ?

**ឆ៖** បាទ ឃើញតែគេជម្លៀសឱ្យចេញទៅក្រៅក្រុង តែត្រង់គេកាត់ដូចថា ដូចលោកបានលើកអំពីការសម្ភាសពីលោក សួន រ៉ី អ៊ីចេះ គឺខ្ញុំអត់បានដឹង។ ត្រង់បែងចែកថា ដកទាហាន ដោយឡែកពលរដ្ឋដោយឡែក អានុ៎ងខ្ញុំមិនបានដឹង ព្រោះអីខ្ញុំក្រោយរំដោះនោះទៅ គេទៅយកពីក្រោយគេទេ បានទៅដល់កន្លែងនោះបាទ។ គ្រាន់តែឃើញគេចេញ។

**ស៖** បាទ សូមអរគុណ។ ឥឡូវចូលទៅនិយាយរយៈកាលមួយទៀត គឺថារយៈកាលដែលលោកធ្វើការនៅខាងពាណិជ្ជកម្ម។ ខ្ញុំសូមត្រឡប់មកនិយាយអំពីប្រវត្តិរូបរបស់លោក លេខកូដ គឺ 19.177 មានកាលបរិច្ឆេទសរសេរនៅលើហ្នឹងថ្ងៃទី១៥ ឧសភា ឆ្នាំ១៩៧៥ លោកជាកម្មករនៅកំពង់សោម អង្គភាពពាណិជ្ជកម្ម។ ជាភាសាបារាំងគឺ មានសរសេរថ្ងៃទី១៥ មីនា ឆ្នាំ៧៥ ប្រហែលជាការភ័ន្តច្រឡំទេ គឺថា ព្រោះថាសរសេរជាភាសាខ្មែរថ្ងៃទី១៥ ឧសភា ឆ្នាំ៧៥ ហើយនៅក្នុងការបកប្រែជាភាសាបារាំងនេះ ពាក្យថា កំពង់សោម អត់មានឃើញទេ។

លោកសាក្សី ម្សិលមិញលោក -- អម្បាញ់មិញលោកបាននិយាយថា លោកធ្លាប់ធ្វើការនៅកំពង់សោម ហើយមានសរសេរនៅក្នុងប្រវត្តិរូបរបស់លោកគឺថា លោកចូលនៅថ្ងៃទី១៥ ឧសភា ឆ្នាំ៧៥ នេះ តើនេះពិតជាព័ត៌មានត្រឹមត្រូវដែរឬទេ?

[១៣:៤៤:៤០]

**ឆ៖** បាទ ការដែលផ្តល់ចម្លើយនៅក្នុងសំណួរទាំងអស់នោះ គឺវាមិនបានគ្រប់លក្ខណៈក៏ពិតមែន ប៉ុន្តែដោយឡែកខ្ញុំចង់បញ្ជាក់អំពីការពិតរបស់យើងខ្ញុំដែលបានទៅនៅកន្លែងនោះ កំពង់សោមបានរយៈ

ពេល១ឆ្នាំ ទៅពី៧៥ ដូចលោកលើកអ៊ីចេះដែរ ប៉ុន្តែបាន១ឆ្នាំ រយៈពេលឆ្នាំ៧៦បញ្ជូនត្រឡប់មកវិញមួយចំនួន។ គេកាត់ទុកនុំងមួយចំនួន។

**ស៖** ក្រោយពេលដែលគេបញ្ជូនលោកទៅកំពង់សោមនោះ លោកធ្វើការនៅកំពង់សោមនោះជាទាហាន ឬក៏ជាជនស៊ីវិលនៅក្នុងមន្ទីរពាណិជ្ជកម្មនៅកន្លែងនោះ? ផ្នែកមួយ អង្គភាពពាណិជ្ជកម្មនៅកំពង់សោមហ្នឹង?

**ឆ៖** បាទ ដែលរស់នៅទីក្រុងកំពង់សោមហ្នឹងគឺធ្វើការជាកម្មករបាទ លីសែងៗ ហើយការរស់នៅឃ្លាំងលើ តែដល់ធ្វើការចេញពីកន្លែងឃ្លាំងលើទៅ គេដឹកឡានបញ្ជូនទៅកំពង់ផែកំពង់សោមសមុទ្រ។ ចេះដូរជាវេនគ្នា វាវិលទៅបាទ គឺថាវិល។ គឺថាចូលម៉ោងប្រាំពីរព្រឹកអ៊ីចេះ ដល់ម៉ោងដប់មួយអ៊ីចេះយើងត្រូវគេដូរ ដូរវិលតែម្តង វិលជុំ។ វេនធ្លាក់ដល់ទៅយប់ទៀតទៅ ក៏វាដូរគ្នា វាទៅជាវិល។

[១៣:៤៦:២៨]

**ស៖** បាទសូមអរគុណ។ នៅទំព័រទី២ជាភាសាខ្មែរនៃឯកសារ E3/363 ទំព័រទី១ជាភាសាខ្មែរ, ទី២ ជាភាសាបារាំង, អង់គ្លេសទំព័រទី៣។ “នៅពីដើមយើងទទួលបន្ទុកខាងជញ្ជូនស្រូវចេញពីកប៉ាល់ចិន ហើយខ្ញុំសូមបញ្ជាក់ថាកាលនោះមានកប៉ាល់ចិននេះមានខាងលើមានរថយន្តចំនួន៩០ ហើយចំណែកខាងក្នុងកប៉ាល់មានផ្ទុកអង្ករ ហើយនិងគ្រឿងសម្ភារៈផ្សេងៗ ដូចជាចប ប៉ែល ថ្នាំសម្លាប់សត្វល្អិតជាដើម”។ បើសិនជាខ្ញុំមិនច្រឡំទេ លោកនិយាយទៅកាន់ចៅក្រមស៊ើបអង្កេតថា ក្រោយពីជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយនិងទីក្រុងផ្សេងទៀត គឺថាមានការទម្លាក់ស្រូវចេញពីកប៉ាល់ចិន សែង ឬទម្លាក់ចេញ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អង្ករទេ សូមអធ្យាស្រ័យ មិនមែនស្រូវទេ បញ្ចេញអង្ករមក ហើយរបស់ផ្ទុកនៅខាងក្រោមនោះដូចបានលើកឡើងអ៊ីចេះ មានសម្ភារៈផ្សេងៗគ្រប់មុខទាំងអស់ហើយបាទ។ ចប ប៉ែល ស្អីៗទៅ ថ្នាំអីដូចការលើកឡើងអ៊ីចេះត្រឹមត្រូវហើយបាទ។ ហើយខាងលើផ្ទុកឡានច្រើនមែន ឡានវាកូរ៉េតូចៗនោះ ៩០គ្រឿង អាកប៉ាល់វាធំណាស់អានោះ គិតទៅវា១៣០ម៉ែត្របណ្តោយវា។ ខ្ទងលើអ៊ីចេះដល់ពេលយោងឡានទម្លាក់ចុះអស់ទៅ បានបើកឃ្លុបឡើង មានប្រដាប់យោងគេមកដាក់ឡានទៅ កម្មករយើងអូសទាញមកដាក់ឃ្លាំងគេនៅមាត់សមុទ្រហ្នឹងដែរបាទ។

[១៣:៤៨:២៥]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកនៅកន្លែងនុំង ជាមួយនឹងនៅកងវរសេនាតូច

នោះ តើមានការចាប់ខ្លួនមនុស្សអីទេ នៅពេលដែលលោកធ្វើការនៅកំពង់ផែកំពង់សោមនោះ?

**ឆ៖** បាទ កាលដែលនៅកំពង់ផែកំពង់សោម ខ្ញុំដូចជាវាខាងក្រោមអត់ទាន់ដឹងថាគេមានចាប់ទេកន្លងទៅ។ ឃើញតែធ្វើការធម្មតា លីសែងទៅមកអ៊ីចេះ។ ដូរវេនគ្នាដូចខ្ញុំបានជម្រាបប្រាប់ខាងដើមអ៊ីចឹង។

**ស៖** តើ តាបេង នោះនៅតែជាប្រធានរបស់លោកទេ? ឬក៏ចន្លោះពី៧៥-៧៦ នោះ ពេលលោកនៅកំពង់សោមនោះ មានការផ្លាស់ប្តូរមេលោកទេ មេឬប្រធានលោកទេ?

**ឆ៖** បាទ បើនិយាយទៅ តាបេង នេះគឺមានការផ្លាស់ប្តូរបាទ។ ព្រោះតាំងពីរំដោះឆ្នាំ៧៥ ហើយដែលបញ្ជូនទៅកំពស់សោម អានោះគេរវសេនាតូចផ្សេង ដោយឡែក គេឡើងផ្សេងទៅទៀត។ តាបេង ហ្នឹងគេមិនដឹងជាបញ្ជូនទៅខាងណា កាន់ខាងណាក៏អត់ដឹងដែរបាទ។

[១៣:៥០:០១]

**ស៖** បាទឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈពេលដែលលោករស់នៅក្បែរភ្នំពេញម្តង បើតាមរប្រវត្តិរូបរបស់ហ្នឹង លោកត្រឡប់មកថ្ងៃទី២៨ ឧសភា ឆ្នាំ១៩៧៦ ហើយជាការត្រឹមត្រូវដែរឬទេដែលថាលោកធ្វើការនៅកន្លែងមួយចំនួនផ្សេងគ្នានៅភ្នំពេញមុនគេ ហើយបន្ទាប់ទៀតទៅគីឡូម៉ែត្រលេខ៦ ឬក៏ច្រាំងចំរេះ ហើយនិងនៅទួលទំពូងផងដែរ។ តើលោកធ្លាប់បានធ្វើការនៅតាខ្មៅដែរឬទេ នៅពេលណាមួយ?

**ឆ៖** បាទអ៊ីចេះ មុនដំបូងកាលពីត្រឡប់ពីខេត្តកំពង់សោមមកនៅទីក្រុងភ្នំពេញ មុនដំបូងគេឲ្យធ្វើការនៅម្តុំច្រាំងចំរេះ មកលីសែងនៅគីឡូលេខ៦ កន្លែងដែលយើងចូលហ្នឹង ជាអង្ករ ជាស៊ីម៉ង់ត៍ចេញពីរទេះភ្លើងដាក់ឡានទៅមក ចេញចូល។ បានក្រោយមកទៅ គេផ្លាស់ប្តូរឲ្យខ្ញុំទៅនៅទឹកខ្មៅបានមួយរយៈ។ ក្រោយមកបានត្រឡប់មកនៅទួលទំពូងនេះវិញបាទ នៅម្តុំវត្តទួលទំពូង។

[១៣:៥១:២៨]

**ស៖** តាមប្រវត្តិរូបហ្នឹង ថាក្រៅពីទឹកខ្មៅ លោកត្រឡប់មកគីឡូម៉ែត្រលេខ៦វិញ ហើយមានសរសេរថាថ្ងៃទី១៥ មីនា ឆ្នាំ១៩៧៧ ហើយបន្ទាប់មកទៀត ថ្ងៃទី២៨ ឧសភា ឆ្នាំ១៩៧៧ មកក-៥១ តើលោកធ្លាប់ធ្វើការនៅច្រាំងចំរេះ ក្រោយពីធ្វើការនៅតាខ្មៅហើយ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចេះធ្វើការច្រាំងចំរេះមុន បានត្រឡប់ទៅនៅតាខ្មៅ។

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីការដែលលោកត្រូវលីសែងអង្ករ ហើយនិងស៊ីម៉ង់ត៍

នៅច្រាំងចំរេះ ខ្ញុំសួរថា តើអង្ករដែលលោកជញ្ជូនដាក់រទេះភ្លើងនោះត្រូវដឹកជញ្ជូនទៅឲ្យអ្នកណាដើម្បីឲ្យប្រើប្រាស់នៅប្រទេសកម្ពុជា ឬក៏ដើម្បីនាំចេញទៅក្រៅប្រទេស?

**ឆ៖** បាទអរគុណ។ អង្ករ ស៊ីម៉ងត៍ គឺគេមិនដឹងដឹកមកពីណាទេ ប៉ុន្តែលីចេញពីរទេះភ្លើងមកដាក់ស្តុបនឹងឃ្លាំងហ្នឹងទៅ។ ហើយអង្ករចេញពីកន្លែងដែលគេកិនម៉ាស៊ីនធំផលិតនោះ តាមកន្លែងគឺត្រូវចេញទៅក្រៅ តាមហ្នឹងទៅ។ ខ្ញុំទៅដល់លីដាក់ឡាន ដាក់រទេះភ្លើង ផលិតចេញទៅក្រៅ។ ព្រោះគេសម្រាំងយកល្អ អាណាបាក់គេថាលេខ២ទៅ អាណាល្អ លេខ១អ៊ីចេះទៅ។ ខ្ញុំមិនដែរ ខ្ញុំតែដឹងធ្វើការអូសទាញ លីសែង។

[១៣:៥៣:៤៣]

**ស៖** ហើយនៅពេលដែលលោកនៅច្រាំងចំរេះនោះ តើលោកគ្រាន់តែជាកម្មករលីសែងដូចនៅកំពង់សោមដែរ ឬក៏កាលនុ៎ះ គឺថាលោកមានតំណែងផ្សេងហើយ។ លោកក្លាយជាប្រធានក្រុមមានមនុស្សច្រើននាក់នៅក្រោមបញ្ជារបស់លោក?

**ឆ៖** បាទនៅជាកម្មករ ជាកម្មករលីសែងដូចគ្នាដែរបាទ ខ្ញុំ។

**ស៖** ខ្ញុំសូមអានសម្រង់មួយទៀតនៃចម្លើយរបស់កំណត់ហេតុស្តាប់ចម្លើយរបស់ គឺថាឯកសារ E3/363 ទំព័រ៣ និង៤ជាភាខ្មែរ, ទំព័រទី៤ជាភាសាបារាំង ហើយនិងទំព័រ៣, ៤ជាភាសាអង់គ្លេស។ គឺជាផ្នែកមួយដែលនិយាយពីការចាប់ខ្លួនមនុស្ស។ បាទលោកនិយាយយ៉ាងដូច្នេះ។

សំណួរទី១៖ “គឺថានៅច្រាំចំរេះ តើមានការចាប់ខ្លួនមនុស្សដែរ ឬទេ?” លោកឆ្លើយថា “បាទមានការចាប់ខ្លួន គេនិយាយ -- គេប្រាប់ទៅមេ ឬក៏អនុប្រធានអីអ៊ីចឹង អនុប្រធានកងវរសេនាតូច ហើយប្រធានអនុសេនាធំ ហើយបន្ទាប់មកទៀត ប្រធានកងតូចៗ ក្នុងចំណោមអ្នកទាំងអស់នោះ មិនបានឃើញអ្នកណាត្រឡប់មកវិញទេ បាត់ខ្លួនរហូត ហើយក្រោយមកនៅសល់តែប្រធានក្រុម ហើយនិងកម្មករធម្មតា ដែលក្រោយមកគេកោះហៅទៅប្រជុំនៅជិតវត្តភ្នំ...” ហើយលោកបន្តទៀតថា “បន្ទាប់ពីការចាប់តាំងប្រធានក្រុមថ្មីនោះ យើងនៅម្តុំក្បែរផ្សារចាស់ ក៏ប៉ុន្តែយើងធ្វើការនៅគីឡូម៉ែត្រ៦ដដែល”។ បាទ សូមបញ្ចប់ការដកស្រង់។

ការចាប់ខ្លួនប្រធាននៅថ្នាក់ក្រោមតូចៗនៅច្រាំចំរេះនេះ តើការចាប់ខ្លួនទាំងអស់នេះ ធ្វើឡើងមុនកិច្ចប្រជុំមួយដែលថា គេប្រកាសក្បត់របស់ ធុច កិច្ចប្រជុំនោះនៅក្បែរវត្តភ្នំ។ អ៊ីចឹងមែនទេ ការចាប់ខ្លួននោះ កើតក្រោយទេ -- មុនៗកិច្ចប្រជុំហ្នឹងទេ?

[១៣:៥៦:៣៨]

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះកន្លងទៅ ចាប់ពីធំ កងធំ កងតូចអ៊ីចេះ ចេះតែប្រមូលហៅទៅរៀន១ហ្នឹង គេថាទៅរៀនរៀបចំទៅ ទៅបាត់ទៅ អត់មានត្រឡប់អ៊ីចេះទៅ ស្រាប់អស់ទៅ វានៅកម្មករសុទ្ធសាធទៅ បានគេប្រមូលយកឡានដឹកយកមកវត្តភ្នំអ៊ីចេះមែន មករៀបចំឯក្រោមកងអី អនុសេនាតូចសាឡើងវិញ សម្រាប់កម្មករធ្វើការងារបន្តទៀត បាទ។ ចុះមែនហ្នឹងឯង។

**ស៖** សូមអរគុណ។ តើគេមានប្រាប់ថា ហេតុអីបានជាប្រធាន១របស់លោកនោះ ប្រធានកងអនុសេនាតូច អនុសេនាធំអី កងវរសេនាតូចហ្នឹង ត្រូវបានគេចាប់ខ្លួន។ គេមានប្រាប់មូលហេតុនៃការចាប់ខ្លួនអ្នកទាំងអស់ហ្នឹងទេ?

**ឆ៖** ក្នុងពេលប្រជុំរៀបចំឯជាក្រុម ជាកងអនុសេនាតូចសម្រាប់គ្រប់គ្រងកម្មករលីសែងបន្តទៅទៀតនោះ គេបានប្រាប់ដែរ គេថា "លោក កុយ ធួន ហៅ ធុច ហៅ ឃួន នេះ ជាអ្នកក្បត់នៅក្រសួងពាណិជ្ជកម្ម"។ អ៊ីចេះ ដើម្បីថាអ្នកខាងក្រោមគេមិនបានប្រកាសទេ ប៉ុន្តែគេថា ជាបណ្តាយរបស់ កុយ ធួន នេះឯង បានត្រូវគេដកចេញឲ្យអស់។

[១៣:៥៨:២៤]

**ស៖** តើការប្រជុំដែលលោកបានលើកឡើងអម្បាញ់មិញនេះ ទាក់ទងតែអ្នកដែលធ្វើការនៅក្រសួងពាណិជ្ជកម្មទេ ហើយខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំហ្នឹង? ហើយអ្នកណាជាអ្នកនិយាយពី កុយ ធួន នៅពេលនោះ នោះ?

**ឆ៖** បាទ អង្កាល់នោះ មានឈ្មោះ តារិទ្ធ។ បាទ ផ្លាស់មកពីភូមិភាគនិរតីនោះ ទទួលបន្ទុក។ ដែលថាខាងពាណិជ្ជកម្មក្នុងប្រទេសហ្នឹងឯង បានមកប្រជុំរៀបចំហៅថាក្រុម កង អនុសេនាតូច ដើម្បីគ្រប់គ្រងកម្មករ រស់នៅដែលនៅជិតវត្តភ្នំផ្សារចាស់នេះឯង ប៉ុន្តែធ្វើការនៅគីឡូ៦ ដដែល ដូចនៅលើដែល ខ្ញុំចាំមិនបានអស់ បាទ។

**ស៖** តើនៅក្នុងពេលប្រជុំហ្នឹង នៅពេលដែលគេប្រកាសថា កុយ ធួន ជាជនក្បត់នោះ តើគេមានបាននិយាយពីអ្នកផ្សេងទៀតទេ? អ្នកផ្សេងទៀត ដែលកាន់តំណែងភូមិភាគខាងជើង -- ភូមិភាគឧត្តរ បាទ សូមទោស មានទេ គេមាននិយាយទេ?

**ឆ៖** ដូចមិនឮនិយាយ និយាយតែខាងក្រោមនោះទេ ក្រោម កុយ ធួន ទៅ មាននិយាយតែចំពោះស្ទីលោក អឿន អ៊ីចេះឯង មេកងពលគេ។ កងពលធំគេនៅក្នុងភូមិភាគហ្នឹងបាទក្រោមបញ្ជាការ

ការគ្រប់គ្រងទូទាំងប្រទេស។ គេហៅ លោក អឿន អ៊ីចេះឯង កងពលធំហ្នឹងបាទ។ ហើយក្រៅពីនោះ បើថ្នាក់ទៅវិញ ខ្ញុំអត់ដឹងទេ គ្រាន់តែគេនិយាយថា គេហៅ បងលេខ១, លេខ២ មិនដឹងនរណាគេ អត់បញ្ចេញឈ្មោះផងឆ្នាំនោះឯង ដែលប្រជុំរៀបចំ។ គេនិយាយថា បងលេខ១, លេខ២ ប៉ុណ្ណឹងមិនដឹង នរណា ខ្ញុំអត់ដឹងបាទ។

[១៤:00:៥២]

**ស៖** បាទ ដើម្បីឲ្យច្បាស់ជាងនេះនៅចម្លើយដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ គឺលោកនិយាយពីកិច្ចប្រជុំនោះដូចតទៅនេះ បាទ ខ្ញុំសូមដកស្រង់ពាក្យសម្ដីរបស់លោក ជាភាសាខ្មែរគឺ 00236033 គឺនៅក្នុងកំណត់ហេតុដែលគឺ E3/363, ជាភាសាបារាំងទំព័រទី៤, អង់គ្លេសក៏ទំព័រទី៤ ដែរ។ លោកបាននិយាយអំពី តាវិទ្ធ លោកនិយាយថា៖

"នៅក្នុងនេះគាត់និយាយថា កុយ ធួន ហៅ ឃួន ជាលេខាភូមិភាគឧត្ដរ ហើយនិងរដ្ឋមន្ត្រីក្រសួងខាងពាណិជ្ជកម្មខាងក្រៅហ្នឹងជាប់ពាក់ព័ន្ធនឹង សេ.អ៊ី.អា ហើយគេមានគម្រោងធ្វើរដ្ឋប្រហារ ដើម្បីផ្ដួលរលំបងលេខ១ និងបងលេខ២។ មេកងទ័ព -- កងពលភូមិភាគឧត្ដរឈ្មោះ អឿន ជាអ្នកបញ្ជាកងទ័ពដើម្បីរដ្ឋប្រហារនោះ ក៏ប៉ុន្តែពួកគេទាំងអស់ត្រូវបានចាប់ជាបន្តបន្ទាប់"។ សូមបញ្ចប់ការដកស្រង់។ ពេលលោកនិយាយពីបងទី១ បងទី២ នេះតើលោកនេះលោករក្សាចម្លើយរបស់លោកគឺថា វិទ្ធ បានអះអាងថា កុយ ធួន នេះមានគម្រោងធ្វើរដ្ឋកប្រហារប្រឆាំងនឹងបងទី១ បងទី២ អ៊ីចឹងមែនទេ លោករក្សាចម្លើយហ្នឹង?

**ឆ៖** បាទៗ ដូចលោកបានលើកឡើង ខ្ញុំមិនអាចចាំបាននអស់ទេ និយាយសាដើមវិញត្រឹមត្រូវ ហើយអ៊ីចុះឯង ចង់ធ្វើរដ្ឋប្រហារអ៊ីចឹងហើយ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំចង់ដឹងថា តើ វិទ្ធ បាននិយាយពីការក្បត់របស់ កុយ ធួន នេះ នៅពេលណា? ហើយតើគេមានបាន -- គាត់មានបាននិយាយថា កុយ ធួន បានសារភាពអំពីគម្រោងធ្វើរដ្ឋប្រហារនេះដែរឬទេ?

[១៤:0២:៥៨]

**ឆ៖** អរគុណ។ សូមទោសត្រង់កន្លែងនេះ ខ្ញុំមិនអាចធ្វើអត្ថាធិប្បាយបានដោយចាំអស់បាទ គ្រាន់តែដឹងតែចំណុចៗប៉ុណ្ណោះឯង ដែលបានលើកឡើងបាទ។

**ស៖** បាទ សូមអរគុណ អត់បញ្ហាអីទេ។ តើនៅអង្គាល់នោះលោកដឹងទេ នៅពេលដែល តាវិទ្ធ

និយាយថា កុយ ធួន ហៅ ធុច ហ្នឹងជាប់ពាក់ព័ន្ធនឹងសេ.អ៊ី.អា?" អង្គាល់ហ្នឹងលោកយល់ទេន័យយ៉ាងម៉េចដែរ ពេលថាជាប់ សេ.អ៊ី.អា ហ្នឹងលោកយល់ទេ តើមានន័យយ៉ាងម៉េចនៅសម័យខ្មែរក្រហម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់សំណួរនេះ ដោយហេតុថាសំណួរនេះក្រៅវិសាលភាពនៃសវនាការសម្រាប់ពេលនេះ។ សូមអរគុណលោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ខ្ញុំគិតថាការជំទាស់នេះពុំមានមូលដ្ឋានអ្វីទេ មួយគឺថាយើងនិយាយពីក្រសួងពាណិជ្ជកម្ម ហើយអ៊ីចឹងយើងដឹងថាក្រសួងហ្នឹងវាមានជាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទដល់កម្រិតណា។ ហើយមួយទៀត យើងនិយាយអំពីនយោបាយ និងនយោបាយខ្លាំង ហើយខ្ញុំសូមរំឭកផងដែរគឺថា រស់ ស៊ុយ គាត់បាននិយាយអំពីបញ្ហានេះដែរនៅក្នុងសាលសវនាការ។ អ៊ីចឹងឈរលើមូលហេតុទាំងអស់នេះ ខ្ញុំគិតថាការជំទាស់របស់សហភាតារបស់ខ្ញុំគ្មានមូលដ្ឋានអីទេលោកប្រធាន។

[១៤:០៤:៥៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់និងសំអាងហេតុ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោកនួនជាចំពោះសំណួរនេះគឺមិនសមស្របទេ។ ដូច្នេះសេចក្តីជំទាស់ហ្នឹងគឺគ្មានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះបើសិនជាលោកនៅចាំ។ សូមលោកឆ្លើយសាក្សី។

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ ក្នុងសំណួរនេះខ្ញុំមិនដឹងថាយ៉ាងម៉េចទេ? តែគ្រាន់តែការលើកឡើងរបស់លោក រិទ្ធ នោះឯងគ្រាន់តែថា កុយ ធួន នេះជាខ្សែបណ្តាញរបស់ សេ.អ៊ី.អា គឺអាមេរិកាំង អ៊ីចេះ គេនិយាយអ៊ីចេះ ខ្ញុំអត់ដឹងថាខ្សែខាងណាខាងណី គឺមិនដឹងទេព្រោះជាសាមញ្ញបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ សូមអរគុណ។ ពេលក្រោយមកទៀតនៅក្នុងអង្គភាពរបស់លោកបន្ទាប់ពីមានការប្រកាសថា កុយ ធួន ជាជនក្បត់ ហើយ អឿន ក៏ជាជនក្បត់ដែរ។ តើមានបរិយាកាសភ័យខ្លាចដែរឬទេនៅក្នុងអង្គភាពរបស់លោក?

[១៤:០៧:២៦]

**ឆ៖** បាទ សូមជម្រាបលោកប្រធានឲ្យបានច្បាស់ថា ការភ័យខ្លាចនេះគឺមានតែក្នុងសម័យសង្គមនោះគឺយើងមិនអាចគេចវេះនឹងឆ្លើយតបការពិតពេនយ៉ាងម៉េចបាន។ ដូច្នេះគឺចេះតែទ្រាំ នឹងរត់គេចគេចមិនរួចដែរ។ អ៊ីចេះចំពោះរឿងខ្ញុំបាទជំនុំគ្នាមិនមែនថាម៉េចទេ និយាយត្រង់ៗរកច្រករត់ តែដល់គិតពិចារណាថា នឹងរត់ទៅឆ្លងប្រទេសមិនដឹងជាទៅដល់ណា? ព្រោះចេញពីកន្លែងនេះ ដល់កន្លែងនោះ គេតែអត់ស្គាល់គេដាក់គុក។ អ៊ីចេះទ្រាំ បាទ ទាល់តែដល់ថ្ងៃរំដោះ។ អ៊ីចឹងទៅបានដឹងថា អូ! មានសភាពខុសគ្នាបាទ។ វាអត់មានសិទ្ធិសេរីភាពទេ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈកាលចុងក្រោយដែលលោកធ្វើការនៅក្រសួងពាណិជ្ជកម្មគឺថាលោកធ្វើការទៅដល់ពេលរបបនោះដួលរលំតែម្ដងគឺនៅទួលទំពូងកាលហ្នឹង។ លោកអាចជម្រាបជូនតុលាការបានទេ ថាលោកនៅទួលទំពូងនោះលោកកាន់តំណែងអ្វីដែរ? ហើយលោកធ្លាប់បានគេដំឡើងឋានន្តរសក្តិទេនៅពេលលោកធ្វើការនៅទួលទំពូងនោះ?

[១៤:០៨:១១]

**ឆ៖** បាទ ខ្ញុំមិនលាក់បាំង មានតំណែងគេឲ្យទទួលជាមេក្រុមដែរបាទកន្លងទៅ។ ធ្វើការក្រោមការគ្រប់គ្រងរបស់ថ្នាក់លើរបស់គេគឺយើងខ្ញុំសូមបកស្រាយនឹងនិយាយបញ្ចប់សេចក្តីរឿងដែលការរស់នៅក្នុងតំបន់ទួលទំពូងជាការងារសម្រិតសម្រាំង។ ចំពោះរឿងរូបខ្ញុំផ្ទាល់សម្រិតសម្រាំងសំឡីក ១ឆ្នាំទល់១ឆ្នាំព្រោះទូទាំងប្រទេស។ ដឹកពីភូមិភាគពាយ័ព្យតាមរទេះភ្លើងមួយខ្សែៗមកពីបូព៌ាដឹកមកតាមកប៉ាល់មកទាំងខ្សែ ហើយភូមិភាគឧត្តរនេះគឺឡានបាទ សុទ្ធតែឡានខ្សែជំនាន់នោះបាទ។ អ៊ីចឹងខ្ញុំនៅនឹងវត្តហ្នឹងឯង គេឲ្យមើលម៉ាស៊ីនដែលរើសំឡីកនេះបួនដប់គ្រឿង។ អ៊ីចឹងកាលណារើទៅការច្រករបស់ប្រជាពលរដ្ឋ ជួនកាលវាដោយថ្ម ឬកម្ទេចឈើថាព្រួសទៅជួនកាលបាក់ធ្មេញម៉ាស៊ីន។ ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ ក្នុង១ខែគេសម្រាក៣ថ្ងៃ។ ១០ថ្ងៃឈប់ម្តង គេត្រូវ -- លោក តារិទ្ធ នេះគាត់ជាប្រធានគ្រប់គ្រង

ខាងពាណិជ្ជកម្មក្នុងប្រទេសផង ក្រៅប្រទេសផង គាត់មកប្រជុំបាទ ប្រជុំផ្សព្វផ្សាយនិយាយថា "មិនលើកពីរឿងបាក់ទេ តែគ្រាន់ថាស្លាបព្រាមួយឲ្យតែបាក់ខ្លាំង គឺមិនទាន់អស់"។ អ៊ីចឹងអារម្មណ៍របស់យើងខ្ញុំមានការភ័យព្រួយមិនដឹងជាថ្ងៃណាទេដែលយើងអាចឆ្លងផុតពីអន្លង់ គេវាអត់រួចបាទ។ នេះបញ្ហាមួយ។

[១៤:១១:០៦]

បញ្ហាពីរទៀត ក្រោយមកប្រធានក្រសួងជានារីដែលមកពីខាងភូមិភាគនិរតីនោះបាទ ឈ្មោះ មិត្តថា អាយុ១៨ឆ្នាំ ទើបតែបានកូនមួយ។ ឈ្មោះមិត្តជា កន្លងទៅជាប់ពាក់ព័ន្ធថាជានីរសាររបស់លោក តាញ៉ែម ដែលគេដកចេញនោះបាទ ដែលឡើង តារិទ្ធ នេះ គេថាដកតាញ៉ែម ចេញដែលនៅកំពង់សោម នោះ អាហ្នឹងខ្ញុំគ្រាន់សាដើមបន្តិចបាទ។ អ៊ីចឹងទៅ ជា ហ្នឹងឯងក៏នៅស្រុកស្មោងជាមួយខ្ញុំដែរបាទ នៅក្នុងឃុំជាមួយខ្ញុំដែរឈ្មោះនោះ ហើយបានគ្រួសារហើយគេរៀបឲ្យ។ គ្នាជានីរសារបរឡាន ដល់ពេលគេដកលោក ញ៉ែម នេះទៅ ចាប់បាត់ទៅ អ៊ីចេះទៅឡើងគាត់នេះមកមានតំណែងនាទីអ៊ីចេះអីទៅ ថ្ងៃមួយ មិត្តថា នេះឯងក៏ជាប់ជាៗ គេដកតាហុងបន្តបន្ទាប់។ មាន តាហុង ហ្នឹងឯងក្រោម តារិទ្ធ ក្តាប់ប្រធានមន្ទីរពាណិជ្ជកម្មក្នុងប្រទេសដែលនៅទួលទំពូង ដកបាត់។ តាហុង នេះទៅមកជាប់មិត្តថា ដល់មកជាប់មិត្តថា ថ្ងៃមួយធ្វើការលីសែង គេជួយអូសឈើ អូសព្រៃពីក្នុងវត្តទួលទំពូងហ្នឹងឯង ឈើវែងៗ អ៊ីចេះទៅ មិត្តថា បានបក់ដៃហៅ មិត្តជា, "ថាមិត្តជាៗមកណេះមួយភ្លែតចេញមកក្រៅទៅមើលឈើនោះបន្តិចមើល កើត -- ធ្វើឃ្លាំងកើតឬអត់?

[១៤:១២:៤៥]

ម៉ោងជាងដប់ហើយជិតឈប់ធ្វើការ ខ្ញុំក្រឡេកមើលតាមច្រកចេញមុខទ្វារទៅវត្តអ៊ីចេះឯងនុះ ព្រោះអាផ្លូវនោះ ផ្លូវវិថីសេរីភាពយើងមកស្ទឹងមានជ័យ តែឥឡូវខ្ញុំវង្វេងហើយ អត់ស្គាល់ទេ អត់ដឹងទេ ដល់វាអ៊ីចេះទៅរីកចម្រើនណ៎ះ។ ដល់អ៊ីចេះទៅ ខ្ញុំលបងាកមើលពីក្រោមឃើញឡានមែន ឡានអាស៊ីមឺស័រ ឃើញលេខក្រហមតូចៗទេ ដាក់តែអក្សរ ម-៧០ អ៊ីចឹង។ មិត្តជា ដើរដល់ភ្លឹបកាំភ្លើងខ្លីភ្ជង់ខ្នោកឡើងឡាន! គ្នាគេបួននាក់ ប្រាំនាក់និងតៃកុង បិទឃ្លុបរឹងបាត់។

ក្រោយមកខ្ញុំ ថ្ងៃល្ងាចអង្គុយជំនុំគ្នាឯងស្ងាត់ៗ យើងអត់ដឹងថ្ងៃណាទេ។ អត់មានប៉ានចេញវាថាទេខ្ញុំសូមរាយការណ៍ឲ្យវាអស់ហេតុផល បានថាអំពើទាំងឡាយនេះ ទៅអត់រួចទេ ខ្ញុំអស់សេចក្តីបញ្ចប់ត្រឹមថ្ងៃ១៧ មេសា ដែលត្រូវរត់ចេញបែកបាក់គ្នាពីភ្នំពេញទៅនេះឯង។ រត់ផ្លាយឡើងដល់ឱរ៉ាល់

ដល់អីទៅ បានធ្លាក់ដល់កោះកុងកំពង់សោម ត្រឡប់មកវិញដែរវៀតណាមគេបានកៀរបាន កុំអីរត់ចូលដីថៃហើយ កាលនុំងនោះ ប៉ុន្តែទៅចេះវៀតណាមនៅស្កាត់មុខបានមកកៀរយកមកវិញមក។ នឹកឃើញថា អ្ហូ! ស្រេចយួនចូលងាប់បាត់។--

[១៤:១៥:១៦]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយចាំស្ដាប់សំណួរបន្តទៀត សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់លោកសាក្សី។ យើងនឹងត្រឡប់មកនិយាយអំពីបញ្ហាដែលលោកនិយាយឡើងវិញ ប៉ុន្តែខ្ញុំកម្រិតត្រឹមទូលទំពូងសិននៅពេលនេះ។ ខ្ញុំចង់អានអំពីកំណត់ហេតុរបស់លោកដែលលោកឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលថា ការប្រជុំធ្វើឡើងរៀងរាល់១០ថ្ងៃម្ដង ជាមួយ វ៉ាន់ រិទ្ធ។ សម្រង់ទី១ គឺនៅក្នុងកំណត់ហេតុដែលលោកមាននៅក្នុងដៃរួចមកហើយគឺលេខ 363 នៅទំព័រទី៥ នៅក្នុងគ្រប់ភាសាទាំងអស់។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ “នៅក្នុងហ្នឹងគឺថាមានការប្រជុំផ្ទៃក្នុងរៀងរាល់១០ថ្ងៃម្ដង ដែលមានឈ្មោះ រិទ្ធ ចូលរួមផងដែរ។ រិទ្ធ នេះបាននិយាយនៅក្នុងអង្គប្រជុំថា ខ្មាំងមិនទាន់អស់ទេ វានៅកំពុងស៊ើរូងផ្ទៃក្នុងក្នុងបក្ស។ ត្រូវតាមដានពិនិត្យតទៅទៀត។ សូម្បីស្លាបព្រាមួយក៏វាបំផ្លាញដែរ មិនចាំបាច់តែរបស់ធំដុំនោះទេ”។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមអានសម្រង់មួយទៀតនៃកំណត់ហេតុមួយទៀត ដែលមានលេខ E3/472 ដែលមានប៉ុន្មានខែក្រោយពីកំណត់ហេតុទី១ គឺថានៅទំព័រទី៣ គ្រប់ភាសាទាំងអស់។

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតប្រគល់ជូនឯកសារនេះជូនសាក្សី និងសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងទំព័រទី៣ជាភាសាខ្មែរនៅក្នុងអេក្រង់ទូរទស្សន៍។

[១៤:១៦:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ពាក់ព័ន្ធនឹងកិច្ចប្រជុំដដែលនេះ លោកបានឆ្លើយនៅក្នុងកំណត់ហេតុថា “នៅពេលប្រជុំតារិទ្ធ បានសុំឲ្យកម្មករទាំងអស់គោរពវិន័យអង្គការ ហើយនិងតាមដានសកម្មភាពខ្មាំង”។ ហើយនៅ

ចម្លើយបន្ទាប់មកទៀត លោកថា -- តារិទ្ធ ថា "មានខ្មាំងមានគិញ ដូច្នេះតែត្រូវតែបន្តចាប់គិញឲ្យអស់" សូមបញ្ចប់ការដកស្រង់។ លោកនិយាយថា វ៉ាន់ រិទ្ធ និយាយអំពីខ្មាំង តើលោកអាចបញ្ជាក់ថាគាត់បាននិយាយថាត្រូវតែតាមដានចាប់ខ្លួន ហើយនិងកម្ទេចខ្មាំងទេ?

**ឆ៖** បាទ។ អ៊ីចេះ គាត់បានលើកឡើងអ៊ីចេះមែន ពិតដូចខ្ញុំបានជម្រាបប្រសាសន៍ខាងដើមដែរ តែមិនអាចចាំបានគ្រប់គន្លងទាំងអស់ទេ។ គ្រាន់តែលើកគោលៗត្រង់កន្លែងណាដែលវាចំណុចសំខាន់ៗ ជូនទៅលោកប្រធានអង្គចៅក្រមបានស្តាប់បាន។

[១៤:១៧:៥២]

**ស៖** សូមអរគុណ។ តើលោកចាំទេ ថា តារិទ្ធ នៅពេលដែលគាត់និយាយអំពីខ្មាំង តើគាត់មាននិយាយសំដៅដល់គោលនយោបាយបក្ស ឬបញ្ជារបស់ថ្នាក់លើនៅក្នុងបក្សទេ?

**ឆ៖** គាត់បានលើកឡើងអ៊ីចេះមែនឯង ត្រង់ថាវាត្រូវតាមដានសកម្មភាពរបស់ខ្មាំងដែលវាស៊ីរូងផ្ទៃក្នុងបង្កប់ហ្នឹង ធ្វើឲ្យ ហៅថាបំផ្លាញដល់បក្សបដិវត្តន៍របស់គេនេះ គឺត្រូវមានវិធានការតាមឲ្យជាប់ ចាប់ឲ្យបានអ៊ីចឹងមែនពិត។ សូមជម្រាបប្រសាសន៍។

**ស៖** ក្រៅពីហេតុការណ៍ដែលលោកបានឃើញថា ជា ដែលជានីរសាររបស់ ញឹម ហើយលោកនិយាយថា ញ៉ែម ក៏ត្រូវបានចាប់ខ្លួនពីមុនមកហើយ។ ក្រៅពីហេតុការណ៍ទាំងអស់ហ្នឹង លោកបានឃើញដឹក ជា។ តើបន្ទាប់មកទៀតលោកឃើញឡានហ្នឹង ឡានដែលដឹក ជា ហ្នឹងត្រឡប់មកវិញទេ ត្រឡប់មកចាប់ខ្លួនអ្នកផ្សេងទៀតទេ?

[១៤:១៩:០៨]

**ឆ៖** បាទ ក្រោយមកគឺថា ឡាននោះចាប់ពីដឹកឈ្មោះ ជា ផុតទៅ គឺថារហូតដល់ថ្ងៃរំដោះ គឺវាបន្តបន្ទាប់មក គឺត្រូវផុតពេលដែលត្រូវចាប់នឹងកន្លែងដែលខ្ញុំបានឃើញបានដឹងបាទ។

**ស៖** មុនពេលចាប់ខ្លួន ជា តើមានអ្នកបាត់ខ្លួននៅក្នុងអង្គភាពរបស់លោកនៅទួលទំពូងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។ រង់ចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការសូមលោកឆ្លើយតប។

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអធ្យាស្រ័យ។ ក្រោយពីការចាប់ឈ្មោះ ជា ផុតទៅ អស់មួយរយៈទៅ វាអាច

ឆ្លងរាលដាលដល់រូបខ្ញុំបាទផ្ទាល់ដែរបាទ។ ប៉ុន្តែដោយយោងទៅតាមនេះឯងគឺថា គុណបុណ្យដឹងអានេះបានជួយ បានរស់ ម្យ៉ាងទៅ។ ថ្ងៃនេះ ខ្ញុំទៅសម្រាកពេទ្យបាត់ហើយ សម្រាកពេទ្យគេហៅពេទ្យ ៦មករា នៅមាត់ទន្លេទៅ។ អ៊ីចេះទៅ វារើអាមុខរបួសនេះ ដល់ត្រូវថ្ងៃចេញមកនោះឯង ខ្ញុំត្រូវឈប់នៅមួយកន្លែងក្រសួងពាណិជ្ជកម្មមានគ្នាតែពីរនាក់ជាមួយនឹងឈ្មោះ សួន រ៉ី ហៅ ខាន់ នេះឯង។ អ៊ីចេះគេមានគ្រួសារហើយ ខ្ញុំនៅលីវទេសម័យនោះបាទ។ ខ្ញុំសូមលើកលាតត្រដាងប្រាប់ហេតុផលឲ្យបានច្បាស់លាស់។

មកដល់យប់ឡើង ខ្ញុំនឹក ទៅពេទ្យយូរ ខ្ញុំនឹកគេ ខ្ញុំចេញដើរទៅ ទៅលេងហ្នឹងគេ។ ទៅរកអាយ៉ៃនាឡិកា ដែលនេះទៅ ដូចចៃដន្យបានគេនិយាយប្រាប់ ផ្លាប់ថ្លើមភឹបថាខ្ញុំត្រូវអស់ហើយពេលនេះ។ ព្រោះដូចពាក្យគេលើកឡើងថា វាខ្លាំងវាអត់ទាន់អស់។ អាមួយម៉ាត់នេះមិនធម្មតាទេ។ ដល់មិត្ត រ៉ី នេះបានប្រាប់ថា មិនដឹងធ្វើម៉េចទេមិត្តឯង ប៉ុនអ៊ីចេះចុះឲ្យយោបល់មួយ។ ថាធ្វើយ៉ាងម៉េចឯង ព្រោះយើងបើយើងរកចេញ ក៏ទៅណា វាក៏អត់រួចទេក្នុងសម័យនោះ។

[១៤:២២:០០]

អ៊ីចឹងឯងតាមគ្នាទៅ បើវាងាប់ក៏មិនដឹងធ្វើម៉េចដែរ កុំបន្ទោសណ៎ា។ ជំនុំគ្នាឯងស្ងាត់ៗ ពេលយប់ហ្នឹងឯង ថាត្រូវមកជួបនឹងប្រធានមន្ទីរទៅ រាយការណ៍ឲ្យត្រង់ខ្លួនឯងទៅ ប្រាប់ហេតុការណ៍។ តើគេអាចគេចរួចផុតពីខ្មោះឃ្មាង ការស្លាប់នេះបានដែរឬក៏អត់។ ខ្ញុំក៏ប្តេជ្ញាតាមគេដែរ នឹកឃើញថាវាអស់នោះ ព្រោះយើងរត់ៗមិនរួចដែរមិនអ៊ីចឹង! មានមកដូចតាមពាក្យគេថាទៅ។ ខ្ញុំដើរមកអ៊ីចេះកណ្តាលយប់មក ម៉ោងប្រហែលជាប្រាំពីរកន្លះយប់ មក ម៉ោងប្រាំបី! ភ្លេចអត់ចាំទេ អាត្រង់នេះឯងយប់ប៉ុន្តែគេអត់ទាន់សម្រាកទេ។ មកដល់ចៃដន្យ អើ នៅទីក្រុងអ៊ីចេះ! ភ្លើងនៅតែភ្លឺអ៊ីចេះដែរយប់។ ខ្ញុំដើរតាមវិថីហ្នឹង ព្រោះវាមិនមែនដូចសម័យនេះឯណា គេនៅនោះស្ងាត់ គេនៅតាមផ្ទះរៀងខ្លួនទេស្ងាត់អត់មានមនុស្សទេ។ អ៊ីចេះខ្ញុំក៏ប្តូរដើរមករកសួរផ្ទាល់តែម្តង ជាមួយឈ្មោះមិត្តថា ដែលជាប្រធាននារី ប្រធានមន្ទីរនោះ។

[១៤:២៣:០៩]

ដល់មក ច្រានទ្វារសុំទោសគេទៅ។ ខ្ញុំថា អូ!សុំ-- អ៊ំ! សួរខ្ញុំថា “មិត្តឯងថាទៅដេកពេទ្យនោះចេញមកថ្មើរម៉ាន?” ខ្ញុំថាចេញមកម៉ោងប្រាំមួយហើយ ថ្ងៃលិចទៅហើយ។ “តោះអញ្ជើញអង្គុយលេងខាងក្នុង” ទាញកៅអីដាក់ឲ្យមក។ “សួរថាទៅណាមកណានេះ? មានកិច្ចការអ្វីចង់និយាយ?” ខ្ញុំនិយាយ

ទាំងធ្លាក់ថ្លើមទេ ព្រោះតែចេះនិយាយប្រាប់គេត្រង់ៗ ថាគោលបំណងនៃរបាយការណ៍ដែលបានលើកឡើងទាំងអម្បាលមាណអំពីរឿងរបស់ខ្ញុំទៅលើ អ្នកខាងក្រោម ដែលខ្ញុំធ្វើជាប្រធានក្រុមទៅលើកម្មករ អីចេះមួយ អីចុះមួយអីនោះ។ ខ្ញុំប្រាប់ បងថា ឯងណាំ -- គេអាយុប៉ុណ្ណោះ ខ្ញុំចំណាស់ជាងទេ ប៉ុន្តែហៅគេបងអីចឹង -- ប្រាប់បងឯងថា "ខ្ញុំទៅតាមគោរពទៅតាមអង្គការវិន័យ (បាទចង់ភ្លេចហើយសម័យនោះបាទ) គោរពអង្គការវិន័យ ចាត់តាំងពីលើ។ បើគ្មានការចាត់តាំង យើងខ្ញុំមិនហ៊ានទេ បើខ្ញុំមិនធ្វើទៅតាមការចាត់តាំងណែនាំបានន័យថា ខ្ញុំអត់គោរពអង្គការវិន័យរបស់បក្ស"។ ប៉ុណ្ណោះឯងឆ្លងផុតមក ស្អែកឡើងអ្នកដែលនៅពីលើខ្ញុំចាប់បាត់ ចាប់ដកខ្លួនបាត់។ នារីដូចគ្នាដែរ គាត់ទៅពីខាងនិរតីដែរនារីនោះ ធ្វើប្រធានពីលើខ្ញុំទៀត។ គេប្រធានកង។

បានថាជាក់ស្តែង ខ្ញុំចៃដន្យដូចថា បើយើងនិយាយក្នុងសម័យនេះឲ្យអស់ទៅថា គុណបុណ្យព្រះលោកជួយបានវាត្រូវបានរស់ បាទ អីចេះ វាត្រូវចាប់បាត់ ហើយបន្ទាប់ទៀត តារិទ្ធ នេះ មិនប្រជុំនៅនោះ ប្រជុំនៅវត្ត នៅព្រះវិហារទួលទំពូងតែម្តង។ "មិត្តឯងទាំងអស់គ្នា មើលទៅលើឃើញរូបភាពអីដែរ?" អ្នកណាហ៊ានត មានអីមានតែគំនូរ ព្រះស្អីទៅស្អីទៅ។ "វាគ្មានការរីកចម្រើនទេ ប៉ុន្តែហីចុះខ្ញុំមិនឲ្យមិត្តឯងរំទេ អានេះអត់យូរទេ ទោះថ្ងៃណាមួយ ថយចេញឲ្យផុត គេយកមីនមកដាក់ហើយអាមីនតោន វាទាញបំបាក់ព្រះវិហារនេះ ឲ្យវាបាត់ទៅ គេយកថ្មនេះទៅធ្វើរោងចក្រវាចំណេញជាង"។ នេះថ្លែងពីសម្តីរបស់លោក វ៉ាន់ រិទ្ធ នេះ បានន័យថា អត់មានអ្នកណាដែលហ៊ានអើតទេ ជាមួយនឹងសង្គមនោះ។ ខ្ញុំសូមអស់យោបល់ប៉ុនណោះឯង។ ខ្ញុំចប់ហើយ បាទ។ អស់ហើយ សំណួរខ្ញុំមានប៉ុនណោះ។

[១៤:២៦:១៥]

**សៈ** សូមអរគុណលោកសាក្សី សម្រាប់ពេលវេលាដែលនៅសល់នេះ ខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានខ្លីៗ ព្រោះថាខ្ញុំមានពេលខ្លី។ បើលោកឆ្លើយខ្លី ខ្ញុំក៏អាចសួរបានច្រើនបន្តិចដែរ។ ឥឡូវនេះ ដើម្បីសង្ខេបអំពីរឿងរ៉ាវដែលលោកទើបតែនិយាយអំមិញនេះ គឺថាធម្មតា គឺថាគេចាប់ខ្លួនលោក ក៏ប៉ុន្តែ សួន រ៉ី នេះ ប្រាប់លោកទៅ ហើយលោកក៏ទៅជួបមេរបស់លោក គឺមិត្តនារី ថា ដើម្បីបញ្ជាក់ថា លោកមិនបានប្រព្រឹត្តខុសទេ អីចឹងលោកក៏បានរួចខ្លួន។ ហើយលោកថាមានការចាប់ខ្លួនមួយទៀត បន្ទាប់ពីលោកទៅជួបមិត្ត ថា ហើយ។ ដូច្នេះ លោកឯកភាពទេ ថាបន្ទាប់ពីមានការចាប់សមមិត្ត ជា ហើយនោះ មានការចាប់មនុស្សផ្សេងទៀតនោះ?

**ឆ៖** មាន បាទ ខ្ញុំដល់យូរទៀតទៅបាននឹកឃើញបាទ សូមអធ្យាស្រ័យ កុំឱ្យថានេះវាត្រូវសាចុះសាឡើង បាទ។ អានេះបើនិយាយទៅ បន្តបន្ទាប់មិនទាន់ដល់រឿងខ្ញុំ ក៏វាល្អស។ ដល់ក្រោយមកវាផ្តើមចាប់មួយៗទេ ដល់យូរទៅ ក្រោយមក គឺចាប់ទាំងខ្សែ។ អានោះគេចង់និយាយថា ដល់ភូមិភាគបូព៌ាម្តងហើយ។ ចាប់អស់ពីតិចដល់ច្រើន យកឡាន រថយន្តក្រុង អាឡានខ្សែអាធំនេះ យកទៅដាក់ទាំងប្រពន្ធ ទាំងកូនអានោះ បញ្ជូនទៅណោះ មិនដឹងជាទៅខាងណាទេ ថាទៅធ្វើផ្លូវរទេះភ្លើងអីចេះមិនដឹងពេជនិល អត់ដឹងដែរអានោះ។ ទៅទាំងអស់តែម្តង យំក្រេវគ្រឹកពេញ។ ដោយទាំងក្មួយខ្ញុំមួយដែរទើបតែបានរៀបឱ្យ ប្តីនៅខេត្តព្រៃវែង ប្រពន្ធនៅឯណោះ។ អីចេះគេយកទៅទាំងអស់។ អីចេះបាទអានេះដែលខ្ញុំបានដឹងគឺដឹងប៉ុណ្ណឹង បាទ។

[១៤:២៨:៣៩]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងឡាន ដែលលោកឃើញមកដឹក អ្នកចាប់ ការចាប់ខ្លួន ជាហើយនិងចាប់អ្នកផ្សេងទៀតនោះ តើលោកមើលទៅឃើញថា ឡាននោះ មានស្លាកលេខទេ? ឬក៏មានសញ្ញាសម្គាល់អីនៅលើឡាន ដើម្បីបញ្ជាក់ពីអង្គភាពណាៗទេ? ហើយមានការណែនាំអ្វីដែលពាក់ព័ន្ធនឹងឡានទាំងអស់នេះ?

**ឆ៖** បាទ សូមជម្រាបបន្ត គឺខ្ញុំមិនបានឃើញមានស្លាកលេខដូចឡានតូចមុន ដែលចាប់មិត្ត ជានោះទេ។ គឺស្គាល់ថា រថយន្តក្រុង ព្រោះដាក់មនុស្សបានច្រើន អាវែងអីចេះទៅ ចូលទៅ ដាក់យកតែម្តង។ ហៅដាក់ៗតែម្តង អត់មានអ្នកទៅប៉ាានអីទេ គឺដុះដើររៀងតែខ្លួនទេ ធ្មេចតែភ្នែកទេ ដល់ម៉ោងធ្វើការ ធ្វើ រឿងគេៗរឿងយើងៗ បាទ។ អានេះ សូមជម្រាបខ្លីៗប៉ុនណេះ។

**ស៖** សូមអរគុណ។ ខ្ញុំចូលទៅប្រធានបទមួយទៀត ខ្ញុំសូមអានចម្លើយនៅក្នុងកំណត់ស្តាប់ចម្លើយរបស់លោក គឺថ្ងៃទី២៩ តុលា ២០០៨ គឺឯកសារ E3/363, គឺពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន។ ជាភាសាបារាំងទំព័រទី៦, ទំព័រទី៥ ជាភាសាអង់គ្លេស, ជាភាសាខ្មែរ 00236035 គឺទំព័រទី៥ ជាភាសាខ្មែរ។ លោកមេធាវីប្រហែលជាអាចជួយគាត់រកមើលឃ្លាទំព័រនុ៎ងបាន។ លោកបានឆ្លើយដូចតទៅ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៤:៣០:៥១]

**លោក អាកទូរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់លោកប្រធាន។ ខ្ញុំកត់សម្គាល់ឃើញថា នៅពេលដែលសហព្រះរាជអាជ្ញាលើកឡើងអំពីកូនក្តីរបស់ខ្ញុំនោះ គាត់អត់សួរសំណួរផ្ទាល់តែម្តងទេ គាត់រំឭកការចងចាំរបស់សាក្សីសិន។ អ៊ីចឹងដូចជាមិនធម្មតាទេ នៅពេលដែលធ្វើអ៊ីចឹង ហេតុអីក៏លោកមិនធ្វើដូចពីមុនទៅ លោកសួរសំណួរសិនទៅ បើសិនជាសាក្សីមិនចាំទេ ចាំរំឭកការចងចាំរបស់គាត់។ ប៉ុន្តែនេះអត់ទេ លោកនិយាយមុនឲ្យគាត់ចងចាំបាត់ទៅហើយ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

បាទ លោកប្រធានដោយសារតែខ្ញុំពេលខ្លី មានពេលខ្លី ដូច្នេះហើយបានជាខ្ញុំធ្វើអ៊ីចឹងនោះ។ គឺថាដើម្បីចំណេញពេលវេលានៅក្នុងការពិភាក្សាដេញដោលរបស់យើង។ ខ្ញុំអាចចោទសំណួរបើកក៏បានដែរ ក៏ប៉ុន្តែសពេលនេះខ្ញុំគ្រាន់តែចង់អានឃ្លាមួយ ហើយបន្ទាប់មកខ្ញុំចង់សួរសំណួរបន្ថែមពាក់ព័ន្ធទៅនឹងចម្លើយនេះ។ ដូច្នេះខ្ញុំគិតថាវិធីនេះ គឺថាមិនមានការហាមឃាត់ពីអង្គជំនុំជម្រះនោះទេ។

[១៤:៣១:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ចំពោះសំណួរបែបនេះមិនសមស្របទេ ពីព្រោះបញ្ហានេះកើតឡើងច្រើនដងហើយៗ យើងបានដោះស្រាយរួចហើយថា ផ្អែកលើមូលដ្ឋាននៃកំណត់ហេតុបែបនេះគឺយើងអាចធ្វើដូច្នេះបាន។ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរបែបនេះចំពោះសាក្សីរូបនេះបាន។

[១៤:៣៣:១៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

**ស៖** ខ្ញុំសូមអានឃ្លាដែលខ្ញុំចង់ដឹងលោកសាក្សី លោកបានឆ្លើយថា "ក្រោយមកនៅឆ្នាំ១៩៧៨ នៅក្នុងពេលដែលខ្ញុំធ្វើការនៅវត្តទួលទំពូង ខ្ញុំឃើញ ខៀវ សំផន អមដោយឈ្មោះ រិទ្ធ មកពិនិត្យមើល

ផលិតផលក្នុងស្រុក ដូចជាសណ្តែកសៀង, សណ្តែកបាយ ដែលកម្មករកំពុងតែសម្រិតសម្រាំងច្រកបាវ និងថ្លឹងសម្រាប់នាំចេញទៅបរទេស"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់មួយ តើលោកបានឃើញលោក ខៀវ សំផន នៅទួលទំពូងមកពិនិត្យមើលកន្លែងហ្នឹងតែម្តង ឬក៏ឃើញគាត់មកច្រើនដងៗ?

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអរគុណ។ ពេលនោះគឺឃើញគាត់មកពិនិត្យនៅផលិតផលមិនបានសំណេះសំណាលយូរ គឺដើរអ៊ីចេះរហូតតាមដងផ្លូវម្តង ដោយអមដោយលោក វ៉ាន់ រិទ្ធ នេះឯងធ្វើដំណើរពីក្រោយបន្តបន្ទាប់ទៅ គ្រាន់តែមានពាក្យនិយាយថា "អ្ហ៎! កម្មករធ្វើការឲ្យស្អាតណាស់ ព្រោះរបស់នេះសម្រិតសម្រាំងសម្រាប់ចេញទៅបរទេស គឺខាងក្រៅប្រទេសយើង"។ អានេះខ្ញុំឮពាក្យសម្តីគាត់និយាយប៉ុណ្ណោះឯង គាត់ទៅរហូតបាត់ទៅបាទ។

[១៤:៣៥:០០]

**ស៖** បើតាមការកតសម្គាល់ឃើញរបស់លោកនៅពេលគាត់មកពិនិត្យនោះហើយនិងអ្វីដែលគេប្រាប់លោកពាក់ព័ន្ធនឹងក្រសួងពាណិជ្ជកម្មនោះគឺថា តើរវាង វ៉ាន់ រិទ្ធ ហើយនិង ខៀវ សំផន ហ្នឹងតើអ្នកណាមានឋានៈខ្ពស់ជាងនៅក្នុងបក្ស?

**ឆ៖** ខ្ញុំមិនដឹងដែរអានេះគ្រាន់ថាបើនិយាយទៅក្រសួងពេបជ្រាយដូចថា នាយករដ្ឋមន្ត្រី ប្រមុខរដ្ឋហ្នឹងខាងក្រសួងវាត្រូវនៅក្រោមហើយបាទ។ អានេះមិនដឹងទេ វាគ្រាន់តែស្មានព្រោះគាត់ត្រូវនៅលើព្រោះ វ៉ាន់ រិទ្ធ (ខមាទោស) ដើរតែឱនពីក្រោយ។

**ស៖** បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ពាក់ព័ន្ធទៅនឹងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ លោកប្រធាន! ខ្ញុំសូមការអនុញ្ញាតអានកិច្ចសម្ភាសន៍របស់សាក្សីរូបនេះជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានលេខ ES19.177, អង់គ្លេសនៅទំព័រទី២ គឺERN 00679694, ជាភាសាខ្មែរ00055227។ មិនមានការបកប្រែជាភាសាបារាំងទេ។ នេះជាឃ្លាខ្លីទេ ខ្ញុំសូមអានបន្ទាប់មកឲ្យសាក្សីឆ្លើយតប។ សំណួររបស់ដាវ៉ា -- លោកប្រធានខ្ញុំសូមការអនុញ្ញាតអានឃ្លានេះជាភាសាអង់គ្លេស ពីព្រោះថាជាភាសាបារាំងអត់មានការបកប្រែទេ។

[១៤:៣៧:១៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

ហើយខាងអ្នកបកប្រែរៀបចំដូរ *ឆេនឆែល* បកប្រែ។

សូមអញ្ជើញ!

**លោក អាកទូរ វែកគែន៖**

លោកប្រធាន លឿនពេកទៅខ្ញុំអត់មានបានពេលដើម្បីកត់ត្រាទំព័រ លេខទំព័រឲ្យបានច្បាស់លាស់ទេ សូមលោកព្រះរាជអាជ្ញាឲ្យម្តងទៀត។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ទំព័រជាភាសាអង់គ្លេសទំព័រទី១០, ជាភាសាខ្មែរ 00055227។ ខ្ញុំសូមដកស្រង់៖ "ដាវ៉ា: តើលោកស្គាល់បងទី២ ជាអ្នកណាទេ? ថាត គាត់ឆ្លើយថា: ប៉ុលពត, ខៀវ សំផន, អៀងសារី ហើយនិងនួនជា គឺជាមេដឹកនាំកំពូល។ ខ្ញុំមិនស្គាល់អ្នកណាជាបងទី២ទេក្នុងចំណោមអ្នកទាំងនេះ។ ខ្ញុំគ្រាន់តែដឹងថា ប៉ុល ពត គេហៅថាបងលេខ១។ ហើយបន្ទាប់មកខាងក្រោមនោះ មានមេដឹកនាំផ្សេងទៀតនៅក្នុងក្រសួងក្រៅពី ប៉ុល ពត ជានាយករដ្ឋមន្ត្រី, ខ្ញុំឮថា សុន សេន ទទួលបន្ទុកក្រសួងការពារជាតិ។ អៀង សារី ទទួលបន្ទុកក្រសួងការបរទេស។ នួន ជា ទទួលបន្ទុកសភាតំណាងប្រជាជនកម្ពុជា"។ សូមបញ្ចប់សេចក្តីដកស្រង់។ ហើយនេះគឺសម្រង់នៃចម្លើយរបស់លោកដែលលោកបានសម្ភាសកាល ពីឆ្នាំ២០០៣ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានឆ្លើយថា ប៉ុល ពត, ខៀវ សំផន, អៀង សារី, នួន ជា ជាមេដឹកនាំធំៗ។ តើលោកអាចប្រាប់បានទេនៅពេលណាដែលលោកចាប់ផ្តើមដឹងថា បុគ្គលទាំងអស់ហ្នឹងគឺជាមេដឹកនាំកំពូលរបស់កម្ពុជាប្រជាធិបតេយ្យ?

[១៤:៣៩:៣៧]

**ឆ៖** បាទ សូមអធ្យាស្រ័យខ្ញុំមិនសូវចាំបានដែរត្រង់ចំណុចនេះឯង។ ចាំមិនបានត្រង់ថាពេលណាទេតែគ្រាន់ថា យើងមិនប៉ានសួរតែគ្រាន់ថាមានពាក្យនិយាយខាងក្រៅ ដែលមេគេបន្តបន្ទាប់ខាងលើគេបានប្រាប់ទៅថា មេដឹកនាំធំៗ ដូចលោកមានប្រសាសន៍អ៊ីចឹងឯងបាទ គឺកំណត់អ៊ីចេះតែម្តងថាតាមមុខសញ្ញារបស់គេ គឺត្រឹមត្រូវអ៊ីចឹងឯង។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំឃើញថាពេលវេលាចេះតែកាន់តែខើចហើយ ហើយខ្ញុំត្រូវការ

ពេលវេលាបន្ថែមទៀត តើដូច្នេះលោកប្រធានត្រូវការសម្រាកសិនឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី ព្រមទាំងមេធាវីប្រឹក្សាគាត់ផង។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១នាទី ដល់ម៉ោង ១៥:០១នាទី)*

[១៥:០១:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណច្រើនលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុននឹងចូលទៅដល់ប្រធានបទពីរចុងដែលខ្ញុំចង់ពិភាក្សាជាមួយលោកសាក្សី ខ្ញុំមានសំណួរបំភ្លឺ សុំការបំភ្លឺមួយចំនួនដើម្បីឲ្យយល់អំពីអ្វីដែលឆ្លើយ។ លោកបានឆ្លើយថា លោកបានធ្វើការនៅកំពង់សោម ច្រាំងចំរេះ តាខ្មៅ និងទួលទំពូង ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ដូច្នេះតើលោកបញ្ជាក់ទេ បានទេថាលោកធ្វើការនៅក្រោមបង្គាប់របស់ វ៉ាន់ រិទ្ធ ឬក៏ តារិទ្ធ នៅក្រសួងពាណិជ្ជកម្ម?

[១៥:០២:២១]

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអរគុណ សូមជម្រាបប្រសាសន៍។ គឺថាការធ្វើកិច្ចការទាំងអស់ គឺក្រោមប្រធានមន្ទីរៗគឺក្រោមលំដាប់ថ្នាក់ វ៉ាន់ រិទ្ធ ជាប្រធានក្រសួងបាទ។ ប្រធានមន្ទីរគឺឈ្មោះ មិត្តថា ហ្នឹងឯងបាទចុងក្រោយ។

**ស៖** សូមអរគុណ។ ខ្ញុំត្រឡប់មកនិយាយអំពីការចាប់ខ្លួន ជា ហើយនិង ឡាន ដែលយើងបាននិយាយមុននេះបន្តិចនោះ។ ខ្ញុំសូមអានចម្លើយដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមសើបអង្កេត គឺឯកសារ E3/366, ជាភាសាខ្មែរគឺឯកសារ 00236034, ជាភាសាបារាំងនិងអង់គ្លេសគឺនៅទំព័រលេខ ទំព័រទី៥។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "ខ្ញុំឃើញផ្ទាល់ភ្នែកនៃការចាប់ខ្លួនសមមិត្ត ជា។ លេខារបស់តាញ៉ឹម -- តាញ៉ែម នៅពេលនោះ គឺកម្មករកំពុងធ្វើការ ហើយនារី ថា ដែលជាប្រធាននោះមកកោះហៅ ជា។ ខ្ញុំឃើញ ជា ដើរតាមនារី ថា រហូតទៅដល់ឡានហ្ស៊ីបមួយដែលបិទឃ្លុប ស្រាប់តែគេភ្ជង់មិត្ត ជា ហើយចាប់បញ្ចូលឡានតែម្តង។ ឡាននោះមានស្លាកលេខពណ៌ក្រហមសរសេរថា ម-៨៧០"។ សូមបញ្ចប់ការដកស្រង់។

[១៥:០៤:២៥]

អម្បាញ់មិញនេះ លោកនិយាយថាលោកអត់បានឃើញស្លាកលេខទេ។ តើលោកអាចបំភ្លឺបានទេថាឡានដែលដឹក ជា ទៅនោះ ពិតជាមានស្លាកលេខពណ៌ក្រហមដែលសរសេរថា ម-៨៧០ ហ្នឹងឬក៏អត់ទេ?

**ឆ៖** បាទ សូមអធ្យាស្រ័យ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការនាំមុខសាក្សីក្នុងការសាកសួរសំណួរនេះ។ សាក្សីលោកបានឆ្លើយហើយតាមខ្ញុំកត់ទុកនៅវេលាម៉ោងពីរ និងដប់បីនាទីរសៀលនេះ។ លោកបានបញ្ជាក់ថាលោកបានឃើញស្លាកលេខឡានដែលមានអក្សរពណ៌ក្រហមតូចៗម-៧០។ ហើយអម្បាញ់មិញនេះ លោកលើក តំណាងសហព្រះរាជអាជ្ញាលើកនូវអង្គហេតុថ្មីមួយគឺ ម-៨៧០ ដែលជាបញ្ហាថ្មី

នាំមុខសាក្សីរូបនេះ។ បាទសូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអត់យល់ពីការជំទាស់នេះសោះ។ ខ្ញុំអានចម្លើយរបស់សាក្សីដែលគាត់ឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំមកប្រឈមមុខនឹងចម្លើយរបស់គាត់ឥឡូវនេះដើម្បីឲ្យគាត់បំភ្លឺព័ត៌មានឲ្យបានច្បាស់។ ដូច្នេះអត់មានការច្រឡំទេ។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាអាចមានបញ្ហាបកប្រែ ឬក៏យ៉ាងម៉េច? គ្រាន់តែបញ្ជាក់ទៅ គាត់ឆ្លើយទៅថាគាត់ឃើញ ឬក៏មិនឃើញស្លាកហ្នឹងតែប៉ុណ្ណឹងហើយ ចប់ហើយ។

[១៥:០៦:១៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ បាទខ្ញុំក៏ខ្ញុំជំទាស់ដែរ មិនមែនដូចលោក គង់ សំអុន ទេក៏ប៉ុន្តែការជំទាស់របស់ខ្ញុំនោះ គឺថាជាការកត់សម្គាល់ឃើញមួយថាសហព្រះរាជអាជ្ញាគាត់រំឭកអានហ្នឹងដូចជាមិនស្មោះត្រង់សោះ។ សាក្សីត្រូវបានស្តាប់ពីរដងដោយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ លើកទី១នោះគាត់ឆ្លើយថា គាត់អត់មានបានឃើញស្លាកអីទេ។ ហើយលើកទី២ គាត់ឆ្លើយថាគាត់បានឃើញ ដូចដែលសហព្រះរាជអាជ្ញាបានរំឭកអម្បាញ់មិញនេះ។ ដូច្នេះដើម្បីឲ្យស្មោះត្រង់ ដើម្បីឲ្យពេញលេញនោះ នៅពេលដែលសហព្រះរាជអាជ្ញារំឭកការចងចាំរបស់សាក្សី គាត់ត្រូវតែអានកំណត់ហេតុទាំងពីរហ្នឹង កុំអានតែមួយ យកមកតែមួយដុំ មួយកំណាត់អ៊ីចឹង។ ដូច្នេះបើយើងមើលទាំងពីរហ្នឹងទៅគឺថាវាបញ្ច្រាសគ្នា។ ចំពោះការជំទាស់របស់លោក គង់ សំអុន នោះគឺថាខ្ញុំអត់យល់ដែរ ប្រហែលជាអាចមានបញ្ហាបកប្រែមើលទៅ។ បកប្រែជាបារាំងមក ហើយចំពោះចម្លើយរបស់សាក្សីអម្បាញ់មិញនេះ ខ្ញុំអត់យល់ដែរ។

[១៥:០៧:៣៨]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបជូនថា ការកត់សម្គាល់ឃើញថាដូច្នេះបញ្ហាចម្លើយរបស់សាក្សីពាក់ព័ន្ធជាមួយនឹងរថយន្តដែលមកទទួលយកមនុស្សពីមុំវត្តទួលទំពូងហ្នឹង គឺគាត់បានឆ្លើយថារថយន្តហ្នឹង គឺតាមគាត់

មើលឃើញ គឺពាក់ស្លាកលេខ ម-៧០ ហើយចំណែកឯងនៅក្នុងកំណត់នោះដែលគាត់ឆ្លើយលើកមុននោះគឺ ម-៨៧០។ ប៉ុន្តែរវាងឆ្លើយខុសទាំងពីរចំណុចនេះ ខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអត់បានសួរបញ្ជាក់ឡើងវិញអំពីភាពខុសគ្នានេះ ដើម្បីបញ្ជាក់ថាតើរថយន្តណាមួយស្លាកអីដែលច្បាស់លាស់ រវាងភាពដែលខុសគ្នារវាងចម្លើយទាំងពីរនេះ មុននឹងឈានដល់សំណួរផ្សេងៗទៀត។ នេះដែលជាបញ្ហានាំឲ្យកើតមានបញ្ហា។ រឿងនេះគឺជារឿងត្រឹមត្រូវបំផុតហើយនូវចម្លើយជាភាសាខ្មែរ គឺច្បាស់លាស់អ៊ីចឹង។

[១៥:០៨:៣៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

បាទលោកប្រធាន។ សូមអរគុណ ប្រសិនបើគាត់និយាយជាភាសាខ្មែរថា ស-៧០នោះ -- ស-៨៧០ នោះគឺវាថា (សូមទោស) ម-៧០ហ្នឹងគឺត្រឹមត្រូវហើយ ក៏ប៉ុន្តែខ្ញុំអត់បានឮអ៊ីចឹងទេ។ ដូច្នេះ ខ្ញុំនឹងពិនិត្យមើលប្រតិចារឹកឡើងវិញ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

**សៈ** លោកបានឆ្លើយថា លោកខៀវ សំផន បានមកទួលទំពូងដើម្បីពិនិត្យមើលរោងជាងនៅឆ្នាំ១៩៧៨។ ហើយលោកក៏បាននិយាយអំពីការចាប់ខ្លួនផងដែរ។ តើការចាប់ខ្លួននៅទួលទំពូងបានកើតឡើងមុនពេលលោក ខៀវ សំផន មកឬក៏មានការចាប់ខ្លួននៅក្រោយពេលលោក ខៀវ សំផន មក?

**លោក ស៊ឹម ហោះ**

**ឆៈ** បាទសូមអរគុណ។ ត្រង់នេះខ្ញុំដូចវាក់បន្តិចដែរ។ អ៊ីចេះសូមពេលគិតឲ្យបានមុនបន្តិចបាទ។ ការចាប់ខ្លួនរបស់មិត្ត ជា គឺមុនពេលដែលលោក ខៀវ សំផន មកបាទ។

**សៈ** សូមអរគុណ ខ្ញុំមានសំណួរមួយទៀតដើម្បីសុំការបំភ្លឺពីលោក។ អម្បាញ់មិញនេះលោកនិយាយថានៅពេលដែលលោក ខៀវ សំផន មកមើលនោះគឺថាមានអមដំណើរដោយ វ៉ាន់ រិទ្ធ ហើយ វ៉ាន់ រិទ្ធ តែងតែដើរឱនៗ។ ខ្ញុំមិនដឹងថាគាត់ឱនហ្នឹងមានន័យថាម៉េចទេ លោកអាចពន្យល់បានទេថា លោក វ៉ាន់ រិទ្ធ ហ្នឹងដើរហ្នឹងឱនៗក្បាលហ្នឹងមានន័យថាម៉េចដែរ?

**ឆៈ** បាទ សូមអរគុណ។ អានេះវាយោងទៅតាមការយល់ដឹងរបស់ខ្ញុំពេលបច្ចុប្បន្នបានន័យថា ការឱនលំទោនជាការគោរពរវាងខ្ពស់និងទាបបាទ។

[១៥:១១:២៩]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀតគឺកិច្ចប្រជុំដែលលោកបានឆ្លើយថា លោកបានចូលរួមជាមួយលោក ខៀវ សំផន នៅដើមឆ្នាំ១៩៧៥។ លោកបាននិយាយអំពីកិច្ចប្រជុំនេះជាច្រើនដងនៅពេលដែលលោកផ្តល់ការសម្ភាសទៅឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៣។ តើលោកអាចជម្រាបបានទេថា អ្នកណាខ្លះបានចូលរួមនៅក្នុងកិច្ចប្រជុំនៅដើមខែមករា ឆ្នាំ១៩៧៥ ហើយនៅ -- ដើមខែមេសា (សូមទោស) តើនៅឯណាដែរ? នៅឆ្នាំ១៩៧៥ (សូមទោស) គឺដើមខែមករា ឆ្នាំ១៩៧៥ ហើយកិច្ចប្រជុំនោះធ្វើឡើងនៅឯណា?

**ឆ៖** សូមអធ្យាស្រ័យ មិនចាំបាទកន្លែង។

**ស៖** បាទ ដោយសារខ្ញុំសល់ពេលវេលាតិចតួច ខ្ញុំសូមរំឭកលោកដោយអាននូវឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានលេខ IS19.177, ជាភាសាអង់គ្លេសនៅទំព័រ ៣៧-៣៨, ជាភាសាខ្មែរ 00055251។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានជាថ្មីម្តងទៀត ខ្ញុំសូមការអនុញ្ញាតអានឃ្លានេះជាភាសាអង់គ្លេស។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នេះជាចម្លើយរបស់លោកនៅក្នុងពេលដែលលោកផ្តល់ការសម្ភាស។

*(អានជាភាសាអង់គ្លេស៖) "នៅថ្ងៃទី០៥ មករា ឆ្នាំ១៩៧៥ នៅពេលដែលមានការជម្លៀសនៅកំពង់ចាម គេបញ្ជូនតាមទូកទៅកំពង់សោម។ ខ្ញុំចូលរួមប្រជុំពេលព្រឹកនៅបុរីកីឡា។ ខ្ញុំបានឃើញ ខៀវ សំផន ដោយផ្ទាល់ ហើយខ្ញុំភ្ញាក់ផ្អើលនៅពេលដែលខ្ញុំឮគាត់និយាយបែបនោះ ខ្ញុំភ្ញាក់ផ្អើល"។*

[១៥:១៤:០២]

ហើយខាងក្រោមនោះបន្តិចលោកបាននិយាយអំពី ខៀវ សំផន *"លោក ខៀវ សំផន បាននិយាយថា ទោះបីថាមានការទម្លាក់គ្រាប់បែក ការប្រយុទ្ធគ្នានៅក្នុងអរិយក្សត្រ យើងជាមេកងទ័ពកងហើយនិងមេបញ្ជាការកងតូច និងអនុសេនាតូចត្រូវតែដឹកត្រង់សេ ហើយពង្រឹង យើងមិនអាចរត់ចេញពីមូលដ្ឋានរបស់យើងទេ។ យើងមិនអាចបាក់ទឹកចិត្តទេ។* (នៅខាងក្រោមបន្តិចនោះ) *នៅបុរីកីឡា -- នៅពហុកីឡដ្ឋាននោះគឺថាអង្គភាពវរសេនា ប្រធានវរសេនាតូចត្រូវអញ្ជើញទៅចូលប្រជុំអ្នកផ្សេងមិនកោះអញ្ជើញទេ គោលបំណងនោះគឺថាដើម្បីឱ្យពួកនោះយល់អំពីសភាពការណ៍។ បន្ទាប់ពីការប្រជុំនោះយើងបានចូលរួមប្រជុំមួយទៀត ប្រធានក្រសួងនោះគឺថា បានបង្គាប់ឱ្យយើងធ្វើការដឹកត្រង់សេ ហើយ*

*និងនិងលានដ្ឋានផ្សេងៗ"*។ សូមបញ្ចប់។ *(បញ្ចប់ការអានជាភាសាអង់គ្លេស)*

[១៥:១៥:១១]

លោកសាក្សីតើលោកនៅតែរក្សាចម្លើយថាលោកបានចូលរួមកិច្ចប្រជុំជាមួយនឹង ខៀវ សំផន នៅបុរីកីឡានៅដើមខែមករា ឆ្នាំ១៩៧៩ គឺថានៅមុនពេលវៀតណាមវ៉ៃយកទីក្រុងភ្នំពេញបានបន្តិច?

**ឆ៖** បាទ សូមអរគុណ ដោយអម្បាញ់មិញ ខ្ញុំភាំងដែលអត់បានយល់។ គឺថាបានពេលនោះ មុនបន្តិចនោះ គឺបានគាត់ហៅទៅប្រជុំអ៊ីចេះនេះ ដូចថាក្រោយលុះបាន១ថ្ងៃមក គឺត្រូវវៀតណាមចូលមកតែម្តង។ គឺចូលចម្លើយដែលបានរៀបខាងដើមអ៊ីចឹង។

**ស៖** ក្រោយពីគេប្រាប់ឲ្យជីកលេណដ្ឋាន ឬក៏ជីកត្រង់សេនោះ តើលោក ខៀវ សំផន មាននិយាយអ្វីផ្សេងទៀតទេ ឧទាហរណ៍ដូចជា គាត់និយាយអំពីការដកទ័ពចេញនៅចំពោះមុខការវ៉ៃចូលរបស់វៀតណាមនេះ?

**ឆ៖** លោក ខៀវ សំផន បាននិយាយអ៊ីចឹងមែន។ គឺថាឲ្យជីកលេណដ្ឋានការពារ ហើយមិនអាចឲ្យរត់គេចផ្តេសផ្តាសបានទេ ដើម្បីតបតជាមួយ ប៉ុណ្ណោះឯង មានប្រសាសន៍ ដឹង ឮនិយាយ។ បាទ សូមអរគុណ។

**ស៖** តើនៅក្នុងពេលប្រជុំនោះ មានតែមនុស្សមកពីខាងពាណិជ្ជកម្ម ឬក៏មានកម្មាភិបាលមកខាងក្រសួងផ្សេងទៀត ឬក៏កម្មាភិបាលយោធាដែលមានវត្តមានផងដែរ?

**ឆ៖** បាទ សូមទោស ត្រង់កន្លែងនេះឯង ខ្ញុំមិនអាចចាំបានទេ ចំពោះអ្នកចូលរួមក្នុងវេទិកាដែលប្រជុំថ្ងៃនោះ។ ក្តាប់អត់បាន មិនដឹងមកប៉ុន្មានកន្លែង។

[១៥:១៧:៤៦]

**ស៖** លោកសាក្សីតើលោកស្គាល់មនុស្សម្នាក់នៅក្រសួងពាណិជ្ជកម្មដែលធ្វើការនៅច្រាំងចំរេះឈ្មោះ រស់ ស៊ុយ។ លោកស្គាល់ទេ រស់ ស៊ុយ? បាទ ខ្ញុំសូមអានម្តងទៀត គឺ រស់ ស៊ុយ។ បើអក្សរឡាតាំងនោះ គឺ អ៊ែ-អ៊ុយ-អូ-អេស-អេស-អ៊ុយ-អីហ្គ្រិច គឺយើងប្រកបទៅ រស់ ស៊ុយ។

**ឆ៖** អត់ស្គាល់ទេ បាទ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងចំណុចនេះ តើលោកចាំទេ នៅថ្ងៃនោះ មានស្តាប់ឮលោក ខៀវ សំផន និយាយអំពីខ្មាំងខាងក្នុង ឬខាងក្រៅទេ?

**ឆ៖** បាទ អរគុណ គឺមិនចាំទេ បាទ។ វាយូរហើយ ភ្លេចភ្លាំងអស់។

**ស៖** សូមអរគុណសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទចុងក្រោយ គឺកិច្ចប្រជុំ ឬក៏ការជួបគ្នាជាមួយ នួន ជា។ ខ្ញុំចង់ដឹងថា តើលោកបានចូលរួមនៅក្នុងពិធី ឬក៏ក្នុងវគ្គសិក្សាប៉ុន្មានដងដែលមានលោក នួន ជា ចូលរួមនោះ?

[១៥:២០:០០]

**ឆ៖** ដូចអត់ចាំទេ អានេះ។

**ស៖** ក៏ប៉ុន្តែលោកចាំថាធ្លាប់បានឃើញគាត់ទេ ឧទាហរណ៍ដូចជានៅក្នុងកិច្ចប្រជុំធំៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យណាមួយនោះ?

**ឆ៖** ដូចមិនដែលបានជួប។

**ស៖** សូមអរគុណសាក្សី។ ខ្ញុំបញ្ចប់ការសួរសំណួរហើយ ហើយខ្ញុំសូមអរគុណដែលលោកបានមកចូលរួមដើម្បីលាតត្រដាងការពិត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! មេធាវីដែលទទួលសិទ្ធិគឺលោកស្រីមេធាវី ជេត វណ្ណលី និងលោកស្រីមេធាវី គ្រីស៊ីន ម៉ាទីណូ។ សូមលោកប្រធានអនុញ្ញាត។

[១៥:២១:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ជាដំបូងសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសូមគោរពដល់អង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** សួស្តីលោកសាក្សី! អម្បាញ់មិញលោកបានបំភ្លឺចំណុចមួយចំនួនជូនសហព្រះរាជអាជ្ញានិង

អង្គសវនាការទាំងមូលរួចហើយ ប៉ុន្តែឥឡូវនេះគឺខ្ញុំសូមឲ្យលោកជួយបំភ្លឺបន្ថែមនូវចំណុចមួយចំនួនទៀត ដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ។ សំណួរដែលខ្ញុំចង់ឲ្យលោកសួរបន្ថែមនេះគឺផ្អែកទៅលើឯកសារ E3/472 ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ និងឯកសារលេខ E3/363 ចុះថ្ងៃទី២៩ ខែតុលា ២០០៨ ដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងឯកសាររបស់ខាង ឌី.ស៊ី.ខេម លេខ IS19.177 និង IS19.177 ដែលមានចំណងជើងពិនិត្យប្រវត្តិរូបបដិវត្តន៍។ ផ្អែកលើឯកសារទាំងបួន នេះគឺថា ព្រះរាជអាជ្ញាក៏បានប្រគល់ជូនលោករួចហើយ។ ដូច្នេះខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្ថែមនូវចំណុចមួយចំនួនដែលទាក់ទាមនឹងអ្វីៗដែលលោកបានជួប បានឃើញកន្លងមកនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោកបានបញ្ជាក់នៅមុខសហព្រះរាជអាជ្ញាថាលោកបានធ្វើការនៅកំពង់សោម។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថាតើពេលដែលលោកធ្វើការនៅកំពង់សោមហ្នឹង តើនៅឆ្នាំណាពិតប្រាកដលោក?

[១៥:២៣:០៨]

**ធ៖** បាទ សូមជម្រាបប្រសាសន៍ ឃើញថា បើនិយាយទៅពីខែ៧ ឆ្នាំ៧៥ មកដល់ខែ៦ ឆ្នាំ៧៦ គឺត្រូវត្រឡប់មកទីក្រុងភ្នំពេញវិញបាទ។ ធ្វើការនៅខេត្តកំពង់សោមបាទ។

**ស៖** អរគុណលោក។ លោកបានបញ្ជាក់ថានៅទីនោះគឺថាលោកទទួលបន្ទុកលីសែងសម្ភារៈចេញពីកប៉ាល់ ហើយនិងដឹកចូលកប៉ាល់វិញ។ ប៉ុន្តែនៅពេលនោះលោកបានជួបព្រឹត្តិការណ៍អីខ្លះដែរនៅកំពង់សោមនោះ ជាមួយកម្មករ ឬមួយព្រឹត្តិការណ៍អីផ្សេងៗខ្លះដែលកើតនៅកំពង់សោម?

**ធ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ កាលដែលនៅកំពង់សោមធ្វើជាកម្មករលីសែងទាំងអស់គ្នាគឺនៅខាងឃ្លាំងលើទេចម្ងាយពីកន្លែងធ្វើការទៅមាត់សមុទ្រនោះចំនួន ៧គីឡូដែរ បើគិតជាចម្ងាយគ្រាន់តែឡានដឹកទៅមក ហើយក្នុងនោះត្រូវលីសែងដាក់ឃ្លាំងមាត់សមុទ្រ។ មុនដំបូងគឺនៅហ្នឹងកប៉ាល់ តែក្រោយមកលុះបានប៉ុន្មានខែមកខាងភូមិភាគនីរតីនេះគេត្រូវផ្លាស់ចេញឲ្យខាងកម្មករ ខាងភូមិភាគឧត្តរដែលធ្វើជាកម្មករដែលទៅនៅកន្លែងនោះគឺដូរគ្នា។ អីចេះខាងនីរតីនេះគេចូលទៅក្នុងកប៉ាល់ ឲ្យខាងកម្មករ ខាងយើងខ្ញុំដែលជាភូមិឧត្តរដែលទៅនៅម្ដុំនោះឲ្យធ្វើការខាងឃ្លាំងមាត់សមុទ្រវិញ។ ចុះពីឃ្លាំងលើទៅលីសែងនៅឃ្លាំងមាត់សមុទ្របាទ។

[១៥:២៤:៥៤]

**ស៖** តើនៅឃ្លាំងមាត់សមុទ្រហ្នឹងលោកបានជួបហេតុការណ៍អីខ្លះដែរទេ ចំពោះកម្មករមានការបាត់បង់ជីវិតឬមានការស្លាប់កម្មករអីទេនៅពេលនោះលោក?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ស៊ឹម ហោ៖**

បាទ សូមអធ្យាស្រ័យខ្ញុំមិនបានមើល។ អ៊ីចឹងនៅពេលធ្វើការនៅកន្លែងនោះមុនដំបូង គឺសូមជម្រាបប្រសាសន៍បន្តបញ្ជាក់បន្ថែម ពីលើកឡើងកន្លងទៅមិនបានថត។ គឺថាកន្លងទៅពេលដែលទៅដល់ថ្មីៗរយៈពេលមិនទាន់បាន១ខែទេ ប្រហែលជាងកន្លះខែ នៅថ្មីថ្មោងទៅ កប៉ាល់មកចតនៅនោះ។ និយាយទៅថ្ងៃមួយនោះ មានយន្តហោះទៅទម្លាក់គ្រាប់បែកអត់ចំកប៉ាល់ទេ អានេះចំឃ្លាំង ឃ្លាំងនោះធំណាស់ផ្ទុកអីវ៉ាន់បានរាប់ម៉ឺនតោនណោះ អាឃ្លាំងមាត់សមុទ្រនេះបាទ។ អ៊ីចឹងវាឆេះឃ្លាំងនុំងអស់មួយទៅគេថាកប៉ាល់អាមេរិក ឮថាទម្លាក់គ្រាប់បែកប្រុងឲ្យចំកប៉ាល់ចិនហ្នឹងឯង តែវាអត់ចំ វាផ្លោងមកវាចំឃ្លាំងនោះបាទ។ ខ្ញុំអត់បានឆ្លើយអស់ដូចកាលដែលរៀបរាប់ដោយទៅយកព័ត៌មានទេបាទ។

[១៥:២៦:២៦]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អរគុណលោក។ តើក្នុងការទម្លាក់គ្រាប់បែកហ្នឹងមានប៉ះពាល់ដល់អាយុជីវិតរបស់កម្មករដែលធ្វើការនៅទីនោះទេចាស? ឬមានការខូចខាតអីខ្លាំងទេចំពោះឃ្លាំងសម្ភារៈទាំងអស់នុំង ឬក៏កប៉ាល់ហ្នឹង?

**ឆ៖** បាទ អ៊ីចេះពេលនោះ ទៅដល់ថ្មីថ្មោង អត់ទាន់ធ្វើការទេ បើនិយាយទៅ។ គឺឃ្លាំងនោះ គឺមិនទាន់ដាក់ផ្ទុកអីវ៉ាន់ទេ មិនទាន់លើកចេញពីកប៉ាល់មកទេ សម្ភារៈទាំងអស់នុំងនៅឡើយទេ។ និយាយពីខូចខាតតែឃ្លាំងទេ ដែលវាទម្លាក់ចំបាទ វានៅមនុស្សអីអត់មានគ្រោះថ្នាក់ គឺអត់បាទ។

**ស៖** សូមអរគុណលោក។ ខ្ញុំឆ្លងទៅសំណួរមួយទៀត។ នៅក្នុងកំណត់ហេតុរបស់លោកជាមួយ ឌី.ស៊ី.ខេម លេខ19.177, ERN ជាភាសាខ្មែរលេខ 0055237, និង ERN ជាភាសាអង់គ្លេស 00679705 និង 00679707 គ្មានជាភាសាបារាំងទេ។ លោកបានបញ្ជាក់ថា “ពេលលោកទៅវត្តឧណ្ណាលោម លោកបានវង្វេងផ្លូវ ហើយបានឃើញនារីម្នាក់ដែលលក់ដូរកន្លែងផ្សារបរទេស គេលាក់ការណ៍ណាស់”។ ក្នុងចំណុចហ្នឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើនៅពេលនោះ កន្លែងដែលលក់ដូរដែលលោកបញ្ជាក់ហ្នឹងជាកន្លែងលក់ដូរយ៉ាងម៉េចលោក? ជាផ្សារ ឬក៏ជាស្ដីចាស? ហើយការដោះដូរគ្នា

យ៉ាងម៉េចចាស? សូមលោកបញ្ជាក់កន្លែងហ្នឹង។ សូមឲ្យលោករំឭកឡើងវិញមើលក្រែងលោកចាំចាស។

[១៥:២៨:១៣]

**ឆ៖** បាទ សូមអរគុណ។ ត្រង់ចន្លោះហ្នឹង ខ្ញុំមិនអាចរៀបរាប់អស់។ វាដូចការលើកឡើងដែរ ប៉ុន្តែខ្ញុំមិនបានលើកអស់ព្រោះវាមានខ្វះចន្លោះដោយការភ្លេចភ្លាំង ព្រោះវាយូរយារហើយ។ កាលត្រឡប់ពីកំពង់សោមមក មុនដំបូងបង្អស់មិនទាន់ទៅច្រាំងចំរេះទេ បើនិយាយទៅឲ្យអស់ទៅ ត្រូវមកនៅស្នាក់នៅនឹងវត្តឧណ្ណាលោម។ អ៊ីចេះ គេឲ្យមករៀបចំអីវ៉ែអីវ៉ាន់នៅម្តុំផ្សារថ្មីអ៊ីចេះឯង គេជូនមក ដល់អ៊ីចឹងរកផ្ទះនោះវាអត់ឃើញទេ ពេលឡប់មកវិញ វាវង្វេង ៗបន្ទប់នៅហ្នឹងអត់ស្គាល់ទេ អត់ស្គាល់ថា ដឹងកន្លែងត្រង់ណាត្រង់ណីដើរចុះដើរឡើង នាំគ្នាទៅមកៗអ៊ីចឹង។ អាន់ុងពិតមែនហ្នឹងឯងបាទ។

**ស៖** ប៉ុនខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ផ្សារដែលលោកនិយាយហ្នឹង ដែលថាលាក់ការណ៍នុ៎ង របៀបលាក់ការណ៍ម៉េចទៅ? ហើយផ្សារនុ៎ងផ្សារយ៉ាងម៉េចលោក? ជាផ្សារដូចសព្វថ្ងៃ ឬក៏ជាផ្សារសម្រាប់តែជនបរទេស?

[១៥:២៩:១៧]

**ឆ៖** អូ! អាកន្លែងនោះ គេទៅដើរចំប្រលោះចង់សួរនារីនោះឯង គេលក់ដូរទៅ ដល់សួរទៅគេថាកន្លែងនេះចូលអត់បានទេ ព្រោះកន្លែងលាក់ការណ៍សម្រាប់លក់ដូរដូចថា ម្ហូបអាហារ ឬអ្វីផ្សេងៗសម្រាប់ជនបរទេស។ ហើយគេចេញចូលបាទ។

**ស៖** អរគុណលោក។ តើលោកអាចបញ្ជាក់បានទេ ការដោះដូរដែលគេ ជនបរទេសដែលទិញនោះណ៎ះ មានការចាយលុយដែរអ៊ីចឹងពេលហ្នឹង? បានន័យថា មានលុយចាយដែរលោក?

**ឆ៖** ត្រង់ចំណុចហ្នឹងខ្ញុំមិនអាចបានដឹងទេ គ្រាន់តែតាមតែពាក្យដែលគេ មិត្តនារីនោះប្រាប់ប៉ុណ្ណោះទេ។ ខ្ញុំអត់បានដឹង ទៅបានចូលទៅសួរនាំហេតុផលអីបញ្ជាក់អ៊ីចេះមួយៗ គឺអត់ដឹង។

**ស៖** សូមអរគុណលោក។ ខ្ញុំឆ្លើយចូលទៅសំណួរមួយទៀត នៅវត្តទួលទំពូង។ អម្បាញ់មិញលោកបានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា លោកធ្វើការមួយរយៈនៅក្នុងវត្តទួលទំពូង ហើយនៅក្នុងឯកសារលេខ E3/472 ដែលមាន ERN ជាភាសាខ្មែរលេខ 00170627 និងERN ជាភាសាអង់គ្លេសលេខ 00205031 និងERN ជាភាសាបារាំងលេខ 00205035, លោកបានបញ្ជាក់ថា តាវិទ្ធជាប្រធានពាណិជ្ជកម្មបានបញ្ជាឲ្យកម្ទេចរូបព្រះ និងជាជីនៅក្នុងវត្តទួលទំពូង។ ខ្ញុំចង់ឲ្យលោកបញ្ជាក់

ថា ហេតុអីបានជាគេឲ្យកម្ទេចព្រះ ព្រះអង្គអីហ្នឹងលោក ហើយចុះលោកសង្ឃអីទៅណាអស់ទៅលោក ពេលដែលលោកមកដល់ទីហ្នឹង?

[១៥:៣១:១១]

**ឆ៖** បាទសូមអរគុណ។ អ៊ីចេះខ្ញុំសូមបញ្ជាក់ជូនថា ក្នុងសម័យនោះកាលដែលនៅក្នុងឆ្នាំដែលសភាពការណ៍គ្រប់គ្រងអាចុងក្រោយ មិនថាចុងទេ បើនិយាយទៅក្នុងសម័យនោះគឺអត់មានទេព្រះសង្ឃ ហើយព្រះនៅតាមវត្តខាងៗឲ្យ គឺឲ្យរើចោលទាំងអស់។ បាទ គេបញ្ជាឲ្យរើចោលកម្ទេចទាំងអស់ គឺអត់មានម្តង។ អ៊ីចេះវិហារនេះ គេគ្រាន់តែបានចង្អុលប្រាប់ថា ថ្ងៃណាមួយមិត្តឯងមិនឲ្យរើទេ គេប្រើវិធីចុចមីន ដាក់មីនទៅ ដើម្បីកម្ទេចយកថ្មនេះឯងទៅធ្វើរោងចក្រ វាចំណេញជាង ហើយមកទុកអ៊ីចេះ គួរគំនូរបានប្រយោជន៍អីអ៊ីចេះ។ យើងត្រូវយល់ឲ្យដឹង មើលទាំងអស់គ្នាទៅឲ្យឃើញអ៊ីចឹង។ អានេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ។ មិនមានទេព្រះសង្ឃ អត់ គ្មានអ្នកណានៅទេ។

**ស៖** អរគុណលោក។ ហើយចុះដែលសម្ភារៈ លោកអំមិញលោកបានបញ្ជាក់នៅមុខព្រះរាជអាជ្ញាថាសម្ភារៈទាំងអស់ដែលលោកទួលបន្ទុកខាងរៀបចំសម្រិតសម្រាំងសំឡី-គ។ ចុះសម្ភារៈសំឡី-គហ្នឹងដាក់នៅកន្លែងណាលោក? គេមានធ្វើឃ្លាំងនៅជុំវិញវត្តហ្នឹង ឬក៏យ៉ាងម៉េចចាស?

**ឆ៖** អរគុណ។ សូមជម្រាបថាបញ្ហាសម្ភារៈជាផ្លែគៗដែលយកមករើនឹងម៉ាស៊ីន ធ្វើឲ្យម៉ាស៊ីនហ្នឹងវាផ្ទុំទៅ គេធ្វើទ្រង់អ៊ីចឹងទៅ រែងទៅ។ អាទី១អ៊ីចេះ ទី២ ទី៣ មានបីប្រភេទរបស់វា។ ពេលបានហើយច្រកប៉ាវ។ ប៉ាវយើងមិនមែនដូចបច្ចុប្បន្នទេ អាហ្នឹងបាវក្រចៅដែលយកពីបាត់ដំបងមក ច្រកៗឲ្យណែនទៅ ដេរមាត់បញ្ជូនទៅអាតាខ្មៅ។ កន្លែងនោះ វាគ្រីបសំឡី-គ មានម៉ាស៊ីនគេគ្រីបសំឡី-គ។ ក្នុងមួយបាវវា គេដេរដាក់ទៅសម្រាប់បញ្ជូនចេញទៅក្រៅប្រទេស។ មួយបេ គឺ១០០គីឡូៗហ្នឹង បាទជ្រុងហ្នឹងបាទ។

[១៥:៣៣:២២]

**ស៖** អរគុណលោក។ អម្បាញ់មិញលោកបានបញ្ជាក់នៅមុខសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះដែរថា លោកបានជួបលោក ខៀវ សំផន ដែលចុះមកត្រួតពិនិត្យបញ្ហាសម្រិតសម្រាំងសំឡី-គ ដែលត្រូវនាំចេញ។ នេះលោកជួបលើកទី១? ហើយដល់ហើយ ក្រៅពីការជួបលើកទី១ហ្នឹង លោកមានដែលជួបលោក ខៀវ សំផន នៅទីកន្លែងណាផ្សេងទៀតទេចាស?

**ឆ៖** បាទ អរគុណ សូមបញ្ជាក់បន្ថែម។ ដែលគាត់មកគឺមិនមានសំណេះសំណាលអីយូរទេ

គឺដើរអ៊ីចេះតែម្ដងរហូតទៅ មានឈ្មោះវ៉ាន់ រិទ្ធ នេះ គាត់ដើរពីក្រោយទៅ។ ជួបតែលើកទី១ និងទី២ ដែលបានបញ្ជាក់ជូនអម្បាញ់មិញ។ បានពីរដងហើយដែលឃើញគាត់។

**ស៖** អរគុណលោក។ ចុះពេលថ្ងៃ០៥ ឆ្នាំ១៩៧៩ លោកមានបានឃើញលោក ខៀវ សំផន ជិះរថក្រោះរត់ចេញពីទីក្រុងភ្នំពេញទេចាស?

**ឆ៖** អរគុណ។ មិនបានឃើញទេបាទ។ ពេលរត់ចេញ គឺអត់ដឹង។ មិនដឹងចេញប្រលោះណា ខ្ញុំអត់ដឹងដែរ។

[១៥:៣៤:៥២]

**ស៖** អរគុណលោក។ អម្បាញ់មិញលោកបានបញ្ជាក់នៅមុខអង្គជំនុំជម្រះថា លោកបានឃើញការចាប់ខ្លួនជាច្រើនលើកច្រើនសារនៅកំពង់សោម នៅក្នុងវត្តទួលទំពូង។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ឲ្យលោកបញ្ជាក់ដែរថា តើលោកមានការដឹងទេថា តើការចាប់ខ្លួនទាំងនោះវាមកពីខាងណាដែរ ចេញបញ្ជាមកពីខាងណាលោកមានដឹងទេ? ហើយលោកបានបញ្ជាក់ថែមទៀតថា លោកឃើញឡានម-៧០ ដូចបានបញ្ជាក់អំមិញហ្នឹង។ ម-៧០ ឬម-៨៧០ហ្នឹង នេះជាការស្ដាប់ដែលមិន វាអត់ទាន់ស៊ីសង្វាក់គ្នា។ អ៊ីចឹងបានថាខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកដឹងថា ម-៧០ ឬម-៨៧០ហ្នឹងចេញមកពីខាងណា លោកមានដឹងទេចាស?

**ឆ៖** បាទ អរគុណ សូមបញ្ជាក់បន្ថែម។ ឃ្លានេះគឺការកត់ត្រាក៏មានការច្រឡំ ខ្ញុំអត់ដែលដឹងថា ម-៨៧០ ទេមានតែ ម-៧០ ដែលក្រឡេកពីចម្ងាយទៅឃើញលេខ៧០ប៉ុណ្ណោះឯងទេបាទ។ តែត្រង់មកពីខាងណាៗអ្នកបញ្ជា គឺខ្ញុំអត់បានដឹង។ បាទៗ តែឃើញៗតែម្ដង យកទៅ។

[១៥:៣៦:០៩]

**ស៖** អរគុណលោក។ ដោយពេលវេលារបស់ខ្ញុំខ្លី ខ្ញុំសូមសួរសំណួរលោកមួយពីរទៀតជាចុងក្រោយ។ ក្រៅពី កុយ ធួន ដែលលោកធ្លាប់ជួបជាមេដឹកនាំខ្មែរក្រហម តើលោកមានជួបមេដឹកនាំខ្មែរក្រហមណាទៀតទេលោក?

**ឆ៖** អរគុណ។ ចំពោះលោក កុយ ធួន ខ្ញុំឮតែឈ្មោះ តែមិនបានឃើញរូបភាពទេ សូមបញ្ជាក់ជូនអ៊ីចេះ។ ឮតែឈ្មោះដែលគេហៅយកទៅប្រជុំ ហើយប្រាប់ថា កុយ ធួន ហៅ ធុច ហៅ ឃួន ឈ្មោះគឺមានបីអ៊ីចឹងតែម្ដង ប្រធានភូមិភាគឧត្តរ។ អ៊ីចេះគឺឮតែឈ្មោះទេ ឲ្យឃើញរូប ឬនិយាយតទល់ជាមួយអត់ដឹង អត់ឃើញ។

**ស៖** អរគុណលោកនេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងកំណត់ហេតុរបស់លោកដែលធ្វើជាមួយ ឌី.ស៊ី.ខេម លេខ19.177, ERN ជាភាសាខ្មែរលេខ 00055269 និង ERN ជាភាសាអង់គ្លេសលេខ 00679695, លោកបានបញ្ជាក់ថា "កាលខ្ញុំនៅភ្នំពេញតែងបានមកប្រជុំដឹងថា ឈ្មោះ សុន សេន ខាងក្រសួងការពារប្រទេស, នួន ជា ខាងសភាប្រជាជន, អៀង សារី ខាងក្រសួងការបរទេស, ជុំ ជឿន ខាងប្រធានសុខាភិបាល, ឌុច ខាងផ្នែកកសិកម្ម, ហ៊ូ នឹម ខាងឃោនាការ, តាយ៉ុន នៅជាមួយហ៊ូ នឹម និងខៀវ សំផន"។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមត្រង់ចំណុចនេះ តើកិច្ចប្រជុំនេះធ្វើនៅជាមួយអ្នកណា? នៅកន្លែងណាលោក?

[១៥:៣៨:០៥]

**ឆ៖** បាទ អរគុណ សូមបញ្ជាក់បន្ថែម។ ត្រង់ចំណុចនេះគឺថា ពេលដែលប្រជុំក្នុងថ្ងៃ១០ ថ្ងៃ២០ ក្នុងមួយខែ គឺថាប្រជុំបីដងនៅក្នុងក្រសួង អ៊ីចេះ។ មាននរណាក្រៅពីលោក វ៉ាន់ រិទ្ធ ដែលជាប្រធានពាណិជ្ជកម្មនៅម្ដុំទួលទំពូងនេះឯង គេជម្រាបប្រាប់ហេតុផលថ្នាក់ដឹកនាំលើៗទាំងអស់គ្រប់រូបបាទ។ ប្រជុំទូទៅមួយក្រសួងមិនមែននេះទេ ទាំងកម្មករទាំងអស់គ្នា។

**ស៖** អរគុណលោក។ តើខ្លឹមសារនៃការប្រជុំនោះភាគច្រើនលើកឡើងពីបញ្ហាអីលោក?

**ឆ៖** បាទ សូមអធ្យាស្រ័យ។ ពេលប្រជុំគឺចាំមិនបានអស់ គឺមានការណែនាំតែអំពីហេតុផលរបស់ការដឹកនាំខាងសង្គមរបស់គេនោះឯងបាទ ជំនាន់នោះឯងបាទ ខ្ញុំមិនអាចរៀបរាប់កើតអស់ទេបាទ មិនចាំ។

**ស៖** អរគុណលោក ក្នុងការប្រជុំនីមួយៗហ្នឹង តែងលើកឡើងពីគោលនយោបាយរបស់បក្សនិយាយពីសភាពការណ៍ខ្មាំង ឬសភាពការណ៍បោសសម្អាតខ្មាំងបង្កប់ផ្ទៃក្នុងអីលោក?

[១៥:៣៩:៤០]

**ឆ៖** បាទ អរគុណ។ ដូចខ្ញុំបានជម្រាបប្រសាសន៍ខាងដើម គឺគេលើកឡើងដដែលអ៊ីចេះឯងគឺថា តែមិនចាំបាច់រឿងអ្វីធំដុំទេ កាលណាមានស្លាព្រាមួយបាក់ក៏ខ្មាំងនៅបង្កប់ស៊ីរូងផ្ទៃក្នុងដែរ។ អ៊ីចេះឲ្យពួកមិត្តទាំងអស់នេះខំប្រឹងប្រែងតាមដានស្រាវជ្រាវ និងខំធ្វើការងារដើម្បីបម្រើបក្សបដិវត្តន៍នេះឲ្យមានការរីកចម្រើនទៅមុខ។ គេថា គេនិយាយច្រើន ខ្ញុំចាំមិនបាន។ គេការឃោសនារបស់គេអប់រំថា "យើងមិនបានធ្វើស្រែដូចម៉ែឪនៅខាងក្រោយផង យើងមានរបបហូបគ្រប់គ្រាន់ ចុះទម្រាំគាត់អ្នកធ្វើផ្ទាល់ដៃនោះ វាមានការសប្បាយរីករាយ"។ អ៊ីចេះបញ្ជាក់ទឹកចិត្តនេះ វាអាចទៅតាមសម្ដីដែលនិយាយ។

តែដល់ការពិត ពេលដែលថាសង្គមប្រែប្រួលដែរ ដល់ផ្ទះវិញ បងប្អូនគឺត្រូវស្លាប់ ហិនហោច បាត់បង់អស់។ អ៊ីចេះ វាអាចខុសផ្ទុយគ្នាមេឃនិងដី។ បាទ សូមអរគុណ។

**ស៖** សូមអរគុណលោក ហើយតើការប្រជុំហ្នឹង ធ្វើញឹកញាប់ទេលោក ក្នុង១ខែប៉ុន្មានដង ឬក៏យ៉ាងម៉េចការប្រជុំហ្នឹង?

[១៥:៤១:០៧]

**ឆ៖** បាទ អរគុណ។ ដូចខ្ញុំជម្រាបខាងដើម ១ខែគេប្រជុំបីដង គឺប្រជុំទូទៅ អាហ្នឹងបើកទូលាយតែម្តង ទាំងកម្មករ ទាំងមេក្រុម មេកងអីក៏ដោយ គឺប្រជុំទាំងអស់ចម្រុះ។ ១ខែបីដង។

**ស៖** ខ្ញុំឱ្យលោកបញ្ជាក់បន្ថែមបន្តិចទៀតទេទៅលើចំណុចនេះដែរ តើសមាសភាពណាខ្លះដែលចូលរួមនៅក្នុងការប្រជុំហ្នឹងលោក?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណេះ!

**លោក ស៊ឹម ហោ៖**

**ឆ៖** បាទ និយាយទៅនៅដដែលទេ ប្រជុំក្នុងមួយខែបីដង មិនរើសថាថ្នាក់ដឹកនាំលើធំៗទេ។ អានេះ បើនិយាយទៅចាប់ពីប្រធានក្រសួង ប្រធានមន្ទីរអី គឺចូលរួមចម្រុះទាំងអស់ ទាំងកម្មករ ទាំងអស់។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកសាក្សី ចំពោះការបំភ្លឺដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ។ សូមបញ្ចប់ដោយពេលវេលាមានកំណត់។ សូមអរគុណ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោកសាក្សី។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** ខ្ញុំសូមចោទសំណួរបន្តិចបន្តួចទេ លោកបានឆ្លើយតបនឹងសំណួរច្រើនមកហើយ។ នេះសុទ្ធតែជាសំណួរសុំព័ត៌មានលម្អិតពីលោកទេ។ ជាបឋមនោះ កាលពីដំបូងលោកជាទាហាន ហើយ

ក្រោយមកគេបញ្ជូនទៅលោកទៅកំពង់សោម ហើយនៅកន្លែងនោះលោកក្លាយកម្មករ។ តើលោកបានប្រកែកហ្នឹងការចាត់តាំងលោកទៅកំពង់សោមហ្នឹងដែរឬទេ? ខ្ញុំយល់មិនសូវច្បាស់អម្បាញ់មិញនោះ តើលោកនៅតែមានទំនាក់ទំនងជាមួយយោធាដែរឬទេ នៅពេលដែលលោកនៅកំពង់សោមនោះ ធ្វើការជាកម្មករនោះ ហើយពេលក្រោយមកលោកត្រឡប់មកភ្នំពេញវិញ សួរថាមានទំនាក់ទំនងជាមួយយោធាទេកាលនោះ?

[១៥:៤៣:២៨]

**លោក ស៊ឹម ហោះ៖**

**ឆ៖** អរគុណ។ សូមបន្ថែមសេចក្ដី ជម្រាបជូនថា ពេលដែល-- បើនិយាយឲ្យខ្លីថាក្រោយរំដោះឆ្នាំ៧៥នេះទៅ ដែលត្រឡប់ទៅកំពង់សោម គឺឈប់ធ្វើទ័ព អត់មានពាក់ព័ន្ធអ្វីជាមួយកងទ័ពទៀតទេ ធ្វើកម្មកររហូត។ បាទ លីសែងរហូត។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺនេះ ប្រហែលជាខ្ញុំតាមដានសវនាការនេះមិនបានច្បាស់ បានជាសួរសំណួរហ្នឹងទៅលោកអម្បាញ់មិញនេះ។ ពេលដែលលោកនៅកំពង់សោម លោកបាននិយាយ ហើយនិយាយទៀត ថាលោកជាអ្នកដែលសែងលីអីវ៉ាន់ចេញពីកប៉ាល់។ តើមានផលិតផលដែលគេនាំចេញពីប្រទេសខ្មែរតាមកប៉ាល់បរទេស ហើយលោកដឹងទេ ដឹងថាដែលនៅក្នុងហ្នឹងមានអីខ្លះទេ លោកអាចស្មានដឹងទេ នៅក្នុងទំនិញដែលលោកដាក់ចេញ ដាក់ចូលកប៉ាល់បរទេសនោះ?

[១៥:៤៤:៥១]

**ឆ៖** បាទ អរគុណ សូមបញ្ជាក់បន្ថែម។ កាលដែលដាក់ចេញ មានសម្ភារៈជាអង្ករ អ្វីផ្សេងៗ ដូចបានបញ្ជាក់ជូនខាងដើមរួចហើយបាទ ហើយនិងសម្ភារៈមួយចំនួន ជាចប, ប៉ែល ថ្នាំបាញ់ ថ្នាំសម្លាប់សត្វល្អិតគ្រប់មុខទាំងអស់ ព្រមទាំងឡានដូចខ្ញុំបានរៀបរាប់ខាងដើម។ តែក្នុងនោះសម្រាប់ផលិតផលរបស់កម្ពុជាដែលចេញទៅក្រៅនោះដែលខ្ញុំបាននៅកន្លែងនោះក៏ដឹងដែរ បានឃើញនិងបានលីសែងចេញទៅដាក់រទេះភ្លើងដាក់កប៉ាល់ចេញទៅវិញមានកៅស៊ូ កៅស៊ូក្រែប កៅស៊ូឆៅ សំឡី-គ ហើយអង្ករគេសម្រាំងយកលេខ១បានចេញទៅក្រៅ, សណ្ដែកសៀង សណ្ដែកបាយ ទាំងអស់សណ្ដែកហើយនិងកៅស៊ូបានចេញទៅ។ តែត្រង់តម្លៃយ៉ាងម៉េចគឺអត់មានទេ នៅក្នុងស្រុកខ្មែរជាលុយកាក់ចាយវាយគឺអត់ដឹង។ គ្រាន់តែបានឃើញនេះបញ្ជាក់ជូនឲ្យអស់។

**ស៖** លោកមិនដែលលីសែង សត្វយកទៅដាក់កប៉ាល់ទាំងអស់នោះទេ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អ៊ីចេះ កម្មករសម្រាប់ការលើកដាក់ និងគ្រឿងចក្រដែរ មានលេរីទ័រ វាជញ្ជូនទៅយើងលើកដាក់ៗស្ទួនគ្នាម្តងបួនប្រាំបេ ដប់បេ បើកៅស៊ូនោះយើងអាចលីព្រោះកៅស៊ូក្រែបប៉ុនៗនេះម៉ុៗទម្ងន់វាប្រហែលជា ៤០គីឡូអ៊ីចេះ ៥០គីឡូអស់ហើយចេះតែលីទៅ។ ហើយគេលើកដាក់បន្តទៅ។

**ស៖** សូមចូលទៅសំណួរមួយទៀត។ នៅពេលដែលគេបញ្ជូនលោកមកភ្នំពេញវិញពីកំពង់សោមនោះ សំណួរខ្ញុំដូចតទៅនេះ តើគេមានពន្យល់លោកច្បាស់លាស់ទេ អំពីថាហេតុអីក៏លោក និងមនុស្សមួយចំនួនផ្សេងទៀតត្រូវបានបញ្ជូនត្រឡប់មកភ្នំពេញវិញ?

[១៥:៤៦:២២]

**ឆ៖** បាទ សូមអរគុណសូមបញ្ជាក់បន្ថែម។ គឺមិនបានដឹងពីហេតុការណ៍ថាយ៉ាងម៉េចទេ អានេះគ្រាន់ថាគេបំបែកកម្លាំងពីរព្រោះនៅក្នុងវរសេនាតូចនោះមានចំនួនច្រើនដែរ បួន-ប្រាំ- ៦០០នាក់ គេដកយក២០០បញ្ជូនមកលើវិញ ដើម្បីជួយធ្វើកិច្ចការខាងនេះវិញ ប្រហែលខ្វះកម្មករដឹង យើងខ្ញុំមិនដឹងដែរត្រង់នេះ។

**ស៖** អ៊ីចឹងបានន័យថា គេមិនដែលបញ្ជាក់ប្រាប់លោកពីមូលហេតុទេ? អ៊ីចឹងនៅពេលដែលលោកមកដល់ភ្នំពេញលោកបានពន្យល់ច្បាស់លាស់អំពីដំណើរ ឬក៏សម្រាកច្រើនកន្លែង ជាពិសេសគឺចូលមកគីឡូម៉ែត្រទី៦ ហើយនិងមកដល់ទួលទំពូង។ ក្រៅពីសមាជិកកងវរសេនាតូចរបស់លោក តើមានកម្មករផ្សេងទៀតដែលធ្វើការនៅក្នុងឃ្លាំងទាំងអស់នេះ ឬក៏ក្នុងរោងចក្រទាំងអស់នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែដឹងចំពោះឯក្រសួងរបស់ខ្ញុំពាណិជ្ជកម្មក្នុងប្រទេស។ តែសម្រាប់កម្មករក្រៅដែលទៅធ្វើការមានជួបគ្នាដែរបាទ ដែលមកនៅភ្នំពេញនៅលីសែងនៅម្តុំគីឡូលេខ៦នោះអីមានជួបដែរ ប៉ុនគេទៅផ្នែកគេយើងមកផ្នែកយើងទៅ។

**ស៖** តើនៅក្នុងការបំពេញការងារជាកម្មកររបស់លោកនេះ លោកធ្លាប់បានធ្វើការនៅក្បែរៗក្មេងៗដែលធ្វើការជិតលោកទេ?

[១៥:៤៩:៥១]

**ឆ៖** អរគុណ។ កន្លែងធ្វើការនៅម្តុំទួលទំពូងនេះ ឬក៏កន្លែងផ្សេងពីនេះ មិនមានកុមារាកុមារីនៅជិតទេ គេដកទៅដាក់កន្លែងមន្ទីរកុមាររបស់គេ មិនដឹងកន្លែងណា មានតែកម្លាំងពេញពលកម្មតែម្តងបាទ។

**ស៖** ខ្ញុំសោកស្តាយណាស់ដែលរកកន្លែងមិនឃើញ ប៉ុន្តែលោកហាក់ដូចជា និយាយអម្បាញ់

មិញនេះថា មានកុមារៗអាយុប្រហែលជា ១២-១៣ឆ្នាំ ខ្ញុំរកឃោងនេះមិនឃើញ។ ខ្ញុំគិតថាមាននៅក្នុងឯកសារថា IS19.177, នៅទំព័រ២២-២៣ ដែលជាភាសាអង់គ្លេស ហើយនិងភាសាខ្មែរ គឺ 00055 238 ដល់ 239 ត្រង់កន្លែងនេះ លោកនិយាយថា "មានយុវជនអាយុ១២-១៣ឆ្នាំ -- គេសួរលោកថា ពួកគេហ្នឹងតែធ្វើការងារឬក៏យ៉ាងម៉េច លោកឆ្លើយថា ពួកនុ៎ងត្រូវធ្វើការងារដូចមនុស្សធំអ៊ីចឹង"។ ខ្ញុំមិនដឹងថានៅភ្នំពេញ ឬក៏នៅកំពង់សោមទេ ក្មេងជំទង់ទាំងអស់នេះ។ អ៊ីចឹងអ្វីដែលលោកនិយាយនេះ ហាក់ដូចជាមិនសូវច្បាស់។ អ៊ីចឹងបើតាមអ្វីដែលលោកនិយាយនេះ គឺថាឃើញលោកហ្នឹងធ្លាប់បានមានទំនាក់ទំនងខ្លះដែរជាមួយនឹងក្មេងៗជំទង់ទាំងអស់នេះ?

[១៥:៥១:៥២]

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ អាយុ១២-១៣ មានមួយចំនួនដែលអង្គាល់នៅម៉្តុំតាខ្មៅ ធ្វើការកន្លែងគ្រីបសំឡី-គនោះ អានោះគេហៅថា កូនកម្មករចាស់ ពីសម្តេច ជំនាន់សម្តេច។ ជំនាន់ លន់ នល់ នុ៎ង អ៊ីចឹងគេអត់ជម្លៀសទេ។ គេយកម៉ែវាដាក់ផ្សេង វាទុកអាកុមារអាយុ១២-១៣ឆ្នាំនេះឲ្យនៅជាមួយដើម្បីជួយប្រាប់យើងជាកម្មករថ្មីក្រោយនេះអត់ដឹងអំពីកិច្ចការនៅក្នុងរោងចក្រគ្រីបសំឡី-គ សំឡីអីបាទ។ នេះសូមបញ្ជាក់អស់យោបល់។

**ស៖** សូមអរគុណ។ លោកសាក្សី លោកបានរៀបការនៅខែឧសភា-មិថុនា ឆ្នាំ១៩៧៦ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានទេ គឺថាការរៀបការនេះ គឺថាដោយសារលោកស្ម័គ្រចិត្តរៀបការដោយខ្លួនឯង ឬក៏ដោយការកំណត់ដោយអង្គការ?

[១៥:៥៣:១៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ប្រហែលជាខាងមេធាវីដើមបណ្តឹងគួរតែពន្យល់ថាតើហេតុអ្វីបានជាចាំបាច់ត្រូវសួរសំណួរបែបនេះ? តើវាមានបញ្ហាអ្វី ពីព្រោះថាការរៀបការដោយបង្ខំមិននិយាយពាក់ព័ន្ធទៅនឹងការទំនាក់ទំនង មិនពាក់ព័ន្ធថាតើទៅនឹងការជម្លៀសដោយបង្ខំ ឬក៏ទួលពោធិ៍ជ្រៃទេ។ ខ្ញុំគិតថាការសួរសំណួរបែបនេះ ហាក់ដូចជាទាក់ទងនឹងការរៀបការដោយបង្ខំដែលស្ថិតនៅក្រៅ

វិសាលភាព។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ រៀបការដោយបង្ខំនោះ នៅថាវាជាផ្នែកមួយនៃគោលនយោបាយទាំងប្រាំ។ អ៊ីចឹងជាការសំខាន់ណាស់ដែលលោកសាក្សីនេះត្រូវឆ្លើយតបព្រោះថា គាត់ធ្លាប់បាននិយាយពីការរៀបការរបស់គាត់។ អ៊ីចឹងសំណួរប្រភេទនេះ គេធ្លាប់សួរច្រើនដងហើយទៅសាក្សីនោះសាក្សីផ្សេងៗ ដោយសារការរៀបការដោយបង្ខំនេះវាជាផ្នែកមួយនៃគោលនយោបាយទាំងប្រាំ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៤:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរសួរចុងក្រោយដោយមេធាវីនាំមុខ -- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិនេះទេ ពីព្រោះសំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការនៅក្នុងសំណុំរឿង ០០២/០១ នេះទេ។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** លោកសាក្សី ខ្ញុំសូមចោទសំណួរចុងក្រោយមួយ។ លោកបានលើកឡើងអម្បាញ់មិញនេះថាត្រូវតែធ្វើដូចជាមើលមិនឃើញ ហើយលោកផ្ទាល់ហ្នឹងក៏ដូចជាសហការីរបស់លោកដែរ អ្នកធ្វើការជាមួយលោកដែលហ្នឹងគឺស្ថិតនៅក្នុងភាពភ័យខ្លាច ខ្លាចគេចាប់ខ្លួន។ តើលោកអាចពន្យល់ជូនតុលាការបានដែរឬទេថា មានអ្វីដែលរារាំងលោកមិនឲ្យមើលឃើញ មើល ហើយអ្នកណាធ្វើឲ្យលោកភ័យ? តើការភ័យខ្លាចមានប្រភពមកពីណា កាលដែលលោកត្រូវបង្ខំចិត្តត្រូវធ្វើដូចខ្វាក់នេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន តាមខ្ញុំស្ដាប់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីហាក់ដូចជា លោកស្រីកំពុងតែដកស្រង់នូវអត្ថបទណាមួយពីឯកសាររបស់តុលាការនេះ។ បើហេតុដូច្នេះមែន សូមឲ្យលោកស្រីបង្ហាញពីទីតាំងជាក់ស្ដែង នៅទីតាំងកន្លែង ឬលេខ ERN ណាមួយលដែលស្រីធ្វើការដកស្រង់នេះ។ សូមអរគុណ។

[១៥:៥៦:៥៥]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ខ្ញុំមិនយោងទៅលើឯកសារណាទេ លោក ស៊ឹម ហោ ហ្នឹងបាននិយាយអម្បាញ់មិញនេះ ខ្ញុំមិនអាចឱ្យលេខយោងបានទេ។ លោកក៏បានឮអម្បាញ់មិញដូចខ្ញុំដែរ។ គាត់និយាយថាត្រូវធ្វើដូចជាមិនឃើញអីចឹងទៅ។ ខ្ញុំឮច្បាស់ណាស់អំមិញហ្នឹង ហើយខ្ញុំបានកត់ទៀតផង។ អីចឹងវាធ្វើឱ្យយើងចោទសំណួរមួយថា តើថាអីចេះបើលោកធ្វើជាមិនឃើញនោះមានការភ័យខ្លាចអី ហេតុអីបានជាលោកធ្វើមិនឃើញបិទភ្នែកនេះ។ នេះសំណួរខ្ញុំតែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរនេះ!

**លោក ស៊ឹម ហោ៖**

**ឆ៖** អរគុណ។ សូមជម្រាបទៅខាងដើមបណ្ដឹងបានជ្រាប មូលហេតុដែលយើងមិនអាចនឹងគេហៅថាសួរ ថាហាក់បីដូចជាបិទភ្នែក ចុះភ័យខ្លាចហើយ។ បាទ ខ្ញុំចង់និយាយថាសង្គមនោះដែលយើងទាំងអស់គ្នាមិនអាចទៅនឹងតវ៉ាបានបាទ។ អីចេះការចាប់ចងខ្នោះឃ្នាង គឺមានជារៀងរហូត បន្តបន្ទាប់។ អីចេះការភ័យព្រួយតែគ្រាន់តែហ្នឹងចេញវាអត់រួចទេ ចេះតែទ្រាំ។ នេះសូមអស់យោបល់ សូមយល់ប៉ុណ្ណឹងចុះ។ បាទអរគុណ។

[១៥:៥៨:៤២]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោក ស៊ឹម ហោ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណសាក្សី។ បាទឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបរំឭកជូនដល់ភាគីនៃរឿងក្ដីនេះថា កាលបរិច្ឆេទនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃ -- សវនាការ និងកិច្ចប្រជុំរៀបចំសវនាការដែលគ្រោងធ្វើនៅថ្ងៃស្អែកនេះ គឺមានការប្រែប្រួលបន្តិច គឺនៅក្នុងកាលវិភាគដែលអង្គជំនុំជម្រះជម្រាបជូនទៅភាគីថា កិច្ចប្រជុំរៀបចំសវនាការគ្រោងកំណត់ធ្វើរសៀលថ្ងៃស្អែក ប៉ុន្តែដោយសារសាក្សីរូបនេះត្រូវបន្តផ្ដល់សក្ខីកម្មទៀត។ ហើយមេធាវីប្រឹក្សាសាក្សី គាត់មិនមានឱកាសក្នុងការអាចចូលរួមនៅព្រឹកថ្ងៃស្អែកបាន។ គាត់សុំថាឱ្យបន្ត

ស្តាប់សក្ខីកម្មសាក្សីរូបនេះនៅរសៀលវិញ។ ដូច្នេះអង្គជំនុំជម្រះជម្រាបថា កិច្ចប្រជុំរៀបចំសវនាការដែលគ្រោងធ្វើនៅរសៀលនេះ គឺលើកមកធ្វើនៅព្រឹកថ្ងៃស្អែក។ សូមភាគីនៃរឿងក្តីនេះជ្រាប។ ហើយចំណែកឯការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ឹម ហោ ហ្នឹងគឺយើងធ្វើនៅពេលរសៀលចាប់ផ្តើមពីម៉ោងមួយសាមសិបនាទីទៅ។

[១៦:០០:០៣]

ដោយឡែកសាក្សីដែលផ្សេងទៀត ដែលយើងគ្រោងធ្វើនៅរសៀលនេះ និងនៅថ្ងៃស្អែកនោះ ដោយសារមានការកិលនូវកាលវិភាគសវនាការដូចដែលអស់លោក លោកស្រីបានជ្រាបហើយ។ ដូច្នេះសាក្សីចំនួនពីររូបដែលយើង ដែលនៅសេសសល់នេះ អង្គជំនុំជម្រះនឹងគ្រោងធ្វើនៅក្នុងសប្តាហ៍ក្រោយ ដោយសាក្សី TCW-384 ធ្វើនៅថ្ងៃចន្ទ ហើយនិងថ្ងៃពុធ សាក្សី TCW-801 សូមភាគីជ្រាប។ ហើយបញ្ហាទី២ គឺអង្គជំនុំជម្រះសូមសួរទៅជនជាប់ចោទថា នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលគ្រោងធ្វើនៅព្រឹកថ្ងៃស្អែកនេះ តើលោកជនជាប់ចោទមានបំណងចូលរួមដែរឬទេ? ពីព្រោះនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះ គឺជនជាប់ចោទមានសិទ្ធិក្នុងការជ្រើសរើសចូលរួមក៏បាន ចូលរួមក៏បាន។

[១៦:០០:៥៩]

**លោក ខៀវ សំផន៖**

បាទ លោកប្រធាន គឺខ្ញុំបាទសូមសម្រាក *(ឮមិនច្បាស់)*។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណអត់អីទេ នេះជាការជម្រើសដើម្បីគ្រាន់តែបញ្ជាក់ច្បាស់លាស់ បើសិនជាជម្រើសអ៊ីចឹងអង្គជំនុំជម្រះនឹងពិចារណាសម្រេចដូច្នេះ។

សូមអញ្ជើញមេធាវីការពារក្តីលោក នួន ជា សូមបញ្ជាក់បញ្ហានេះ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំប្រហែលជាត្រូវជម្រាបនូវព្រឹកស្អែក ព្រោះខ្ញុំអត់ទាន់ទទួលព័ត៌មានទេនាពេលនេះ ខ្ញុំមិនប្រាកដថា តើលោក នួន ជា ចង់ចូលរួម ឬមិនចង់ចូលរួមទេក្នុងពេលឥឡូវនេះ ខ្ញុំអត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះត្រូវការព័ត៌មានឥឡូវនេះ មូលហេតុវាជាប់ពាក់ព័ន្ធទៅនឹងបញ្ហារបស់អង្គជំនុំជម្រះថាតើឲ្យនាំខ្លួនជនជាប់ចោទមកកាន់ចូលរួមកិច្ចដំណើរការប្រជុំ ឬក៏សវនាការហ្នឹងនៅពេលណា? ដូចជា

លោក ខៀវ សំផន បានច្បាស់ បញ្ជាក់ច្បាស់លាស់ហើយ។

*(សម្រាករយៈពេលខ្លី)*

[១៦:០៣:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោក នួន ជា មិនចង់ចូលរួមទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវព័ត៌មានជាក់ច្បាស់នេះ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៣ ខែមិថុនា ឆ្នាំ២០១៣។ នៅថ្ងៃស្អែកនេះនៅពេលព្រឹក ចាប់ពីម៉ោងប្រាំបួនអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើនូវកិច្ចប្រជុំរៀបចំសវនាការ ហើយនៅពេលរសៀលអង្គជំនុំជម្រះសាលាដំបូង នឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ឹម ហោ ដែលនឹងបន្តសួរដេញដោលដោយក្រុមមេធាវីការពារក្ដីដែលនឹងចាប់ផ្ដើមសួរពីក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដែលជាម្ចាស់សំណើមុននឹងមេធាវី នួន ជា សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

លោក ស៊ឹម ហោ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មរបស់លោកនៅរសៀលថ្ងៃស្អែកទៀត ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងមួយនិងសាមសិបនាទីរសៀល។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី ស៊ឹម ហោ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលថ្ងៃស្អែកនៅវេលាម៉ោងមួយសាមសិបនាទី ហើយលោកមេធាវី ម៉ម រិទ្ធា ដែលជាមេធាវីប្រឹក្សាសាក្សីសូមអញ្ជើញចូលរួមដូចគ្នានឹងសាក្សី ស៊ឹម ហោ ដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ទាំងពីររូបមក

ចូលរួមសវនាការនេះវិញ នៅរសៀលថ្ងៃស្អែក ឲ្យមុនម៉ោងមួយសាមសិបនាទី។ ហើយដូចសព្វដង អ៊ីចឹង គឺលោក នួន ជា គឺបង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*